ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**
**នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"**
**សាធារណៈ**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩**
**សវនាការលើកទី៧២**

**ចៅក្រមសាលាដំបូង៖**
លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**
លោកស្រី សែ កុលវុឌ្ឍី
លោក ឌុច ផារី
កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha Wexels-Riser)*
លោក ម៉ាតូ គ្រីស្ពារ *(Mr. Matteo Crippa)*
លោក ចេមស៍ វ៉លតុន*(Mr. James WALTON)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**
លោក សេង ប៊ុនឃាង
លោក វីលៀម ស្មីត *(Mr. William SMITH)*

លោក អានីស អះមេដ *(Mr.Anees AHMED)*

លោក ប៉ាក ច័ន្ទលីណូ

លោក បូចាន់ លីសាក់ *(Mr.Bojan LISAC)*

**ជនជាប់ចោទ៖**

លោក កាំង ហ្កេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ម៉ុច សុវណ្ណារី

កញ្ញា ទី ស្រ៊ីនណា

លោក គង់ ពិសី

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កែវ កូវរតនៈ

# ឧបសម្ព័ន្ធ

## ជនជាប់ចោទ: កាំង ហ្គេកអ៊ាវ ហៅ ឌុច

សួរដោយលោក វីលៀម ស្មីត ផ្ដើមពី........................................ទំព័រ ១
សួរដោយលោក សេង ប៊ុនឃាង ផ្ដើមពី........................................ទំព័រ ២០
សួរដោយលោក ការ សាវុត្ថ ផ្ដើមពី........................................ទំព័រ ២៣
សួរដោយលោក ហ្វ្រង់ស្វ័រ រូ ផ្ដើមពី........................................ទំព័រ ៣០

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អានីស អះមេដ | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:១៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតាមកាលវិភាគនិងការជូនដំណឹងកាលពីម្សិលមិញរបស់អង្គជំនុំជម្រះ ។ ថ្ងៃនេះយើងបន្តកិច្ចដំណើរការនីតិវិធីស្តាប់ចម្លើយជនជាប់ចោទ ពាក់ព័ន្ធទៅនឹងអត្តចរិតរបស់ជនជាប់ចោទ ដែលសួរដោយភាគី ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទមកកាន់ឈើរាំងក្រចកសេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។

អង្គជំនុំជម្រះសូមប្រគល់វេទិកានេះទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការសួរសំណួរទៅកាន់ជនជាប់ចោទអំពីអត្តចរិតរបស់ជនជាប់ចោទ ហើយសូមជម្រាបថា សហព្រះរាជអាជ្ញាមានពេលវេលាមួយម៉ោងនិងដប់ប្រាំនាទីក្នុងការសួរនេះ ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វីលៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម លោកមេធាវី ហើយនិងលោក កាំង ហ្គេកអ៊ាវ នេះជាចុងក្រោយដែលថា សហព្រះរាជអាជ្ញាបានស្នើ ហើយសូមអរគុណជាមុន ដើម្បី-- ចំពោះការឯកភាព និងឆ្លើយនូវសំណួរថ្ងៃនេះ ហើយសុំឲ្យលោកផ្តោតអារម្មណ៍ទៅលើសំណួរឲ្យបានល្អ ហើយឲ្យសង្ខេបបំផុតតាមដែលអាចធ្វើទៅបាន ។ ហើយយើងមានប្រធានបទជាច្រើនដែលយើងចង់បញ្ចប់ក្នុងតែរយៈពេលមួយម៉ោង។ ហើយចំណុចមួយមុននឹងយើងចាប់ផ្តើមនោះ គឺថាយើងត្រូវមានឯកភាព ប្រសិនបើលោកត្រូវបើកចិត្តឲ្យបានទូលាយ ឲ្យបានច្បាស់ថា តើលោកជាមនុស្សបែបណា? ជាអ្នកណា? ក្នុងរយៈពេល៣០ឆ្នាំកន្លងមកនេះនៅស-២១ ដើម្បីជាការជួយដល់អង្គជំនុំជម្រះ ដើម្បីព្យាយាមបញ្ជាក់នូវការពិតអំពីតួនាទី ហើយនិងថា តើមានអ្វីកើតឡើងនៅស-២១ នោះ ។

ជាបឋមខ្ញុំសូមតាមដាន ឬក៏សូមបន្តពីចៅក្រម ឡាវែន៍ ពីម្សិលមិញនោះ គឺដែលពិភាក្សាមួយចំនួនទាក់ទងទៅនឹងគំនិតនៅក្នុងគ្រួសាររបស់លោក ហើយសេចក្តីសម្រេចមួយចំនួនដែលលោកបានធ្វើទាក់ទងទៅនឹងក្រុមគ្រួសារ នៅពេលដែលលោកធ្វើការនៅស-២១ ។ ហើយឆ្លើយតបទៅនឹងចៅក្រមនោះ លោកបាននិយាយថា "កូនរបស់ខ្ញុំជាកូនរបស់អង្គការ គ្រាន់តែចិញ្ចឹមវាដើម្បីបម្រើចលនាបដិវត្តន៍

នោះជាភារកិច្ចរបស់ខ្ញុំពេលនោះ" ពេលនោះលោកបាននិយាយទៀតថា ហើយកែខ្ញុំបើខ្ញុំនិយាយខុស "ហើយខ្ញុំពេញក្រុមគ្រួសារ ហើយមានសេចក្តីស្រឡាញ់ ឲ្យគេស្រឡាញ់បដិវត្តន៍ ហើយចូលបដិវត្តន៍" ។

[០៩:០៩:១៥]

**ស៖** សំណួរខ្ញុំចំពោះលោក តើលោកមានគោលបំណងដូចម្តេចដែលថាប្រពន្ធរបស់លោក ហើយនិងកូនរបស់លោក ឲ្យចូលក្នុងបដិវត្តន៍ទេ? តើនៅពេលនោះជាឆន្ទៈរបស់លោកទេ ថាប្រពន្ធ ហើយនិងកូនរបស់លោកនឹងត្រូវបានកើតនៅស-២១? ថាតើពួកគេជាផ្នែកនៃបដិវត្តន៍ ហើយគេជឿបដិវត្តន៍ដែរឬទេក្នុងកាលនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ដំបូងខ្ញុំនិយាយពីទ្រឹស្តី ខ្ញុំនៅតែរក្សាទ្រឹស្តី ដែលខ្ញុំបានគោរពរាយការណ៍ជូនលោកចៅក្រម ឡាវែន៍ ច្បាស់លាស់ហើយ ។ ខ្ញុំចូលបដិវត្តន៍ ខ្ញុំចង់ឲ្យមាតាបិតាខ្ញុំ លោកស្រឡាញ់បដិវត្តន៍ ហើយថ្ងៃណាមួយលោកចូលទៅបដិវត្តន៍ដែរ ។ ខ្ញុំចង់ឲ្យប្អូនខ្ញុំស្រឡាញ់បដិវត្តន៍ ហើយក៏ថ្ងៃណាមួយឲ្យប្អូនខ្ញុំចូលទៅក្នុងបដិវត្តន៍ដែរ ។ នេះមួយរឿង ។

រឿងទីពីរ សូមបញ្ជាក់ជូនលោកដោយស្មោះត្រង់ថា ខ្ញុំជាកម្មាភិបាលមួយរូបរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំគ្មានសិទ្ធិរៀបការជាមួយនឹងជនជម្លៀសទេ ។ ខ្ញុំគ្មានសិទ្ធិរៀបការជាមួយនឹងអ្នក ដែលទៅពីភ្នំពេញ ប្រជាជន១៧ មេសាទេ ។ សូមជម្រាបបញ្ជាក់ជូនលោកចៅក្រមថា ប្រពន្ធខ្ញុំដែលខ្ញុំរៀបការនេះជាបក្ខជនរបស់បក្សកុម្មុយនីស្តកម្ពុជា គាត់ចេញពីផ្ទះទៅនៅកំពូលភ្នំឱរ៉ាល់ តាំងពីឆ្នាំ១៩៦៨ ។ ដូច្នេះខ្ញុំរើសយកបក្ខជនមកធ្វើជាប្រពន្ធ ដូចខ្ញុំនិយាយរួចមកហើយថា "ខ្ញុំពេញចិត្តអ្នកកំពង់ត្រឡាច" ប្រពន្ធខ្ញុំក៏ខ្ញុំរើសអ្នកកំពង់ត្រឡាច កងការពារខ្ញុំក៏ខ្ញុំរើសអ្នកកំពង់ត្រឡាច ។ នៅពេលដែលសក្ខីកម្មរបស់មិត្ត ឈុន ផល នៅទីនេះ មិត្ត ឈុន ផល អ្នកកំពង់ត្រឡាច ។ ដូច្នេះ ខ្ញុំជ្រើសរើសរកអ្នកដែលស្រឡាញ់បដិវត្តន៍ដូចគ្នា ធ្វើបដិវត្តន៍ដូចគ្នា។ នេះគឺអ៊ីចឹង ។ ដល់កូនខ្ញុំកើតមក ជាកូនរបស់អង្គការ ។

ខ្ញុំនិយាយថា "កូនអង្គការនេះ" គឺខ្ញុំចង់និយាយមួយឲ្យច្បាស់ មិនមែនថាកូនជាកូនរបស់អង្គការត្រូវរាយការណ៍ពីម៉ែឪឲ្យអង្គការទេ ។ កូនរបស់អង្គការត្រូវឧបត្ថម្ភវា ចិញ្ចឹមវា សម្រាប់បម្រើអង្គការសម្រាប់ បម្រើជាតិប្រជាជនតទៅទៀត នេះទស្សនៈរបស់កុម្មុយនីស្តជំនាន់នុ៎ង ។ ខុសត្រូវយ៉ាងម៉េចអានេះវាជារឿងមួយផ្សេងទៀត ។ ក៏ប៉ុន្តែ ទស្សនៈរបស់ជនកុម្មុយនីស្តជំនាន់នុ៎ងវាអាចអ៊ីចឹងនេះសូមជម្រាបជូន លោកព្រះរាជអាជ្ញាអ៊ីចេះ ។

[០៩:១២:១៨]

**ស៖** តើលោកចង់ឲ្យកូនរបស់លោក ដែលកើតនៅស-២១ តើចង់ឲ្យគេក្លាយជាផ្នែកនៃចលនាបដិវត្តន៍ដែរឬទេ? តើមែនឬមិនមែន?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! អ្នកណាក៏ចង់ឲ្យកូនមានអនាគតរុងរឿង ។ ដូច្នេះ ជនបដិវត្តន៍ចង់ឲ្យកូនស្រឡាញ់បដិវត្តន៍ ធ្វើបដិវត្តន៍។ នេះជារឿងមួយ ។ ឯចំណែកបដិវត្តន៍ យើងយល់ឃើញយ៉ាងម៉េចចំពោះបដិវត្តន៍ពេលនោះ វាជារឿងមួយផ្សេងទៀត ។

**ស៖** ដូច្នេះ លោកចង់ឲ្យកូនរបស់លោកដែលកើតនៅពេលលោកធ្វើការជាប្រធានស-២១ ឲ្យជាផ្នែក ឬក៏ឲ្យចូលជាចលនាបដិវត្តន៍ តើត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ស-២១ វាជាផ្នែកមួយនៃការងារបដិវត្តន៍ ដូច្នេះ កូនមិនមែនសំដៅឲ្យវាទៅធ្វើប៉ូលិសដូចឪវាទេ ។ ក៏ប៉ុន្តែ ក្នុងជួរបដិវត្តន៍ៗ ។

**ស៖** សូមអរគុណ ។ លោកបានរៀបការនៅក្នុងឆ្នាំ-- បានជួបនៅឆ្នាំ១៩៧៤ ប៉ុន្តែបានរៀបការនៅខែធ្នូ ១៩៧៥ ហើយមានកូនស្រីទីមួយ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៧ ហើយកូនប្រុសទីមួយនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៨ ។ ដូច្នេះ នៅក្នុងកំឡុងពេលនុ៎ង លោកពិតជាបានជឿជាក់ថា ទិដ្ឋភាព ឬគោលការណ៍នៃបដិវត្តន៍ ហើយប៉ុន្តែលោកប្រហែលជាមិនឯករាជ្យ-- ឯកភាពថា របៀបដែលការងារ ដែលធ្វើនោះ ប៉ុន្តែលោកជឿនៅលើបដិវត្តន៍ថា អ្វីដែលលោកធ្វើនៅស-២១ គឺជាមធ្យោបាយមួយដើម្បីបញ្ចប់មួយ ។ គឺជាមធ្យោបាយដែលលោកហើយនិងអ្នកផ្សេងទៀត អាចសម្រេចដល់គោលដៅបដិវត្តន៍កុម្មុយនីស្ត ដើម្បីឈានដល់សង្គមមួយល្អដូចដែលលោកបានធ្វើផែនការ ឬគ្រោង តើត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បញ្ហានេះខ្ញុំបានលើកច្រើនលើកហើយ បើនិយាយតាមទ្រឹស្តីបដិច្ចសមុប្បាតសម្ភារៈ គេហៅថាឯកភាពមុខផ្ទុយ ។ ខ្ញុំតក់ស្លុតនឹងការងារនគរបាលដែលសម្លាប់មនុស្ស ។ ក៏ប៉ុន្តែ ខ្ញុំនៅក្នុងចង្កោមរបស់បក្ខជន ដែលត្រូវតែគោរពវិន័យ ចេញទៅណាមិនរួច កន្លងមកខ្ញុំធ្លាប់ហៅថា ខ្ញុំជាចំណាប់ថ្នូរនៃរបប ក៏ប៉ុន្តែជាអ្នកសម្តែងតួនៅក្នុងឧក្រិដ្ឋកម្ម ។

ថ្មីៗនេះអ្នកជំនាញ វ៉ាអ៊ីល ម៉ាកចេណា លោកមានប្រសាសន៍ថា កុំនិយាយអ៊ីចឹង ត្រូវនិយាយថាខ្ញុំជាអ្នកបម្រើរបប ហើយជាប់ចំណាប់ថ្នូរនៅក្នុងរបប ។ ហើយដែលអ្នកស្រី ស៊ីរ៉ូនី គាត់ថា ស៊ីសស្តែម ឌឹ រូអាហ្ស ។ ប្រព័ន្ធខ្មៅស្ពឺនៅក្នុងម៉ាស៊ីន ។ ដូច្នេះ ទិដ្ឋភាពមុខផ្ទុយបែបនេះវាៗស្ថិតនៅ ។ ខ្ញុំចង់ឲ្យកូនធ្វើបដិវត្តន៍ក៏ពិតមែន កាលដែលធ្វើឧក្រិដ្ឋទៅលើប្រជាជនក៏ខ្ញុំយល់ពិតមែន។ ក៏ប៉ុន្តែ គេចទៅណាវាអត់រួចទេ ។ ដូច្នេះ ខ្ញុំមិនមែនភ្នែកទិព្វ ទៅឃើញថាបក្សកុម្មុយនីស្តកម្ពុជាចាញ់ទេ ។ ហ៊ាស!

ហ្នឹងសូមបញ្ជាក់ជូនប៉ុណ្ណឹង ។

**ស៖** ដូច្នេះ តើត្រូវដែរឬទេ យើងនិយាយថា លោកជឿលើអ្វីដែលលោកធ្វើ លោកជឿលើបដិវត្តន៍? ប៉ុន្តែលោកមិនចូលចិត្តគំនិតនៃការកាប់សម្លាប់ហើយនិងទារុណកម្ម? តើយើងអាចនិយាយអ៊ីចឹងត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍! បញ្ហានេះអត់ដាច់គ្នាបានទេ ពាក់ព័ន្ធគ្នាៗ ។ មុនឆ្នាំ១៩៧១ ដែលខ្ញុំទទួលភារកិច្ចជានគរបាល ខ្ញុំជឿទាំងស្រុងថា បដិវត្តន៍ឈ្នះ ។ ជឿទាំងស្រុង ។ ដល់ក្រោយមកឃើញការកាប់សម្លាប់ មានការចាប់អារម្មណ៍មន្ទិលសង្ស័យបន្តិចម្តងៗ ។ លោកជឿចុះ លោកសង្កេតមើលចុះ នៅលើលោកនេះ គ្មានអ្វីដែលឈោតផ្តោះទេ វាតែងតែទៅសន្សឹមៗអ៊ីចឹងៗ។ អ៊ីចឹងចាប់អារម្មណ៍សង្ស័យលើបដិវត្តន៍នេះ វាទៅបណ្តើរៗអ៊ីចឹងដែរ នេះសូមជម្រាបលោកដោយស្មោះអ៊ីចឹង ។

**ស៖** ហេតុអ្វីបានជាយកកូនរបស់លោកចូលទៅក្នុងពិភពដែលថា វានឹងមានបទឧក្រិដ្ឋនឹងត្រូវកើតឡើង? ហេតុអ្វីបានជាលោកជឿថា វាអាចថ្ងៃណាមួយគេនឹងឆ្លើយដាក់លោកនៅក្នុងរបបហ្នឹង? ហើយប្រសិនបើគេឆ្លើយដាក់លោក ហើយក្រុមគ្រួសាររបស់លោកនឹងត្រូវគេឆ្លើយដាក់ ថាហេតុអ្វីបានជាលោកនាំកូន ក្រុមគ្រួសារចូលទៅក្នុងពិភពកុម្មុយនីស្តបែបនេះ ដែលថាប្រឈមមុខនឹងគ្រោះថ្នាក់បែបនេះហើយ នៅតែធ្វើនោះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន សូមអភ័យទោស ខ្ញុំនេះជា-- សំណួរដែលហួសពីព្រំដែន គឺជា-- ហួសពីលក្ខណៈទីបំផុត គឺថាអាចមិនគប្បីសួរនៅទីនេះទេ ។ បើយើងសួរថាតែហេតុអ្វីបាន-- សូមអភ័យទោសដែលខ្ញុំប្រើការកាត់នេះ ។ ដូចជាការបំពានទៅលើសិទ្ធិបុគ្គលផ្ទាល់ខ្លួន ហើយសូមការអនុញ្ញាតសហព្រះរាជអាជ្ញាកែសម្រួលពាក្យហ្នឹងឲ្យបានល្អជាងនេះ ។ សូមអរគុណ ។

**លោក វីលៀម ស្មីត៖**

ខ្ញុំមិនច្បាស់ថា ខ្ញុំជំទាស់ទៅលើ យល់ច្បាស់ពីការជំទាស់នោះទេ ប៉ុន្តែខ្ញុំនឹងសួរចំណុចមួយផ្សេងមួយ ។

**សួរដោយលោក វីលៀម ស្មីត៖**

**ស៖** តើនៅ ស-២១ លោកមានសុវត្ថិភាពទេ សុវត្ថិភាពផ្ទាល់ខ្លួន ដែលថាលោកមិនត្រូវបានគេផ្តើយដាក់? បើមិនដូច្នោះទេ លោកមិនអាចនឹងឲ្យមានកុមារជាកូននោះទេ តើត្រឹមត្រូវដែរឬទេ?

[០៩:២០:00]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បើនិយាយថា រឿងគេផ្តើយដាក់ ឬមិនផ្តើយដាក់ អាហ្នឹងវាចូលក្នុងពាក្យសន្និដ្ឋានទៅហើយ ។ អ្នកណាទៅសន្និដ្ឋានសភាពការណ៍ត្រូវពីរឿងថាខ្ញុំរស់នៅទីនេះមិនមានគេផ្តើយដាក់? អត់សន្និដ្ឋានត្រូវទេ ។ ក៏ប៉ុន្តែ ជាក់ស្តែងជីវិតខ្ញុំ នៅក្នុងចុងសក់ទេ ព្រលឹងខ្ញុំនៅក្នុងចុងសក់ទេពេលនោះ ។ ព្រោះអី? ប្អូនថ្លៃគេចាប់មកមួយ គេបញ្ជូនមកឲ្យនៅជាមួយខ្ញុំមួយ ។ មេដឹកនាំខ្ញុំគឺ វន វ៉េត ក៏គេចាប់មក ។ កុយ ធួន ដែលខ្ញុំធ្លាប់ជិតស្និទ្ធក៏គេចាប់មក ហើយកម្មាភិបាលភូមិភាគឧត្តរ ដែលខ្ញុំធ្លាប់ជិតស្និទ្ធក៏គេចាប់មក ។ ថ្ងៃណាគេត្រូវផ្តើយដាក់ខ្ញុំ ខ្ញុំអត់ប៉ានសន្និដ្ឋានទេ ។ ថ្ងៃណាគេចាប់ខ្ញុំ ខ្ញុំអត់ប៉ានសន្និដ្ឋានទេ ។ សំខាន់ពេលដែលមានខ្នាំងផ្តើយដាក់លោកគ្រូ សុន សេន មិនមែនគ្រាន់តែផ្តើយដាក់ទេ កូនចៅគាត់មួយចំនួនត្រូវគេចាប់មកចូលស-២១ តើគាត់គិតទេ? ប្រពន្ធខ្ញុំគាត់បណ្តេញឲ្យចេញពីពេទ្យមកទុកនៅជាមួយខ្ញុំ ។ ដូច្នេះបញ្ហាជីវិតខ្ញុំ ខ្ញុំមិនដឹងជាថ្ងៃណារស់ ថ្ងៃណាស្លាប់ទេ ។ ក៏ប៉ុន្តែ ការចង់បានកូន វាត្រូវតែចង់បាន បើសិនជាមិនស្លាប់ វារស់ វាមានកូនតពូជនឹងគេ ។ បើសិនជាមិនស្លាប់អ៊ីចឹង វារស់ វាមានកូនតពូជនឹងគេ ។ បើសិនវាងាប់ មិនដឹងធ្វើម៉េច វាទៅទាំងអស់ហើយ ទាំងម៉ែខ្ញុំ និងជីដូនមួយទៀត នេះជម្រាបលោកព្រះរាជអាជ្ញាដោយត្រង់ ។ មិនមែនត្រឹមតែខ្ញុំហើយនិងកូនខ្ញុំ ហើយនិប្រពន្ធខ្ញុំទេ ទាំងម្តាយខ្ញុំ ឪពុកខ្ញុំ ហើយនិងជីដូនខ្ញុំមួយទៀត ។

**ស៖** លោកបាននិយាយថា លោកបានជាប់អន្ទាក់នៅក្នុងរបបខ្មែរក្រហម ។ អ៊ីចឹង សូមលោកនិយាយឲ្យច្បាស់ នៅចុងបំផុត គឺថាម្នាក់ៗនៅទីបំផុតហ្នឹងជាប់អន្ទាក់ គឺថា វន វ៉េត, សុន សេន ក៏ត្រូវបានគេផ្តើយដាក់ ហើយម្នាក់ៗនៅក្នុងរបបនោះ រួមទាំង ប៉ុល ពត ផង ក៏ជាមនុស្សដែលអាចគេផ្តើយដាក់បានដែរ ហើយក៏អាចគេយកទៅស-២១ ដែរ តើលោកឯកភាពនឹងគំនិតហ្នឹងដែរឬទេ?

**ឆ៖** មនុស្សដែលគេមិនផ្តើយដាក់ ហើយគេទុកជាសក្ការៈ មានពីរ គឺប៉ុល ពត និង នួន ជា ក្រៅពីនោះ បុគ្គលទីបី សោ ភឹម គេផ្តើយដាក់ ហើយគ្នាស្លាប់ទៅបាត់ទៅហើយ។ បុគ្គលទីបួន តាម៉ុក មានគេផ្តើយដាក់ដែរ ក៏ប៉ុន្តែគ្មានអាណាទៅប៉ានពាល់រោមជើង តាម៉ុក ទេ ។ បុគ្គលទីប្រាំ អៀង សារី អត់មានអ្នកណាគេផ្តើយដាក់ទេ ។ បុគ្គលទីប្រាំមួយមានគេផ្តើយហើយ គ្នាមកទៅបាត់ហើយ ស្លាប់នៅ

ស-២១ ស្លាប់ទៅហើយ ។ បុគ្គលទីប្រាំពីរ សុន សេន ក៏គេឆ្លើយដាក់ច្រើនដែរ ។ ឯចំណែក ខៀវ សំផន ប្រហែលជាបុគ្គលទីប្រាំបី អត់មានអ្នកណាឆ្លើយដាក់ទេ ។ នេះរឿងគេឆ្លើយដាក់ បើតាមខ្ញុំចាំរំឭកឡើងវិញប៉ុណ្ណឹង ។

ដូច្នេះខ្ញុំបាទខ្លួនឯង មិនដឹងជាអ្នកណាឆ្លើយនៅឯខាងភូមិភាគណាទៀត ខ្ញុំអត់ដឹងទេ ។

[០៩:២៣:៥៤]

**ស៖** សូមអរគុណ ។ ប្រហែលជាយើងអាចបន្តទៅនឹងចំណុចមួយចំនួនដែលថាដាក់តាំងនៅស-២១ ហើយតើការងារដែលលោកទទួលនោះ តើលោកទទួល ហើយមោទនភាពដែលការងារធ្វើនៅស-២១ លោកទទួលស្គាល់ដែរឬទេ? តើលោកឯកភាពទេអំពីតួនាទីបណ្តុះបណ្តាល ហើយនិងអប់រំនៅស-២១ ជាតួនាទីចម្បង ដែលលោកធ្លាប់មានក្នុងអាជីពរបស់លោក គឺជាតំណែងដ៏មានតម្លៃរបស់លោកពីព្រោះវាមានកម្រិតល្អចំពោះការបង្រៀន ហើយនិងការអប់រំអំពី មិនត្រឹមតែគណិតវិទ្យាទេដែលជំនាញរបស់លោក គឺថាជាមនោគមវិជ្ជាដែលប្តូរជីវិតមនុស្ស អាកប្បកិរិយារបស់មនុស្ស ដើម្បីឱ្យគេធ្វើអ្វីមួយ។ តាមពិតលោកទទួលបន្ទុកនូវការងារជាអ្នកសួរចម្លើយថ្នាក់មជ្ឈិមនៅស-២១ ហើយដែលធ្វើឱ្យលោកមានអារម្មណ៍ល្អ មានមោទនភាព ហើយជាឱកាសដ៏ធំមួយសម្រាប់លោក ដែលថាជាមនុស្សដែលប្រកបដោយមហិច្ឆតា? តើលោកឯកភាពជាមួយខ្ញុំទេ នៅពេលដែលលោកទទួលការងារដំបូងនៅស-២១ នោះ លោកមានមោទនភាពអំពីការងារនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំជម្រាបដោយត្រង់ ការទទួលការងារនៅស-២១ ហ្នឹងមិនមែនទទួលដោយមោទនភាពទេ ។ ទីមួយ ភស្តុតាងបញ្ជាក់ ខ្ញុំចូលទៅនៅនុំងក្នុងឋានៈជាអនុប្រធានរបស់គេ នៅក្នុងខែបីឆ្នាំ១៩៧៦ បក្សដក ណាត ចេញពីប្រធាន ដាក់ឱ្យខ្ញុំឡើងជាប្រធាន ។ ពេលនោះខ្ញុំតវ៉ាជាមួយនឹងបក្ស សុំឱ្យយក ឆាយ គឹមហ៊ កមកដាក់ធ្វើប្រធានវិញ ។ មេកំហែង ។ ដូច្នេះបញ្ជាក់ហើយថា ឃើញថាខ្ញុំគ្មានមោទនភាពទេ ។

ឥឡូវ ឯកសារដែលនៅសល់ សូមព្រះរាជអាជ្ញាលោកវិភាគឯកសារនោះទៅចុះ ឯកសារប៉ុន្មានលើកក្រោយនេះ គឺឯកសារលេខ E5/2 តាំងពីចុច ១ រហូតដល់ទៅដល់ចុច ៨ ស្ថិតនៅក្នុងរយៈកាលណាត ។ តើ ណាត គេបញ្ជាឱ្យខ្ញុំសរសេរយ៉ាងម៉េចនៅខាងចុង ហើយតាំងពីចិត-- ឯកសារបន្តទៅទៀត ខ្ញុំសរសេរយ៉ាងម៉េច? នោះលោកព្រះរាជអាជ្ញាលោកសង្កេតឃើញហើយ ខ្ញុំអត់មានមោទនភាពនឹងការងារនេះ ស-២១ នេះទេ ។ ក៏ប៉ុន្តែបើនិយាយអំពីការអប់រំ ខ្ញុំ--

[០៩:២៧:០៧]

**សៈ** ប្រហែលជាខ្ញុំសូមជូនជាឧទាហរណ៍ជាក់លាក់ដល់លោក ហើយលោកអាចរង់ចាំដល់ពេលនោះ ដើម្បីពន្យល់ ដែលលោកពេញចិត្ត ឬក៏មានមោទនភាពអំពីការបណ្តុះបណ្តាលអំពីការអប់រំ ប្រហែលជាមិនមែនពាក្យថា មោទនភាពនោះទេ គឺថាគ្រាន់តែប្រើពាក្យថា លោកមានអារម្មណ៍ថា លោកពេញចិត្តនឹងការងារ ពីព្រោះលោកមានអារម្មណ៍ពេលនោះថាលោកពូកែជាងអ្នកដទៃជាអ្នកសួរចម្លើយពូកែជាងគេ ជាអ្នកអប់រំល្អជាងគេ។ ដូច្នោះហើយលោកគិតថា មុខតំណែងនោះគឺថាវាស័ក្តិសមសម្រាប់លោក ជាងអ្នកដទៃ ។ តើលោកពេញចិត្តនឹងការងារតំណែងនោះដែរឬទេ?

**ឆៈ** ខ្ញុំជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! និយាយថាពេញចិត្ត មិនត្រូវទេ ។ បើនិយាយថាខ្ញុំមានសមត្ថភាពនឹងបំពេញចិត្តខាងលើ វាត្រូវជាង ។ ខាងទ្រឹស្តី ណាត គាត់ធ្វើមេខ្ញុំក៏ពិតមែន ក៏ប៉ុន្តែទ្រឹស្តី ណាត ចាញ់ខ្ញុំទេ ។ ខាងការអប់រំបណ្តុះបណ្តាល ក៏ ណាត គ្មានសមត្ថភាពដល់ខ្ញុំដែរ ។ ដូច្នេះ ខ្ញុំមានសមត្ថភាពនឹងបំពេញចិត្តគេ ។

**សៈ** ហើយហេតុការណ៍ដែលថាលោកមានសមត្ថភាពដើម្បីបំពេញចិត្តគេនោះ គឺបំពេញចិត្តមេដឹកនាំ ឬថ្នាក់លើ ធ្វើឲ្យលោកសប្បាយចិត្ត ដោយសារថាលោកមានមហិច្ឆតា មានគោលបំណងមួយ ហើយលោកបានធ្វើការជាមួយមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងប្រទេស ។ ការងារនោះហើយដែលធ្វើឲ្យលោកមានការសប្បាយចិត្ត ឬក៏អារម្មណ៍ល្អ ។ តើអ៊ីចឹងដែរទេ?

**ឆៈ** បើលោកពិនិត្យមើលបញ្ហានេះ វាហាក់ដូចសេចក្តីសន្និដ្ឋានរបស់លោកត្រឹមត្រូវទាំងស្រុងមួយរយភាគរយ ។ ក៏ប៉ុន្តែសូមលោកពិនិត្យមើលការងារសព្វជ្រុង ។ សូមលោកជ្រាបថា ខ្ញុំបាទហើយនិងមេខ្ញុំ ទាក់ទងគ្នាតាមទូរស័ព្ទរាល់ល្ងាច គាត់តាមដានការងារខ្ញុំ គាត់ជំរុញខ្ញុំ ។ ឥឡូវ បើគេស្គាល់ការងារលម្អិតហើយ គេជំរុញហើយ តើយើងចៀសអីពីត្រូវធ្វើ? ត្រូវតែធ្វើឲ្យគេ ។ ដូច្នេះ សូមលោកមេត្តាថ្លឹងថ្លែងឲ្យគ្រប់ជ្រុង ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

**សៈ** យើងយល់ថា លោកហើយនិងអ្នកផ្សេងៗទៀតនៅក្នុងរបបខ្មែរក្រហមនោះ ធ្វើការនៅក្នុងប្រព័ន្ធក្រោមបញ្ជាតាមថ្នាក់លើ ប៉ុន្តែថាតើគេចង់ធ្វើ ឬមិនចង់ធ្វើ ថាតើអនុវត្តបញ្ជា ឬក៏មិនអនុវត្តបញ្ជា តើគេអាចបដិសេធបញ្ជាហ្នឹងបានដែរឬទេ? ប៉ុន្តែ-- ហើយខ្ញុំសូមដកស្រង់សម្តីមួយ ដែលចៅក្រមខាតវ៉ាយថ៍ សួរសំណួរទៅលោកនៅក្នុងសក្ខីកម្មថ្ងៃណាមួយ ហើយលោកដកស្រង់ពីសៀវភៅ ដេវីដ ឆេនដ័ល័រ ហើយលោកនិយាយថា សង្ខេបសៀវភៅនេះ "លោកចង់ធ្វើឲ្យការងាររបស់លោកនៅស-២១

នោះឱ្យពូកែ ហើយធ្វើជាការងារដ៏ល្អបំផុត ហើយចង់ឱ្យការងារហ្នឹងល្អបំផុតនៅក្នុងអាជីពរបស់លោក តាំងពីលោកនៅជានិស្សិត ជាគ្រូ ហើយលោកចង់បម្រើថ្នាក់លើដោយការពេញចិត្តដោយជំនាញ ហើយលោកចង់ឱ្យមានមោទនភាពអំពីការងាររបស់លោក ។ តើជាការវាយតម្លៃអំពីអត្តចរិតរបស់លោកដែរឬទេ?” ពេលនោះលោកឆ្លើយថា “លោកចៅក្រមជាទីគោរព! និយាយអំពីការចង់ថា ឱ្យក្លាយទៅជាតួនាទីនោះតាមពិតគឺអ៊ីចឹងមែន ។ ប៉ុន្តែ ខ្ញុំមិនចង់បញ្ជាក់ពីមូលហេតុអំពីការចង់ក្លាយទៅជាមនុស្សបែបនោះនៅពេលនេះទេ” ។ អ៊ីចឹងយើងចាំហើយថា អ្វីដែលលោកបាននិយាយពីខាងដើមនោះ តើវាជាករណីត្រូវដែរឬទេនៅពេលដែលលោកចាប់ផ្តើមធ្វើការនៅស-២១ ដំបូង? ដូចដែលលោកបានជម្រាបលោកចៅក្រម ខាតវ៉ាយថ៍ នោះលោកបានចង់ធ្វើតួនាទីហ្នឹង គឺថាអ្វីៗអាចកែប្រែនៅពេលក្រោយមកនៅក្នុងឆ្នាំ១៩៧៨ នៅពេលដែលមេរបស់លោក ហើយនិងកម្មាភិបាលដែលលោកស្គាល់ត្រូវបានចាប់ខ្លួន ។

ប៉ុន្តែនៅពេលចាប់ផ្តើមដំបូងនោះ ដូចដែលលោកបាននិយាយ លោកបានចង់ទទួលតំណែងហ្នឹងតួនាទីហ្នឹង ។ តើលោកអាចពន្យល់ពីមូលហេតុបានទេ អំពីការចង់បានតួនាទីនេះនោះ?

[០៩:៣១:៤៥]

**ឆ៖** សូមជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! សំណួររបស់លោកធ្វើឱ្យខ្ញុំពិបាកឆ្លើយ ព្រោះយើងឆ្លងកាត់ការបកប្រែភាសាពីរបីជាន់ទៅហើយ ពីខ្មែរនៅក្នុងប្រតិចារឹកទៅជាអង់គ្លេស ។ រួចឥឡូវលោកមានប្រសាសន៍ជាអង់គ្លេស ដឹងជាត្រឹមត្រូវប៉ុន្មានតាមប្រតិចារឹកអង់គ្លេស ហើយគេបកប្រែមកឱ្យខ្ញុំស្តាប់ជាខ្មែរ ដូច្នេះខ្ញុំពិបាកជម្រាបណាស់ ពិបាកឆ្លើយណាស់ ។ យកល្អគួរយកប្រតិចារឹករបស់ខ្ញុំដែលខ្ញុំឆ្លើយជម្រាបលោកជំទាវ ខាតវ៉ាយថ៍ មកដាក់ទាំងអស់គ្នា ហើយដេញដោល ។ ខ្ញុំសូមបញ្ជាក់បញ្ហានេះប៉ុណ្ណោះ ។

**ស៖** ខ្ញុំមិនដឹងថាតើវាមានបញ្ហាបកប្រែ ឬយ៉ាងម៉េចនោះទេ? យើងអាចពិភាក្សាទៅលើចំណុចនេះ នៅក្នុងរបៀបផ្សេងវិញ ។ ចៅក្រម ខាតវ៉ាយថ៍ គាត់បានសួរទៅកាន់លោកអំពីចំណុចយោងមួយទៀត ដែលគាត់និយាយថា “លោកជាអ្នកមានប្រាជ្ញា ហើយលោកប្រឹងប្រែងធ្វើការងារ ហើយលោកចូលចិត្តបំពេញចិត្តមេរបស់លោក ហើយលោកចង់ឱ្យមានជំនាញ និងពូកែគ្រប់ការងារទាំងអស់ ។ លោកប្រុងប្រយ័ត្ននឹងការងាររបស់លោក ហើយលោកពិនិត្យពិច័យទៅលើបញ្ហាពិស្តារ ហើយលោកមានមោទនភាពទៅលើការងារដែលលោកបានធ្វើ។ ថាតើចំណុចទាំងអស់នេះ គឺជាការសន្និដ្ឋានសង្ខេប

ត្រឹមត្រូវដែរឬទេ?" លោកបានឆ្លើយថា "ខ្ញុំមិនជំទាស់ទៅនឹងការលើកឡើងសន្និដ្ឋាននោះទេ" ។ ថាតើទិដ្ឋភាពការងារអ្វីខ្លះនៅ ស-២១ ដែលធ្វើឱ្យលោកមានមោទនភាព?

[០៩:៣៣:៤១]

**ឆ៖** បញ្ហាពាក្យមោទនភាពនេះ យើងជជែកគ្នាមួយសារួចទៅហើយ លោកក៏បានបោះចោលថាមិនប្រើពាក្យនេះ ។ យើងទាំងអស់គ្នាធ្លាក់មកប្រើពាក្យមួយថា ខ្ញុំខំធ្វើការដើម្បីឱ្យមេពេញចិត្ត នេះយើងបានឯកភាពគ្នាថាប្រើពាក្យនេះរួចទៅហើយ ។ ដូច្នេះ ខ្ញុំសូមសរុបឡើងវិញ សមត្ថភាពរបស់ខ្ញុំទៅខាងកាប់ចាក់ វ៉ៃដំ ទាត់ធាក់ ខ្ញុំមិនមានសមត្ថភាពទេ ។ ក៏ប៉ុន្តែបើសមត្ថភាពបង្រៀនគេ បំពាក់ទ្រឹស្តីឱ្យគេ សមត្ថភាពយល់ដឹងខាងទ្រឹស្តី ខ្ញុំពិតជាមាន ។ ខ្ញុំត្រូវតែធ្វើ ម្យ៉ាងដើម្បីឱ្យមេពេញចិត្ត កាលណាបើមេពេញចិត្តហើយ វានឹងបានរស់ អត់ប្រាថ្នាទាន់ចង់បានបុណ្យស័ក្តិឡើងមជ្ឈិមទេ ។ សូមបញ្ជាក់ថាខ្ញុំអត់ទាន់បានចូលថ្នាក់មជ្ឈិមទេ ។ ដូច្នេះ វាមិនមែនជាមោទនភាពទេ គឺជាការខំធ្វើការដើម្បីឱ្យមេពេញចិត្តនឹងបានរស់ឃើញពន្លឺព្រះអាទិត្យនឹងគេ ។ នេះខ្ញុំសូមបញ្ជាក់អញ្ចេះទៅវិញទៅចុះ ។

**ស៖** ពាក្យ"មោទនភាព" គឺពាក្យដែលលោកបានប្រើនៅក្នុងសវនការនេះ ។ លោកបាននិយាយថា លោកមានមោទនភាពនៅពេលដែលលោកបានរកឃើញសាលាទួលស្លែង ហើយលោកបាននិយាយថា លោកហាក់ដូចជាមានមោទនភាពនៅពេលដែលលោកបាននិយាយតាមរយៈមីក្រូហ្វូន នៅក្នុងវគ្គអប់រំទៅលើកម្មាភិបាលរបស់លោក ហើយលោកក៏បានលើឡើងផងដែរ នៅពេលដែលលោកបានជួបប៉ុល ពត នៅចុងឆមាសទីពីរឆ្នាំ៧៨ គឺលោកក៏បានលើកឡើងថា លោកមានអារម្មណ៍ល្អ ។ ហើយខ្ញុំដកស្រង់នូវអ្វីលោកជម្រាបអង្គជំនុំជម្រះនេះថា លោកបានលើកឡើងកាលពីមុន ដែលជាសំណួររបស់ខ្ញុំសួរនៅពេលនោះ ។ លោកបានលើកឡើងថា "កម្មាភិបាលបក្ស មានការច្រណែនប្រសិនបើកម្មាភិបាលម្នាក់ជួប ប៉ុល ពត" ។ ថាតើលោកមានមោទនភាពបុព្វសិទ្ធដែរឬទេ នៅពេលដែលមាន ប៉ុល ពត នៅក្នុងកិច្ចប្រជុំ ហើយជួប ប៉ុល ពត នោះ? ហើយលោកបានឆ្លើយថា "ខ្ញុំសូមនិយាយដោយស្មោះត្រង់ថា នៅពេលនោះ ខ្ញុំមានអារម្មណ៍ចម្លែកមួយ នៅពេលដេលខ្ញុំរៀនជាមួយនិងកម្មាភិបាលប្រាំពីរនាក់នៅទីនោះ ហើយខ្ញុំបានជួបបងទីមួយ នៅក្នុងបក្សលើកទីមួយនៅពេលនោះ ។ ហើយនៅពេលនោះ ខ្ញុំមានអារម្មណ៍ចម្លែកណាស់ ហើយវាពិបាកក្នុងការរៀបរាប់នូវអារម្មណ៍របស់ខ្ញុំនៅពេលនោះ" ។ ហើយខ្ញុំបានសួរលោក ថាតើលោកមានអារម្មណ៍ល្អដែរឬទេ នៅពេលដែលមានវត្តរបស់បងទីមួយនោះ? ហើយលោកបានឆ្លើយថា "អារម្មណ៍ចម្លែកនោះ មានន័យថា ដូចដែលលោកបានជម្រាបហើយ គឺអារម្មណ៍

ល្អតែម្ដង នៅពេលដែលខ្ញុំឃើញគាត់” ។

ដូច្នេះ ខ្ញុំចង់សួរលោកថា ហេតុអ្វីបានជាលោកមានអារម្មណ៍ល្អ នៅឆមាសទីពីរឆ្នាំ៧៨? នៅពេលដែលលោកបានប្រាប់តុលាការថា “លោកបានគិតថារបបនោះ កំពុងតែស្ថិតនៅក្នុងស្ថានភាពគ្រប់គ្រងលែងបានហើយ ហើយលោកមិនពេញចិត្តទៅនឹងរបបនោះ ហើយលោកស្អប់ទៅនឹងការងារ ហើយលោកភ័យខ្លាចនឹងការស្លាប់នូវជីវិតរបស់លោក” ។ តើពេលនោះ តើលោកមានអារម្មណ៍ល្អយ៉ាងម៉េច នៅពេលដែលលោកជួបបុគ្គលទីមួយ? ដែលលោកគិតថា វាមានអ្វីអាចកើតឡើងចំពោះករណីទាំងអស់នោះ ។ តើលោកអាចពន្យល់អំពីអារម្មណ៍ល្អរបស់លោកនៅពេលនោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! សំណួរលោកវែង ក៏ប៉ុន្តែសរុបមក បើតាមខ្ញុំស្ដាប់ដូចនៅត្រឹមតែថ្ងៃដែលខ្ញុំចូលទៅរៀនសូត្រជាមួយនឹង ប៉ុល ពត ។ ប៉ុល ពត ឧទ្ទេសនាម ។ រាល់ឆ្នាំខ្ញុំអត់ដែលបានរៀនជាមួយ ប៉ុល ពត ទេ ខ្ញុំរៀនជាមួយ សុន សេន ។ ទើបឆ្នាំនុ៎ងទេ ដែលកងទ័ពគេទៅមុខអស់ទៅ ភ្នំពេញអត់មានកងទ័ព សុន សេន គាត់អត់បើកវគ្គនៅភ្នំពេញទេ ខ្ញុំអត់បានទៅនឹងគេ ខ្ញុំរៀនជាមួយនឹងពួកផ្សេងទៀត ដោយមាន ប៉ុល ពត ជាអ្នកបង្រៀន ។ សរុបមកនៅពេលហ្នឹង ខ្ញុំអត់ទៅរៀនមនុស្សតែប្រាំពីរនាក់ទេ ខ្ញុំទៅរៀនមនុស្សរាប់រយ ។ ប៉ុល ពត គាត់ជាអ្នកឧទ្ទេសនាម នួន ជា គាត់នៅក្បែរជាមួយ ប៉ុល ពត នុ៎ង អែបគ្នានៅហ្នឹង មនុស្សរាប់រយ ។

រឿងដែលធ្វើឲ្យខ្ញុំរំភើប ពិតជាមាន ។ ទីមួយ គឺខ្ញុំបានទៅរៀនជាមួយនឹងបុគ្គលទីមួយ មិនមែនបុគ្គលទីប្រាំពីរ ក៏ប៉ុន្តែរឿងដែលរំភើបមែនទែនវាមានចំណុចមួយ ប៉ុល ពត គាត់ហាមមិនឲ្យសួរចម្លើយ គាត់និយាយច្បាស់មិនឲ្យសួរចម្លើយ ឈប់សួរចម្លើយ ។ គាត់និយាយទៀតថា ពាក្យដែលហៅថា “ចោរព្រៃ” គ្មានស្អីទេ គឺគ្នាដែលអត់បាយស៊ីហើយទៅដេកក្នុងព្រៃ ឲ្យបាយស៊ីទៅវាលែងមានចោរព្រៃហើយ ។ ដូច្នេះ អាត្រង់ហ្នឹងដែលខ្ញុំសប្បាយចិត្ត ព្រោះសារាចរ វាមានមួយម្ដងរួចមកហើយ អ្នកណាចូល សេអ៊ីអា ពីឆ្នាំណាអីណា ចូល សេអ៊ីអា ពីឆ្នាំណាស្អី ខ្ញុំមានការរីករាយមែន ។ ដល់ចេញមកខ្ញុំអត់សួរ ធ្វើស្អីខ្ញុំ មាគ៌ាបក្សអ៊ីចឹង ។ ដល់ថ្ងៃមួយ ពូនួន គាត់ហៅខ្ញុំទៅធ្វើការ ដល់ហៅទៅធ្វើការ ខ្ញុំថាខ្ញុំអត់មានបានសួរស្អីខ្ញុំទេ ។ នួន ជា គាត់ស្ទុកមកឲ្យខ្ញុំវិញថា “អ្ហ៎! មិត្ត ឌុច ឥឡូវ គេចេះមាគ៌ាសម្បើមណាស់ អ្ហ៎!” គាត់បង្ខំឲ្យខ្ញុំសួរបន្តទៅទៀត ។ ដូច្នេះ ពេលនុ៎ងខ្ញុំសប្បាយចិត្តមែន ខ្ញុំស្មានគិតថា អាមាគ៌ាឈប់សួរចម្លើយ ឈប់ធ្វើទារុណកម្មអីហ្នឹងចប់ ជាមាគ៌ាពិត ។ នុ៎ង ដែលខ្ញុំសប្បាយចិត្តពិតប្រាកដរបស់ខ្ញុំ ។ ហ្នឹង សូមជម្រាបលោកព្រះរាជអាជ្ញាអ៊ីចឹង ។

[០៩:៤០:០៦]

**ស៖** នៅពេលនោះ លោកនៅតែជឿទៅលើបដិវត្តន៍កុម្មុយនីស្ត ហើយលោកនៅតែជឿថាបដិវត្តន៍នោះនឹងទទួលជោគជ័យ ហើយលោកមានសេចក្ដីរីករាយក្នុងការជួបជាមួយនឹងមេដឹកនាំទាំងអស់ក្នុងមូលហេតុដូចដែលលោកបានលើកឡើងអ៊ីចឹង តើត្រឹមត្រូវដែរឬទេ?

**ឆ៖** រឿងដែលទៅរៀន វាជារឿងមួយ ។ រឿងជួបមេដឹកនាំទាំងអស់ វាជារឿងមួយទៀត ។ ខ្ញុំសូមជម្រាបបញ្ជាក់ជូនលោកសហព្រះរាជអាជ្ញាថា ខ្ញុំមិនដែលជួបមេដឹកនាំណាទេ ក្រៅពី សុន សេន ហើយនិង នួន ជា ហើយជាមួយ ប៉ុល ពត ខ្ញុំបានទៅរៀនតែម្ដងនុ៎ងគត់ ។ ដូច្នេះ រឿងវាជាបញ្ហាផ្សេង រឿងជួបមេដឹកនាំទាំងអស់ ខ្ញុំអត់ដែលបានជួបៗទេ ។

**ស៖** នៅពេលដែលលោកជួប ប៉ុល ពត នៅចុងឆ្នាំ១៩៧៨ លោកនៅតែជឿទៅលើមនោគមកុម្មុយនីស្តដដែល តើត្រឹមត្រូវដែរឬទេ? ពិតមែនដែរឬទេ?

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា បញ្ហាជឿដូចខ្ញុំបាននិយាយអ៊ីចឹង ។ ការជឿនេះវាសន្សំមកយូរ ហើយពេលនុ៎ង ការដែលចាប់ផ្ដើមចាប់អារម្មណ៍មិនជឿ ក៏វាមានដែរ ។ នៅក្នុងខ្លួនខ្ញុំវាមានមួយផ្នែកជឿ ក៏ប៉ុន្តែចាប់អារម្មណ៍មន្ទិលសង្ស័យថាហាក់ដូចជាទៅមិនរួច នេះវាជារឿងពិត ។ ដល់ទៅគេបញ្ឈប់ថា អ៊ូ៎ៗ ឈប់ឱ្យសួរចម្លើយ ឈប់ឱ្យធ្វើទារុណកម្ម អ៎! គិតថា អ៎! អានេះគេងាកមករកផ្លូវត្រឹមត្រូវហើយ លោកគិតមើលផ្លូវបត់ណ៎ា បើសិនរឿងហ្នឹង គាត់និយាយពិតមែន កុំគាត់ភរ អាហ្នឹងវាជារឿងត្រឹមត្រូវ ក៏ប៉ុន្តែគាត់ភរ យើងស្រងាកចិត្ត ។ ដូច្នេះ រឿងជឿនិងមិនជឿ វាលិចអណ្ដែតទៅតាមសភាពការណ៍ដែលគេបញ្ជាមកយើង គេបង្រៀនយើង វាទៅអ៊ីចឹង ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានជាទីគោរព! ខ្ញុំសូមអភ័យទោសដែលខ្ញុំកាត់សាជាថ្មី ប៉ុន្តែខ្ញុំសូមៗឱ្យសហព្រះរាជអាជ្ញា ធ្វើការតាំងសំណួរជាជាងការធ្វើសម្មតិកម្ម គឺកុំឱ្យគាត់សួរថាពិត ឬក៏មិនពិត ។ សហព្រះរាជអាជ្ញាគួរតែនិយាយនិងសួរថា ជនជាប់ចោទមានជំនឿទៅលើបដិវត្តន៍ដែរឬទេ? កុំឱ្យគាត់សួរសំណួរបិទ ។ ហើយកុំឱ្យគាត់លើកជាយោបល់ ហើយឱ្យសូមសួរទៅកាន់ជនជាប់ចោទ ឱ្យទទួលស្គាល់ទៅលើគំនិតរបស់គាត់ ។ ដូច្នេះ ហើយសូមឱ្យលោកសហព្រះរាជអាជ្ញា ធ្វើការសួរសំណួរឱ្យបានជាក់

លាក់ កុំឲ្យសួរសំណួរលើកជាយោបល់ បន្ទាប់មកសួរសំណួរបិទ ។ ដូច្នេះហើយខ្ញុំសូមបញ្ជាក់ទៅលើចំណុចនេះ លោកប្រធាន ។

[០៩:៤៣:៣៤]

**លោក វីលៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបទៅលើការតាំងសំណួរនេះ ។ ជនជាប់ចោទគាត់មានជម្រើសក្នុងការយល់ព្រម ឬក៏មិនព្រម ។ ហើយសំណួររបស់ខ្ញុំនេះ គឺផ្អែកទៅលើភស្តុតាង និងចម្លើយនៅក្នុងសំណុំរឿង ដូចដែលខ្ញុំបានលើកឡើងហើយ ជនជាប់ចោទគាត់បានឆ្លើយយ៉ាងវែង។ ដូច្នេះហើយវាត្រឹមត្រូវដែលខ្ញុំសូមលើកឡើងថា សំណួរយ៉េស បាទ ពិត ឬក៏មិនពិត នេះគឺវាគ្រាន់តែជួយឲ្យយើងក្នុងការស្វែងយល់អំពីការពិតដែលបញ្ជាក់នៅក្នុងចម្លើយរបស់គាត់តែប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ជាការលំបាកមែននៅក្នុងដំណើរការប្រព្រឹត្តទៅនៃការសួរដេញដោលនេះ ដោយសារតែសំណួរហ្នឹងគឺវាវែង ។ ហើយនាំឲ្យមានបញ្ហាកើតឡើងនៃការជំទាស់របស់មេធាវីការពារ ហើយអាចទៅជាប្រភេទនៃសំណួរដឹកមុខផង ។ អ៊ីចឹង អង្គជំនុំជម្រះសូមឲ្យតំណាងសហព្រះរាជអាជ្ញា ធ្វើការកែសម្រួលនូវសំណួរ សូមឲ្យសួរនូវសំណួរងាយៗ ហើយនិងងាយឆ្លើយ ងាយសួរ និងស្តាប់ហើយបាន ហើយងាយឆ្លើយ ។ សុខចិត្តសួរច្រើនសំណួរចុះដើម្បីឲ្យលទ្ធផលហ្នឹងគឺងាយទទួលយកបាន ហើយច្បាស់លាស់ផង ។

**សួរដោយលោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំទទួលយកការណែនាំរបស់លោកប្រធាន ។

**ស៖** ក្នុងពេលសវនាការ លោកបានពន្យល់យ៉ាងច្រើនអំពីការប្រឹងប្រែងដែលលោកបានបំពេញដើម្បីធានាថាការសួរចម្លើយរបស់លោក គឺនាំទៅដល់ការដាក់បន្ទុកទៅដល់ខ្មាំងផ្សេងៗ ។ ហើយលោកបានពន្យល់ផងដែរថា លោកយកក្មេងៗដែលជាជនស្លូតត្រង់មិនដឹងអី ហើយបំពាក់បំប៉នពួកគេអប់រំពួកគេអំពីរៀបធ្វើទារុណកម្ម ហើយលោកបង្រៀនពួកគេឲ្យមានភាពសាហាវដល់កម្រិតមួយដើម្បីធ្វើយ៉ាងណាទាញចម្លើយសារភាព ដើម្បីដាក់បន្ទុកទៅដល់អ្នកដទៃថាមានកំហុស ។ ហើយលោកបានបញ្ជូនចម្លើយសារភាពទាំងអស់នោះឡើងទៅលើមេរបស់លោក ចំពោះឈ្មោះទាំងឡាយ ហើយលោកក៏បានបញ្ជាក់ទៅលើការចាប់ខ្លួន ហើយក្រោយមកយើងឃើញថា មានបុគ្គលទាំងឡាយដែលត្រូវបានគេឆ្លើយ

ដាក់នោះ គឺត្រូវបានគេចាប់ខ្លួន ហើយសម្លាប់ចោល ។ ហើយថាតើវាត្រឹមត្រូវដែរឬទេ? ក្នុងការនិយាយថា លោកបានអនុវត្ត និងអំណាចរបស់លោកក្នុងកម្រិតអតិប្បមារនៅក្នុងស-២១ ក្នុងនាមលោកជាប្រធាននៅកន្លែងនោះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមគោរព ជម្រាបលោកសហព្រះរាជអាជ្ញា! មុននឹងលើកសំណួរ លោកបានធ្វើអត្ថាធិប្បាយអំពីការងាររបស់ខ្ញុំ ដោយបន្ថែមគុណនាមដែលលោកពេញចិត្តបន្ថែម មិនមែនជាគុណនាមដែលខ្ញុំប្រើ ។ ខ្ញុំសូមនិយាយរឿងពិតវិញ។ ជម្រើសរបស់ខ្ញុំ គឺពិតជារើសយកយុវជនកសិករក្រយកមកបណ្តុះបណ្តាលគេ ដែលមានជំហរវណ្ណៈ ដែលមានជំហរស្មោះត្រង់ ហើយដែលអត់ចង់ដឹងឮអីច្រើនពាសវាលពាសកាលដែលមិនចាំបាច់ ។ ឧទាហរណ៍ ដូចមិត្ត ឈុន ផល ដែលព្រះរាជអាជ្ញាលោកឃើញស្រាប់ ខ្ញុំចង់បានអ៊ីចឹង ។ មកដល់ ខ្ញុំប្រគល់ភារកិច្ចដែលខ្ញុំត្រូវការឲ្យគេ ឲ្យគេចេះយាម ឲ្យគេចេះសួរចម្លើយ សព្វបែបយ៉ាង ។ ដូច្នេះ នេះជារឿងពិតដែលខ្ញុំធ្លាប់និយាយ ។

[០៩:៤៩:០៣]

ឯចំណែកចម្លើយសារភាព ខ្ញុំនិយាយហើយនិយាយទៀត ថាឧក្រិដ្ឋកម្មរបស់ខ្ញុំ វាមិនមែនស្ថិតនៅក្នុងសម្លាប់ដៃ-- មិនមែនស្ថិតនៅក្នុងការសម្លាប់មនុស្សដោយផ្ទាល់ដៃទេ គឺក្នុងការ ទីមួយ ហើយធំជាងគេ គឺការកសាងមនុស្សឲ្យចេះសួរចម្លើយ ។ បើសិនជាខ្ញុំកសាងមនុស្សដប់នាក់ ដែលស្មោះត្រង់និងបក្សកុម្មុយនីស្តកម្ពុជាដូចខ្ញុំហើយដែលធ្វើការងារហ្មត់ចត់ដូចខ្ញុំ គេអរ ។ ដូច្នេះ ឧក្រិដ្ឋកម្មវាកាន់តែទូលាយ នេះជារឿងខ្ញុំដែលខ្ញុំនិយាយ ។ ចំណែកការសួរចម្លើយ ដែលខ្ញុំទទួលស្គាល់ឧក្រិដ្ឋកម្មរបស់ខ្ញុំ គឺត្រង់ដែលខ្ញុំបដិសេធគោលជំហរត្រឹមត្រូវរបស់គេដែលចេះតែពិចារណា មែន ឬមិនមែនៗ ។ បញ្ហានេះឲ្យគេផាត់អាហ្នឹងចោលហើយឲ្យនិយាយថាមែនហ្នឹង ។ ឧទាហរណ៍ ការសួរចម្លើយឥឡូវ ក៏អ៊ីចឹងដែរ ។

**ស៖** ខ្ញុំសូមបញ្ឈប់លោកនៅត្រង់ទីនេះ ហើយខ្ញុំសូមលើកឡើងទៅលើចម្លើយដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺ 00149918 D21 គឺចម្លើយទាក់ទៅនឹងការងាររបស់លោកនៅស-២១ ហើយលោកបានលើកឡើងថា នៅមន្ទីរស-២១ គឺលោកធ្វើការងារក្នុងកម្រិតអតិបរិមា ហើយខ្ញុំធ្វើការងារដែលមិនអាចចៀសផុតតែប៉ុណ្ណោះ ។ ដូច្នេះ ខ្ញុំមិនដែលទទួលព័ត៌មានណាមួយឲ្យបានជាក់លាក់នោះទេ តើលោកយល់ស្របជាមួយខ្ញុំដែរឬទេថា ទាក់ទងលើភស្តុតាងលោកផ្តល់ជូនក្នុងតុលាការនេះ គឺលោកហាក់ដូចជាប្រាប់ព័ត៌មានខុសទៅដល់សហចៅក្រមស៊ើបអង្កេត ដែលលោកបានលើកឡើង

ថាលោកចៀសវាងការងារក្នុងកម្រិតអតិបរមា ។ ថាតើលោកយល់ស្របជាមួយខ្ញុំដែរឬទេថា នៅពេលដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតនោះ គឺលោកធ្វើយ៉ាងណាឆ្លើយចៀសវាងទៅលើការងារនិងតួនាទីរបស់លោកនៅមន្ទីរស-២១ តើអ៊ីចឹងមែនឬទេ?

**ឆ៖** លោកព្រះរាជអាជ្ញាជាទីគោរព! សូមមេត្តាបញ្ចេញកំណត់ហេតុសួរចម្លើយរបស់ខ្ញុំដោយសហចៅក្រមស៊ើបអង្កេតមានជាភាសាខ្មែរ ហើយនិងប្រតិចារឹករបស់ខ្ញុំនៅអង្គសវនាការនេះជាភាសាខ្មែរ យកមកបង្ហាញអង្គជំនុំជម្រះ ហើយសឹមលោកលើកបញ្ហា ។

**ស៖** ប្រហែលជាមានភាពងាយស្រួលនិងលឿនជាង ប្រសិនបើឲ្យលោកជនជាប់ចោទផ្តល់ជាយោបល់ថា តើវាពិតត្រឹមត្រូវដែរឬទេ? នៅស-២១ ខ្ញុំចៀសវាងធ្វើការងារនៅស-២១ ក្នុងលក្ខណៈអតិបរិមា ហើយខ្ញុំចៀសវាងធ្វើការងារច្រើននៅស-២១ ហើយខ្ញុំមិនបានទទួលព័ត៌មានច្រើនទេនៅទីនោះ ថាតើចម្លើយដែលលោកនិយាយនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំអត់យល់សំណួរលោកទេ ខ្ញុំអត់យល់ ខ្ញុំដូចឆ្លើយមិនត្រូវទេ ។

**ស៖** ខ្ញុំមិនអាចបញ្ជាំងនៅតាមអេក្រង់នេះទេ នៅពេលនេះ ។

**លោក ការ សាវុត្ថ៖**

ខ្ញុំបាទសូមគោរពលោកប្រធាន! ខ្ញុំសូមស្នើលោកសហព្រះរាជអាជ្ញាអន្តរជាតិ មេត្តាសួរសំណួរឲ្យបានច្បាស់ដើម្បីជនជាប់ចោទឆ្លើយ ។ លោកសួរជារួម ឧទាហរណ៍ថា កូនក្តីខ្ញុំហ្នឹង មិនបានសារភាពហ្នឹងវាអស់ទេ ។ ស្អីទីណាទេ សូមលោកលើករបាយការណ៍ដែលកាលនៅចៅស៊ើបអង្កេតចំណុចណាដែលលោកយល់ថា កូនក្តីខ្ញុំវាលាក់មិនសារភាពអស់នោះ សូមលោកលើកឲ្យចំ ។ អាហ្នឹងបានកូនក្តីខ្ញុំបញ្ជាក់ជូនបាន ។ សូមអរគុណ ។

[០៩:៥៣:៤១]

**ប្រធានអង្គជំនុំ៖**

ឥឡូវបើលោកតំណាងសហព្រះរាជអាជ្ញាបានផ្អែកទៅលើកំណត់ហេតុទាំងឡាយ ដែលធ្វើឡើងចំពោះមុខសហចៅក្រមស៊ើបអង្កេត អាចនិយាយឲ្យបានច្បាស់លាស់ថា ជាភាសាអ្វីដែលប្រើប្រាស់ ហើយនៅក្នុងកថាខណ្ឌ ឬក៏មាត្រា-- នៅទំព័រទីប៉ុន្មាន? ហើយមានលេខ ERN យ៉ាងម៉េច? ដើម្បីអង្គជំនុំជម្រះមានសមត្ថភាពនៅក្នុងការចាត់ចែងបញ្ជាំងនូវចំណុចដែលលើកមកដេញដោលនេះ ដើម្បីឲ្យជនជាប់ចោទឆ្លើយ បញ្ហាទីមួយ ។

ទីពីរ ខ្ញុំសូមរំឭកដល់សហព្រះរាជអាជ្ញាថា ដំណើរការនៃការសវនាការលទ្ធផលនៃការស៊ើបអង្កេតវាជាអំណោយផលមួយដល់ដំណើរការប្រព្រឹត្តទៅជាមូលហេតុនៃការចោទប្រកាន់ ។ ដូច្នេះ នៅលទ្ធផលនៃការជំនុំជម្រះកន្លងមក ចម្លើយរបស់ជនជាប់ចោទមានចំណុចខ្លះ គឺគាត់បញ្ជាក់ដែលគាត់មិនបានឆ្លើយនៅក្នុងអំឡុងពេលចំពោះមុខចៅក្រមស៊ើបអង្កេតទេ ប៉ុន្តែគាត់បានបញ្ជាក់ច្បាស់នៅចំពោះមុខអង្គជំនុំជម្រះនៅពេលដែលមានភស្តុតាងពេញលេញ ឬក៏មានការបង្ហាញហេតុដែលមានលក្ខណៈពេញលេញ គឺគាត់ឆ្លើយទៀតផង ។ អ៊ីចឹង អាចមានលក្ខណៈខុសគ្នាលើចំណុចថា ផ្អែកលើឯកសារទាំងស្រុងនៅដំណាក់កាលចៅក្រមស៊ើបអង្កេតអាចមានការប្រែប្រួលបំពេញបន្ថែម ដែលគាត់បានបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ ដើម្បីឱ្យបានងាយច្បាស់លាស់ គឺសូមបង្ហាញដូចអ្វីដែលទម្លាប់ធ្វើពីមុនមកនៅក្នុងដំណើរការនៃការផ្ទៀងផ្ទាត់ធៀបទៅនឹងឯកសារដែលមាននៅក្នុងសំណុំរឿង ។ បើសិនជាលោកអាចធ្វើបាន លោកអាចបង្ហាញនូវឯកសារដែលមានលេខ ERN ហើយនិងលេខទំព័រផង ដើម្បីយើងអាចបញ្ជាឱ្យទៅមន្ត្រីខាងតុលាការដើម្បីបញ្ចាំងនូវឯកសារនោះនៅចំពោះអង្គសវនាការពេលនេះដើម្បីពិភាក្សាដេញដោល ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ ។ ប្រហែលខ្ញុំអាចបន្តទៅមុខ ខ្ញុំសូមផ្តល់លេខ ERN គឺ 00149918 ។ D21 ជាភាសាអង់គ្លេស ។ ប៉ុន្តែ យ៉ាងណាក៏ដោយខ្ញុំអាចពិនិត្យទៅលើឯកសារនេះ នៅពេលក្រោយទៀត ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោក កាំង ហ្គេកអ៊ាវ ចំពោះពេលដែលលោកនៅមន្ទីរម-១៣ និងនៅពេលដែលលោកនៅមន្ទីរស-២១ រហូតដល់ពេលដែលលោកនិយាយថា លោកក្លាយទៅជាអ្នកទោសនៃរបបនោះ ។ តើលោកអាចជម្រាបតុលាការបានដែរឬទេ ថាតើនៅពេលណាដែលលោកយល់ឃើញថា លោកមិនក្លាយទៅជាអ្នកទោសរបស់របបខ្មែរក្រហមនោះទៀតទេ? ថាតើលោកបានមានអារម្មណ៍ដូច្នេះនៅពេលណា? នៅក្នុងឆ្នាំណាដែរ?

**ឆ៖** គឺនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ នៅពេលដែលរដ្ឋាភិបាលយកខ្ញុំមកទុកនៅអយ្យការយោធា ។

**ស៖** មុនពេលឆ្នាំ១៩៩៩ ថាតើលោកមានសេរីភាពក្នុងការដើរហើរចេញពីតំបន់ខ្មែរក្រហមដែរឬទេ មុនឆ្នាំ១៩៩៩?

**ឆ៖** មុនឆ្នាំ១៩៨៩ទេ ខ្ញុំគិតថា លោកព្រះរាជអាជ្ញាដឹងសភាពការណ៍នុ៎ងហើយ ។ ប្រហែលជាក្នុងឆ្នាំ១៩៨៧ មាស មុត កែនប្រជាជននៅសំឡូត យកទៅដាក់ជំរំសាថ្មី ។ ពេលនុ៎ងនរណាប៉ានដើរចេញក្រៅជំរំមិនបានទេ ។ ដល់ឆ្នាំ១៩៨៨ ត្រឡប់មកវិញ ខ្ញុំខ្លាចណាស់ ខ្លាចកម្លាំងតាម៉ុក ។ បើសិនជាខ្ញុំចេញមុខបង្ហាញថា ខ្ញុំប្រធានស-២១ កម្លាំងតាម៉ុក កាត់កខ្ញុំណា ។ ដូច្នេះ ខ្ញុំដើរហើរសេរីបាន ក៏ប៉ុន្តែវានៅជាប់អ៊ីចឹង ដែលខ្ញុំខ្លាច តាម៉ុក ជាខ្មែរក្រហម ។ ដូច្នេះ ហើយបានជាខ្ញុំនិយាយថា របបឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវាមកចប់នៅថ្ងៃ០៦ ខែ០៣ ឆ្នាំ១៩៩៩ ថ្ងៃដែល ហ៊ុន សែន ទៅចាប់ តាម៉ុក យកមកទុកនៅអយ្យការយោធាសម្រាប់កាត់ទោស ។

**ស៖** ដូច្នេះលោកកំពុងតែនិយាយថា ប្រហែលជាម្ភៃប្រាំមួយ ទៅម្ភៃប្រាំពីរឆ្នាំ ចាប់ពីឆ្នាំ១៩៧១ លោកពុំមានលទ្ធភាពណាមួយក្នុងរយៈពេលម្ភៃប្រាំមួយ ម្ភៃប្រាំពីរឆ្នាំនេះ ដើម្បីគេចចេញពីរបបខ្មែរក្រហមនោះទេ ។ តើត្រឹមត្រូវដែរឬទេនូវអ្វីដែលលោកកំពុងលើកឡើងនេះ?

**ឆ៖** សូមលោកដកធ្វើលេខដកសិន ខ្ញុំសូមលោកធ្វើលេខដកសិន ។ ១៩៩៩ ដក ១៩៧១, ២៧ បាទ លួ ។ ខ្ញុំស្ថិតនៅក្នុងការឃុំគ្រងនៃរបបខ្មែរក្រហមម្ភៃប្រាំពីរឆ្នាំ គ្រាន់តែរូបភាពខុសគ្នា។ ។ លោកព្រះរាជអាជ្ញាជ្រាបហើយ ខ្ញុំល្មើសបន្តិច ប៉ាកជំប៉ានខុសបន្តិច ប្រពន្ធខ្ញុំត្រូវគេសម្លាប់ ។ ខ្ញុំត្រូវរបួសប៊ិះនឹងស្លាប់ ។

**ស៖** វាពិត ឬក៏មិនពិតដែលលោកនៅជាមួយនឹងខ្មែរក្រហមរហូតដល់ឆ្នាំ៩០ ហើយលោកនៅតែជឿទៅលើរបបខ្មែរក្រហម ។ តើត្រឹមត្រូវដែរឬទេ?

[០៩:៥៩:៥៦]

**ឆ៖** លោកមានប្រសាសន៍អ៊ីចឹងវាម្យ៉ាងហើយ រឿងនៅត្រូវតែនៅ ក៏ប៉ុន្តែជឿ ខ្ញុំលែងជឿទាំងស្រុងហើយ ពីព្រោះស្អី? ក្រោយឆ្នាំ១៩៧៩ ខ្ញុំអត់មានធ្វើការខាងសមរភូមិទៀតទេ ។ លោកសួរទៅរាល់ថ្ងៃនេះ ចៅហ្វាយស្រុកសំឡូតឈ្មោះលោក ហែន សុផល ចង់បានខ្ញុំទៅប្រធានកងដឹកជញ្ជូនខ្ញុំមិនទៅ ។ ដល់ក្រោយ ស៊ូ ម៉េត ចាត់តាំងខ្ញុំឲ្យបង្រៀនក្មេងៗ ថ្នាក់កុមារដ្ឋាន ខ្ញុំបង្រៀន ។ ដូច្នេះ ខ្ញុំនៅជាមួយនឹងគេក៏ពិតមែន ក៏ប៉ុន្តែការងារស្អីដែលបម្រើសមរភូមិ ដែលបម្រើការកាប់សម្លាប់ ខ្ញុំអត់ធ្វើទៀត ។ ខ្ញុំមានសេរីភាពចាប់តាំងពីថ្ងៃក្រោយ ១៧មេសា ត្រង់ប៉ានប្រកែក ប៉ានគេចអំពីការងារសមរភូមិ ខាងការកាប់សម្លាប់ប៉ុណ្ណឹង ។ ដូច្នេះ ខ្ញុំបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** នៅពេលដែលលោកនិយាយទៅអ្នកចិត្តសាស្ត្រអំពីមរណភាពរបស់ឪពុករបស់លោកនៅឆ្នាំ១៩៩០ ហើយលោកនិយាយថា ហើយគេនិយាយនៅក្នុងរបាយការណ៍របស់គេ និយាយអំពីមរណ-ភាពរបស់ឪពុកនៅឆ្នាំ១៩៩០ នៅពេលនោះលោកមានអារម្មណ៍ម៉េច? ហើយលោកនិយាយថា ខ្ញុំមិនអាចជាជនបដិវត្តន៍បើខ្ញុំមានអារម្មណ៍អាណិតអាសូរនោះ ។ ប៉ុន្តែនៅឆ្នាំ១៩៩០ហ្នឹង លោកនៅតែជាជនបដិវត្តន៍ដដែល ហើយនៅតែជឿរបបហ្នឹង តើអ៊ីចឹងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំប្លែកដែរនឹងសេចក្តីសន្និដ្ឋានរបស់ចិត្តសាស្ត្រ ជាមួយ *ម៉ាដាម* ស៊ីរ៉ូនី ហើយនិងលោក កាស៊ុន បូណាត ។ ដូចជាមិនទាន់ឃើញឈរនៅលើមូលដ្ឋានពាក្យណាមួយពិតប្រាកដរបស់ខ្ញុំសោះ គាត់សន្និដ្ឋានអ៊ីចឹង ។ ដូច្នេះ វាជារឿងខ្ញុំទាស់គ្នាមិនពេញចិត្តនឹងសេចក្តីសន្និដ្ឋានរបស់ ស៊ីរ៉ូនី ។ សូមលោកកុំយកបញ្ហាហ្នឹងមកនិយាយ ខ្ញុំអត់ទទួលស្គាល់ទេ ។

**ស៖** អ្នកជំនាញមួយចំនួនបានពិនិត្យនូវឯកសារទាំងឡាយនៅក្នុងសំណុំរឿង ជាពិសេសឯកសារមកពីស-២១ លោក ដេវីដ ឆេនដ័ល័រ ក៏បានបញ្ជាក់ដែរ ហើយអ្នកចិត្តសាស្ត្របានបញ្ជាក់ផងដែរថាហេតុផលដែលលោកគោរពបញ្ជានោះ គឺមិនមែនដោយសារការភ័យខ្លាចទេ ពីព្រោះថាលោកជឿអំពីមូលដ្ឋាននៃការបញ្ជានោះ ហើយសំណួរមួយ ខ្ញុំលើកឡើងពីចំណុចមួយនៃរបាយការណ៍ពីអ្នកចិត្តសាស្ត្រខាងផ្លូវចិត្តនោះ ។ របាយការណ៍នោះនិយាយថា ការគោរពមិនមែនជាកត្តាជំរុញអំពើរបស់ទេៗ ប៉ុន្តែជាផលវិបាក ។ ប៉ុន្តែវាមានហេតុផលដែលឲ្យជឿបានថា ហើយនៅ១៩៧៧នោះ គំនិតនោះ មនោគមវិជ្ជានោះ គឺគាត់មានការពេញចិត្តក្នុងការធ្វើការងារជាជាងការដើរចេញពីការងារនោះ ។ តើករណីហ្នឹង ពិតឬទេនូវអនុវត្តការងាររបស់លោកនៅស-២១ ដោយសារតែលោកជឿជាក់នូវបដិវត្តន៍ មិនមែនដោយសារការភ័យខ្លាចនោះទេ មិនមែនដោយសារធ្វើតាមតែបញ្ជានោះទេ?

[១០:០៣:៤៨]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញាជាទីគោរព! ខ្ញុំសូមគោរពរាយការណ៍ជូនដូចតទៅ៖ ការវិភាគរបស់អ្នកជំនាញវាជាបញ្ហាមួយ។ ឯចំណែក ហេតុផលជាក់ស្តែងដែលខ្ញុំដឹងក្នុងខ្លួនជាអ្នកធ្វើវាជាបញ្ហាមួយផ្សេងទៀត ។ ខ្ញុំសូមរាយការណ៍ជូនអំពីបញ្ហាដែលខ្ញុំធ្វើនេះវិញម្តង ។ មូលដ្ឋានឯកសារនៅទាំងអស់ របស់ស-២១ នៅទាំងអស់ លោកព្រះរាជអាជ្ញាអាចយកមកផ្ទៀងផ្ទាត់នូវសេចក្តីបញ្ជាក់របស់ខ្ញុំ ។ ខ្ញុំធ្វើតាមការណែនាំរបស់គេទាំងបង្ខំ-- យើងនិយាយថា បង្ខំចិត្តអ៊ីចឹងក៏បានដែរ ។ បើគេដឹងព្រឹក ដឹងល្ងាច រាល់ថ្ងៃអំពីថាចម្លើយអ្នកណាដល់ៗ រឿងនេះមិត្តធ្វើយ៉ាងម៉េច អានេះជាមួយ សុន

សេន ។ ជាមួយ នួន ជា បីថ្ងៃគាត់ហៅទៅជួបម្តង គាត់ឲ្យខ្ញុំរាយការណ៍ យើងគេចម៉េចរួចពីយើងមិនត្រូវធ្វើតាមបញ្ជាគេ ។ ដូច្នេះ ពេញចិត្ត ឬមិនពេញចិត្តត្រូវតែធ្វើ បើអ្នកឯងមិនធ្វើអ្នកឯងកំបុតក។ នេះសភាពការណ៍ជាក់ស្តែងដែលខ្ញុំសូមជម្រាបជូនលោកព្រះរាជអាជ្ញាទន្ទឹមនឹងសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញដែលគេសន្និដ្ឋានតាមការវិភាគរបស់គេ ។

[១៥:០៥:០៧]

**ស៖** មានសំណួរមួយចំនួនទាក់ទងអំពីការចាប់ខ្លួនរបស់លោក លោកនិយាយថា ប្រាប់តុលាការថាតើលោកបានត្រៀមខ្លួនដើម្បីៗធ្វើជាប្រធានមន្ទីរអប់រំនៅសំឡូតដែរឬទេ? ប៉ុន្តែក្រោយមក លោកប្តូរសម្តីហ្នឹង នៅពេលដែលបានជួប នីក ដងឡុប អ្វីៗត្រូវបានសម្របសម្រួល ប៉ុន្តែក្រោយមក នីក ដងឡុប ជួបខ្ញុំ ហើយគេបានចាប់ខ្ញុំ ហើយគេបានចាប់ខ្ញុំមកដាក់ឃុំឃាំងនៅក្នុងថ្ងៃទី ១០ ខែឧសភា ១៩៩៩ ។ ប៉ុន្តែសំណួររបស់ខ្ញុំទាក់ទងថា ក្រៅពី នក ដងឡុប ទៅជួបលោក ដែលបង្ហាញរូបថតលោក ដែលថតនៅស២-១ នោះ ហើយលោកបានដឹងពីហេតុការណ៍មួយចំនួន គាត់បានដឹងពីតួនាទីរបស់លោកនៅពេលនោះ ។ បើគាត់មិនដឹងទេ លោកនៅតែបង្ហាញនៅកន្លែងនោះ ហើយជាប្រធានមន្ទីរអប់រំនៅសំឡូតដដែល ។ តើលោកឯកភាពជាមួយខ្ញុំដែរឬទេគំនិតនេះ?

**ឆ៖** លោកព្រះរាជអាជ្ញាជាទីគោរព! ប្រសាសន៍របស់លោកមានទាក់ទងដល់រឿង នីក ដងឡុប សេចក្តីរាយការណ៍យ៉ាងនេះ យ៉ាងនោះ ខ្ញុំក្តាប់មិនបានទេ ។ ខ្ញុំសូមអនុញ្ញាតលោកមេត្តាជម្រាបលោកដោយស្មោះ តាមរឿងដែលកើតជាក់ស្តែង ។

ខ្ញុំបានរាយការណ៍ជូនអង្គសវនាការយើងនេះរួចមកហើយថា នៅពេលដែល ស៊ូ ម៉េត ចុះចូលជាមួយរដ្ឋាភិបាលៗទទួល ស៊ូ ម៉េត ធ្វើសមាហរណកម្ម ប្អូនពៅខ្ញុំវាស្ទុះមកយកខ្ញុំពីស្វាយចេកទៅនៅឯនោះ ទាំងអស់គ្នាគណៈកម្មាធិការសំឡូត ដែលមានស៊ូ ម៉េត, មាន ហែន សុផល ចៅហ្វាយស្រុកបច្ចុប្បន្ន ហើយនិងមានឧត្តមសេនីយ៍ ង៉ែន គង់ ប្រជុំគ្នាទៅថា ខ្ញុំក៏ធ្វើសមាហរណកម្មនឹងគេដែរ ។ សាថ្មី មិនសាថ្មីអីទេ ក៏ប៉ុន្តែធ្វើសមាហរណកម្មនៅក្នុងដីសំឡូត ព្រោះខ្ញុំជាមនុស្សសំឡូតចាស់ ហើយឲ្យខ្ញុំធ្វើជាប្រធានការិយាល័យអប់រំស្រុក ជាតួនាទីស្រុក ជាតួនាទីមួយខាងអប់រំរបស់រដ្ឋាភិបាល ។ ទើបនឹងរៀបចំហ្នឹង ស្រាប់តែទៅកើតរឿងអា នីក ដងឡុប វាទៅបង្កើតរឿងរហូតដល់មានព្រឹត្តិការណ៍ថ្ងៃ ១០ ខែឧសភា ១៩៩៩ ហ្នឹងមក ។ នេះជារឿងពិត ។

**ស៖** ដូច្នេះ លោកមិនមានចេតនាដើម្បីប្រគល់ខ្លួនលោកទៅឲ្យអាជ្ញាធរទេ រហូតទាល់តែបានប្រឈមមុខទៅនឹងហេតុការណ៍អតីតកាលដែលធ្លាយឡើង ។ តើលោកឯកភាពអ៊ីចឹងទេ?

[១០:០៨:១៩]

**ឆ៖** សំណួរលោកកាត់ណាស់ ខ្ញុំមិនឆ្លើយថាឯកភាពនិងមិនឯកភាពទេ ។ ខ្ញុំសូមឆ្លើយរាប់រៀបដូចតទៅ៖ ខ្ញុំបានរាយការណ៍ជូនអង្គសវនាការនេះរួចហើយ ។ ខ្ញុំគិតថា អាថ៌កំបាំងអីក៏ដោយ មិនដែលលាក់បានជារៀងរហូតទេ គង់តែថ្ងៃណាមួយបែក ។ ខ្ញុំនៅបន្ទាយមានជ័យ ខ្ញុំបានទទួលស្គាល់ជាគ្រូបង្រៀន ក៏ប៉ុន្តែខ្ញុំនៅមិនអស់ចិត្តទេ ។

នៅពេលឆ្នាំ១៩៩៦ ខែមិថុនា លោកគ្រូ អៀង សារី ចុះចូលរដ្ឋាភិបាល បានសមាហរណកម្ម ។ ខ្ញុំប្រុងរត់ទៅរកគាត់ដើម្បីធ្វើសមាហរណកម្ម ឲ្យរដ្ឋាភិបាលទទួលស្គាល់ខ្ញុំ ។ ប៉ុន្តែ ខ្ញុំមិនស្គាល់ អៀង សារីៗ មិនស្គាល់ខ្ញុំៗនៅស្ងៀមសិន ។ ដល់ ស៊ូ ម៉េត បានៗខ្ញុំបង្ហាញខ្លួនឲ្យរដ្ឋាភិបាល ។ ដូច្នេះ ខ្ញុំត្រូវតែបង្ហាញខ្លួនឲ្យរដ្ឋាភិបាលរបស់ខ្ញុំ ក៏ប៉ុន្តែបង្ហាញតាមអ្នកណា? បង្ហាញតាមមនុស្សដែលខ្ញុំស្គាល់ ខ្ញុំទុកចិត្តគឺ ស៊ូ ម៉េត ។ ដូច្នេះ ខ្ញុំអត់មានគេចអីពីរដ្ឋាភិបាលទេ ទាល់តែ នីក ដងឡុប វាទៅអីៗនោះទេ អត់ទេ ។ ខ្ញុំអត់គេចពីរដ្ឋាភិបាលទេ រកតែផ្លូវបង្ហាញឲ្យរដ្ឋាភិបាលឃើញ ។

**ស៖** គ្រាន់តែសំណួរមួយចំនួនតូចអំពីការសុំខមាទោសរបស់លោក ហើយលោកបានឆ្លើយសំណួរទៅចៅក្រម ឡាវែន៍ នៅពេលដែលផ្តល់សក្ខីភាពទាក់ទងទៅនឹងបទឧក្រិដ្ឋដែលធ្វើឡើងនៅម-១៣ និងស-២១ ហើយលោកជឿថា មជ្ឈិមបក្សជាអ្នកទទួលខុសត្រូវចំពោះប្រវត្តិសាស្ត្រ ហើយលោកបានប្រាប់ ភិតធ័រ ឡឺប្រិច ដូចគ្នាដែរ នៅពេលដែលលោកនៅតុលាការយោធានោះ ។ ប៉ុន្តែ នៅពេលដែលលោកបានជួបមេធាវីទាំងពីររូបរបស់លោក ខ្ញុំសន្និដ្ឋានថាលោកបាននិយាយទៅមេធាវីទាំងពីរថ្ងៃនេះក្រោយពីការពិគ្រោះយោបល់ជាមួយគាត់ ហើយគាត់ថា រដ្ឋាភិបាលមិនជាអ្នកទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋនោះទេ ហើយគឺបុគ្គលម្នាក់ៗជាអ្នកទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់ខ្លួន ។ ប៉ុន្តែ តាមទស្សនៈខ្ញុំៗនៅតែជឿថា ខ្ញុំគឺជានគរបាលដែលអនុវត្តបញ្ជាដែលគេចាត់ឲ្យខ្ញុំ ដែលថ្នាក់លើចាត់ឲ្យខ្ញុំ ។ នេះជាហើយជាអ្វីដែលខ្ញុំមានការវិវឌ្ឍន៍នៅក្នុងគំនិតទាក់ទងទៅនឹងបទឧក្រិដ្ឋ ហើយនិងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

សំណួររបស់ខ្ញុំចំពោះលោកគឺ តើត្រឹមត្រូវដែរឬទេ លោកទទួលខុសត្រូវផ្ទាល់ខ្លួន ជាពិរុទ្ធភាពផ្ទាល់ខ្លួនតាំង-- មុនឆ្នាំ២០០៧ នោះគឺមិនដែលនិយាយដូច្នោះទេ លុះត្រាតែមកដល់តុលាការនេះ ទើប

លោកបាននិយាយ?

**ឆ៖** រឿងរ៉ាវខ្ញុំសូមបញ្ជាក់ឡើងវិញតាមការពិត ។ តាមពិត ការពិតដែលខ្ញុំនិយាយ លោកយកទៅស្លុកថែមគ្រឿងថែមគ្រៅទៅហើយ ។ ខ្ញុំសូមនិយាយត្រឡប់ការពិតឡើងវិញ ។ តាមហេតុការណ៍ជាក់ស្តែង នៅពេលដែលខ្ញុំទទួលភារកិច្ចជាមន្ទីរនគរបាលនៅម-១៣ ឆាយ គឹមហ៊ា ប្រាប់ខ្ញុំ ។

[១០:១១:៥២]

ម-១៣ គ្មានសិទ្ធិទៅចាប់មនុស្សទេ ចាំទទួលមនុស្ស ។ ឯចំណែក រឿងចាប់មនុស្សមិត្តកុំភ័យ មជ្ឈិមបក្សគេទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ ។ នេះ ឆាយ គឹមហ៊ា និយាយច្បាស់ ខ្ញុំនៅរក្សាគោលគំនិតហ្នឹងរហូតមក ក៏ប៉ុន្តែ ខ្ញុំតក់ស្លុតដែរ ដោយឃើញចេះតែចាប់ ។ ខ្ញុំបានបដិសេធនៅជាមួយនឹង ភិតផ័រ ឡឺប្រិច ដែល ភិតផ័រ ឡាប្រិច ទៅជួបខ្ញុំ ខ្ញុំគិតថា ភិតផ័រ ឡឺប្រិច មានឲ្យគេកត់ត្រាទុក ។ ថ្វីត្បិតតែថ្ងៃនោះខ្ញុំអត់មានឃើញម៉ាស៊ីនថតសំឡេងក៏ដោយ ក៏ខ្ញុំជឿថា ភិតផ័រ ឡឺប្រិច ឲ្យគេកត់ត្រាទុក ។ ខ្ញុំថាខ្ញុំជាប៉ូលិសរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ជារដ្ឋាភិបាលពេញលក្ខណៈច្បាប់ ស្របច្បាប់តែមួយគត់របស់សហប្រជាជាតិ នេះខ្ញុំនិយាយជាមួយមុខ ភិតផ័រ ឡឺប្រិច អ៊ីចឹង ។ បើខ្ញុំមិនធ្វើតាមទេគេកាត់កខ្ញុំ ។ ដូច្នេះខ្ញុំមានអីខុស? ខ្ញុំនិយាយជាមួយនឹង ភិតផ័រ ឡឺប្រិច អ៊ីចឹង ។ នេះរឿងទីពីរ ។

ដល់ក្រោយមកខ្ញុំមកជួបមេធាវីខ្ញុំទាំងពីរ ។ គាត់ពន្យល់ថា រដ្ឋាភិបាលហ្នឹងជារដ្ឋាភិបាលឧក្រិដ្ឋយន្តការឧក្រិដ្ឋ ដូច្នេះអ្នកឯងត្រូវតែមានតួនាទីមួយក្នុងឧក្រិដ្ឋកម្មនេះ។ នេះដំណើរការវិវឌ្ឍន៍នៃការយល់ដឹងរបស់ខ្ញុំវាបែបនេះ ។ នេះសូមសង្ខេបខ្លីជូនលោកព្រះរាជអាជ្ញាប៉ុណ្ណេះ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកចៅក្រម ហើយសហសេវិករបស់ខ្ញុំនឹងមានសំណួរមួយចំនួន ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** សួស្តីលោក កាំង ហ្គេកអ៊ាវ ។ តើលោកដឹងទេថា អ៊ុន លន ហៅ ណាត នោះត្រូវបានដកចេញពីតំណែងនៅខែមីនា ឆ្នាំ១៩៧៦ ដោយសារមូលហេតុអីដែរ? ហើយថាដកហ្នឹង ដកទៅណា?

**ឆ៖** អរគុណលោកព្រះរាជអាជ្ញាដែលលើកសំណួរនេះ ។ អ៊ុន លន អត់ហៅ ណាត ដកចេញនៅខែ៣ កាលនោះមេប្រាប់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមជម្រាបសួរលោកប្រធាន! ឥឡូវនេះយើងទាក់ទងទៅនឹងការសួរសំណួរនិយាយពីអត្តចរិតរបស់ជនជាប់ចោទ ។ ហើយខ្ញុំមិនគិតថា សំណួរនេះពាក់ព័ន្ធទៅនឹងអត្តចរិតជនជាប់ចោទទេ ។ ខ្ញុំសូមអនុញ្ញាតឲ្យត្រឡប់ទៅប្រធានបទនៃសវនាការថ្ងៃនេះវិញ ។

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់មេធាវីការពារក្ដីជាការត្រឹមត្រូវ ។ អ៊ីចឹងតំណាងសហព្រះរាជអាជ្ញាជាតិ សូមរៀបចំសំណួរដោយជ្រើសរើសនូវសំណួរណាដែលពាក់ព័ន្ធជាមួយនឹងបំណងនៃការសួរដេញដោលអំពីអត្តចរិតជនជាប់ចោទ តាមរបៀបវារៈនៃដំណើរការសវនាការថ្ងៃនេះ ។

**សួរដោយលោក សេង ប៊ុនឃាង៖**

អរគុណលោកប្រធាន ។ ដោយសារថាសំណួរនេះ តំណាងអយ្យការគិតថាវាមានពាក់ព័ន្ធទៅនឹងសំណួរផ្សេងទៀត ។

**ស៖** អ៊ីចឹងខ្ញុំសូមបន្តសំណួរទៅទៀត ។ តើលោកធ្លាប់គិតថា លោកមានការច្រណែននឹងឈ្មោះ អ៊ិន លន ហៅ ណាត ដែរឬទេ ដែលថានៅពេលនោះលោកជាអនុប្រធាននៃមន្ទីរស-២១ ដែលកន្លងមកលោកធ្លាប់បានជម្រាបអង្គជំនុំជម្រះថា លោកគឺជាប្រធានខ្សែជនបង្គោល ដែលក្នុងនោះមាន ណាត គឺជាសមាជិកក្រុមរបស់លោក ប៉ុន្តែពេលនេះបែរជា ណាត ធ្វើជាប្រធានរបស់លោកវិញ ។ តើលោកមានការតូចចិត្តនឹងបញ្ហានេះដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំសូមជម្រាបដោយស្មោះត្រង់បញ្ហានេះ ។ អ៊ិន លន ហៅ ណាត គេអាយុច្រើនជាងខ្ញុំ ។ លោកព្រះរាជអាជ្ញាអាចសង្កេតឃើញខ្ញុំហើយ នៅក្នុងអង្គសវនាការយើងនេះ ខ្ញុំលើកដៃថ្វាយបង្គំមនុស្សពីរនាក់ ម្សិលមិញខ្ញុំលើកដៃថ្វាយបង្គំព្រឹទ្ធាចារ្យ ស្ដេហ្វិន ហាស្ដែរ្យល ពីចម្ងាយ ។ ប៉ុន្មានថ្ងៃមុន ខ្ញុំលើកដៃថ្វាយបង្គំលោកជំទាវ មាស គេតសម្ផុត្ត អ្នកណាអាយុច្រើនខ្ញុំថ្វាយបង្គំអ៊ីចឹងហើយ ខ្ញុំគោរពអ្នកនុ៎ង ។ ដូច្នេះជាមួយ អ៊ិន លន ហៅ ណាត គេនៅក្រោមខ្ញុំពីអង្កាល់មុនមែន តែខ្ញុំក៏មិនហ៊ានបំពាននឹងអាយុគេដែរ ។ នេះជាអត្តចរិតមួយរបស់ខ្ញុំ ។

ក៏ប៉ុន្តែដល់មកនៅស-២១ លោកព្រះរាជអាជ្ញាលោកនៅស្រុកខ្មែរលោកគង់ជ្រាប ។ បក្សកុម្មុយនីស្ដកម្ពុជាគេឲ្យតម្លៃចលនាយោធាជំនាន់នោះ ជាចលនាមួយដែលមានលក្ខណៈខ្ពង់ខ្ពស់ឧត្ដុង្គឧត្ដមស័ក្ដិប៉ុន្មានអីប៉ុន្មាន គេប្រគល់ឲ្យពួកយោធាហើយ ណាត គេៗជាលេខាវរសេនាតូចតាំងពីឆ្នាំ១៩៧០

តាម៉ុក ជ្រើសរើសដោយខ្លួនឯង ។ គ្នាបីនាក់ វរសេនាតូចជំនាន់នុំង អ៊ិន លន ហៅ ណាត, សំ ប៊ិត ហើយនិង មាស មុត ។ ខ្ញុំអត់ច្រណែនទេ ។

ខ្ញុំអង្គាល់នៅមន្ទីរអមលាំង សូមជម្រាបលោកព្រះរាជអាជ្ញា នៅក្នុងអនុសាខាមួយ ប្រជុំអនុសាខាមកប្រជុំគ្នានៅឯខាង-- ប្រជុំសាខាមកនៅប្រជុំគ្នានៅឯមន្ទីរ៥០៥ នៅក្រាំងបេង ឃុំពាម ឯនេះ ។ ដូច្នេះបើនិយាយពីឋានៈក្នុងបក្ស វាខុសគ្នាឆ្ងាយណាស់ ។ ដូច្នេះ ខ្ញុំអត់ច្រណែននឹងគេទេ ។ នេះម្យ៉ាង ។ ម្យ៉ាងទៀត ខ្ញុំដឹងថាការងារនៅស-២១ ខ្ញុំមិនចង់ធ្វើ ដូច្នេះបានគេនៅពីលើនោះ អរនោះអរ ។ នេះជម្រាបដោយស្មោះត្រង់ អត់មានច្រណែនទេ ។

**ស៖** អរគុណ ។ បន្ទាប់ពីថ្ងៃរំដោះ ៧មករា ១៩៧៩ មក តើលោកនៅតែគោរព និងមានភក្តីភាពចំពោះ សុន សេន ដដែលឬក៏យ៉ាងណា?

**ឆ៖** ១៧ មករា?

**ស៖** ៧ មករា ១៩៧៩ ។

**ឆ៖** អ៊ូ! បាទ ។ ខ្ញុំអរគុណលោកចៅក្រម ដែលលើកបញ្ហានេះត្រូវចំណុចចិត្ត ដែលខ្ញុំចង់លាតត្រដាងជូនជាតិប្រជាជនកម្ពុជាហើយ ។ ខ្ញុំតក់ស្លុតណាស់នឹងឱ្យខ្លាំងឆ្លើយដាក់គាត់ ភ័យនេះភ័យ ដល់ថ្ងៃ២៥ មិថុនា ១៩៨៦ ដែលគាត់ហៅខ្ញុំទៅជួបនៅមន្ទីរក-១៨ គាត់មានប្រសាសន៍មួយមាត់ គាត់ថារឿងចាស់ទុកចោល យើងគិតរឿងថ្មី គឺសាមគ្គីគ្នាវៃយ៉ួន ។ ខ្ញុំសង្កេតមើលឫកពារលោកគ្រូ សុន សេន ខ្ញុំនៅតែមានសេចក្តីអាណិតអាសូរដល់ខ្ញុំ នៅតែស្រឡាញ់ខ្ញុំ នៅតែខំអប់រំកសាងខ្ញុំដូចពីមុន ខ្ញុំកាន់តែគោរពគាត់ឡើង ។ ដូច្នេះហើយបានជាអារម្មណ៍ខ្ញុំជាប់ជាមួយនឹង សុន សេន ខ្លាំងមែនទែនពីថ្ងៃ ២៥ មិថុនា ១៩៨៦ ហ្នឹងមក ខ្លាំងណាស់ ដោយសាររឿងហ្នឹង ដោយសារគាត់បានលើកលែងទោស ដែលខ្ញុំធ្វើខុសចំពោះគាត់ហ្នឹងចោល ។

**លោក សេង ប៊ុនឃាង៖**

អរគុណ ។ លោកប្រធានតំណាងអយ្យការអស់សំណួរហើយបាទ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការសវនាការ ។

*[សវនាការសម្រាកពីម៉ោង១០:២០នាទី ដល់ម៉ោង ១០:៤៤នាទី ]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្ដី ដើម្បីមានឱកាសតាំងសំណួរដល់ចំពោះកូនក្ដីរបស់ខ្លួន ដែលពាក់ព័ន្ធមួយនឹងការធ្វើសវនាការអំពីអត្តចរិតជនជាប់ចោទ ។ សូមអញ្ជើញលោកមេធាវី ។

**ការតាំងសំណួរដោយលោកមេធាវីការពារក្ដី**

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណ និងសូមគោរពលោកប្រធាន សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ និងសូមគោរពអង្គសវនាការទាំងមូល ។

**ស៖** លោក ឌុច នៅពេលដែលលោករៀននៅសាលាបឋមសិក្សា តើលោកដែលឃើញរូបថត ម៉ៅ សេទុង ដែរឬទេ? ហើយបើលោកធ្លាប់ឃើញនៅសាលាបឋមសិក្សានោះ ពេលឃើញនោះតើលោកមានអារម្មណ៍យ៉ាងណា? សូមលោកបញ្ជាក់ ។

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំឃើញរូបថត ម៉ៅ សេទុង មិនមែននៅក្នុងសាលាទេ គឺនៅផ្ទះចិនលក់ចាប់ហួយម្នាក់ឈ្មោះ ឈាវ គ័ន នៅផ្សារស្ទោង ជារូបថតប្រភេទកាប៉ុស្ដាល់ ។ ម៉ៅ សេទុង គាត់ឈរបញ្ឆិតដែលគេហៅ *ទ្រ័រកា* ហើយរូបថតគាត់មិនមែននេះទេ គឺពីត្រឹមចង្កេះឡើងលើ-- ពីត្រឹមៗភ្លៅឡើងលើ ។ ខ្ញុំសូមបញ្ជាក់ថា ពេលនុ៎ងចិនៗអរគុណានឹង ម៉ោង សេទុង ដែលបានដោះស្រាយបញ្ហាជីវភាពប្រជាជនចិននៅស្រុកចិនបាន ។ ចិនមានបាយហូបចុក នេះខ្ញុំរើបដែរ ដោយបងប្អូនរបស់ខ្មោចជីតាខ្ញុំខាងឪពុកនៅស្រុកចិននឹងគេដែរ ធ្លាប់ក្រធ្លាប់អត់ ។ នេះខ្ញុំសូមជម្រាបបញ្ជាក់អ៊ីចឹង ។

**ស៖** សូមអរគុណ ។ ចុះពេលនៅរៀនអនុវិទ្យាល័យកំពង់ធំ ហេតុអ្វីបានជាលោកហៅ ស៊ូ សាត ថាមីងៗ ចំណែកឯង ឃុន សាមុត លោកអត់ហៅថា មីងទេ ព្រោះពីរនាក់ហ្នឹងមិត្តភក្ដិនឹងគ្នា លោកបែរជាហៅថា បងទៅវិញ ។ សូមលោកពន្យល់អារម្មណ៍លោកគិតយ៉ាងម៉េច បានជាលោកហៅអ៊ីចឹង?

[១០:៤៧:១៦]

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំទាំងប្រាំនាក់ ប្រុសបី ស្រីពីរនេះ មានអាយុប្រហែលគ្នា រួមគ្នារៀនសូត្រ សុទ្ធតែជាសិស្សពូកែដូចគ្នា ។ ខ្ញុំខ្លាចណាស់ ខ្លាចវាមិននៅត្រឹមតែការរៀនសូត្រវាវិវឌ្ឍន៍ទៅជារឿងជំងឺស្នេហា ម្ល៉ោះហើយទាំងបីនាក់ក្មេងប្រុសៗមកពីស្ទោងនេះ ហៅ ឃុន សាមុត នេះហៅបងៗមុត ។ ឯចំណែក ស៊ូ សាត មានតែខ្ញុំម្នាក់ទេហៅគាត់មីង ព្រោះខ្ញុំពួកម៉ាកជាមួយនឹង អាកុល

ក្មួយគាត់នុ៎ង ហើយក៏ហៅមីងជាប់រហូតអ៊ីចឹងមក ។ ដូច្នេះហៅមីង និងបងនេះ ដើម្បីជាចៀសវាងឥទ្ធិពលដែលមានស្នេហានៅក្នុងក្ដីបសិក្សានេះ ហើយយើងខ្ញុំចៀសវាងបានមែន ។

**ស៖** សូមអរគុណ ។ ពេលលោករៀននៅមហាវិទ្យាល័យគរុកោសល្យ តើលោកបានទទួលការបំពាក់បំប៉ន ការអប់រំឲ្យធ្វើបដិវត្តន៍ពីអ្នកណាខ្លះ?

[១០:៤៨:២៩]

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំជួបលោកគ្រូ សុន សេន នៅឆ្នាំ១៩៦៣ ពេលនុ៎ងខ្ញុំរៀននៅថ្នាក់ *ទែមីណាល់* នៅឡើយទេ ។ ខ្ញុំបានសន្យានឹងគាត់ថា ចាំខ្ញុំប្រលងបាក់ឌុបជាប់សឹមខ្ញុំគិតគូរ ប៉ុន្តែដល់ប្រលងជាប់អ៊ីចឹងទៅខ្ញុំនៅតែគិតគូរពីរឿងខំរៀន *ម៉ាតេម៉ាទីក* តទៅទៀត។ ទាល់តែក្រោយគេចាប់ជាងដប់នាក់មាន ឆាយ គឹមហ៊ី មាន ឃាង ជួន មានអីៗហ្នឹងទៅ បានខ្ញុំបោះសៀវភៅគណិតវិទ្យាចោលខ្ញុំមកចាប់ផ្ដើមធ្វើបដិវត្តន៍ ។ ខ្សែខ្ញុំពេលនោះទាក់ទងជាមួយនឹង កង សារ៉ន សិស្សកំពង់ធំម្នាក់ដែរ ប៉ុន្តែគេ *ប្រឺមីញ៉េរ ឌឺប្រូម៉ូស្យុង* នៅកំពង់ធំ គេជំនាន់ទីមួយនៃអនុវិទ្យាល័យកំពង់ធំ ។ នេះគឺខ្ញុំជាប់ពីខ្សែនុ៎ងមករហូតមក បានៗមកប្រែក្រោយមកទៅរកខ្សែដើមខ្ញុំវិញ ។

**ស៖** សូមអរគុណ ។ នៅឆ្នាំ១៩៦៩ លោកមានដែលទៅផ្ទះអ្នកស្រី ស៊ូ សាត ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ១៩៦៩ ខ្ញុំអត់ដែលជាន់ផ្ទះ ស៊ូ សាត ទេ ហើយនេះជម្រាបដោយត្រង់ ខ្ញុំទៅផ្ទះ សាត បបួលនៅថ្ងៃ២១ តុលា ឆ្នាំ១៩៧៥-- ឈប់ៗ ៦៧-- ៦៦-- ឈប់--៦៧ ខ្ញុំចូលទៅលាគាត់ទៅធ្វើបដិវត្តន៍ គឺនៅថ្ងៃ២១ តុលា ១៩៦៧ ឯណោះវិញទេ ។

[១០:៥០:៣២]

**ស៖** សូមអរគុណ ។ អ៊ីចឹងឆ្នាំ១៩៦៧ លោកបានទៅផ្ទះ ស៊ូ សាត តើលោកធ្លាប់បានដេកនៅនោះមួយយប់ទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំទៅហ្នឹងល្ងាច ។ ទៅហ្នឹងគឺលា សាត ហើយនិងប្ដីគាត់សារិន-- ស្វាយ សារិន នេះទៅធ្វើបដិវត្តន៍ ពេលនោះអាឡោះអាល័យគ្នាណាស់ ហើយផ្ទះនុ៎ងវាអត់មានគ្រែ អត់មានមុងអីផ្សេងទេ គេចាប់ខ្ញុំបញ្ចូលទៅក្នុងមុងជាមួយនឹងគេហ្នឹង ។ ខ្ញុំហើយ សារិន ប្ដីគេហើយនិងអាកូនតូចរបស់គេហ្នឹង អាញ៉ូច នុ៎ង ហើយបានគេនៅម្ខាង ។ ដេកមួយយប់ទាល់ភ្លឺជាមួយគ្នានៅនុ៎ងទៅ ។

**ស៖** ចុះពេលដេកលើគ្រែគ្នាបីនាក់ ប្អូននាក់និងអាកូនតូចនោះ តើលោកបាននិយាយអីខ្លះទេ?

**ឆ៖** ពេលដេកហ្នឹងអស់និយាយហើយ ។ បើនិយាយៗនៅពេលថ្ងៃដែលអត់បានដេក អ៎! ដែលមិនទាន់ដេកខ្ញុំលាៗទៅផ្ទះ អ៎! ន៎ែ សូមលាគេទៅធ្វើបដិវត្តន៍ចេញចោលតំណែងហើយ ខ្ញុំលាគេ ហើយមានការអាឡោះអាល័យគ្នា ហ្អឺអឺចេះ អ្ហឺអឺចុះ អ៊ាវ អើយ អ៊ាវៗ នៅតែ អ្ហឺ! មិនចប់ហ្នឹងឯង ។

[១០:៥១:៥៥]

**ស៖** ហើយមុននឹងលោករត់ចូលព្រៃនៅឆ្នាំ១៩-- ប្រហែលជា៧៨ តើលោកបានធ្វើថ្វាយបង្គំលាឪពុកម្ដាយលោកឬទេ? បើបានថ្វាយបង្គំលា តើលោកលាឪពុកម្ដាយចូលព្រៃនេះ ដើម្បីតស៊ូ តើលោកតស៊ូចង់បានអ្វី សូមលោកបញ្ជាក់?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ថ្ងៃ២១ ខ្ញុំទៅផ្ទះ សាត ថ្ងៃ២០ ខ្ញុំទៅថ្វាយបង្គំលាមាតាបិតាខ្ញុំ ។ យប់ប្អូនៗវាដេកអស់បានខ្ញុំលាគាត់ ពេលនោះឪពុកខ្ញុំគាត់អាណិតអាសូរខ្ញុំដែរ គាត់យកកថារបស់គាត់មកឲ្យខ្ញុំថ្មីត្បិតតែខ្ញុំមិនជឿកថា មិនជឿអីក៏ដោយក៏ខ្ញុំសុខចិត្តទទួល ថ្វាយបង្គំទទួលកថាហ្នឹងពីគាត់យកមកទុកប្រើ ។ ដូច្នេះ គឺដូចខ្ញុំបានរាយការណ៍ជម្រាបមកហើយ ខ្ញុំចូលបដិវត្តន៍ ខ្ញុំចង់ឲ្យមាតាបិតាខ្ញុំស្រឡាញ់ចូលបដិវត្តន៍ដែរ ។ ដូច្នេះ ពេលចេញទៅធ្វើបដិវត្តន៍ ខ្ញុំចេញទៅថ្វាយបង្គំលាគាត់លាមាតាបិតាទៅធ្វើបដិវត្តន៍ក្នុងគោលបំណងរំដោះជាតិប្រជាជនកម្ពុជាតាមឧត្តមគតិរបស់ខ្ញុំដែលមានកាលនោះ ។

**ស៖** សូមអរគុណ ។ សូមលោកបញ្ជាក់ឡើងវិញនៅចម្លោះឆ្នាំ១៩៧០ មក៧៥ លោកនៅក្នុងតំបន់រំដោះ លោកបានឃើញច្បាស់ថា បក្សកុម្មុយនីស្តកម្ពុជាបានកាប់សម្លាប់មនុស្សជាបណ្ដើរៗហើយតើអ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំឃើញការកាប់សម្លាប់ហ្នឹងជាបណ្ដើរៗមែន ។ ដំបូងឃើញនៅខាងស្អាងកោះធំ តំបន់២៥ ទេ បន្ទាប់មកទៅខាងឯអមលាំងនុំង ដោយគេបញ្ជាឲ្យខ្ញុំជាអ្នកធ្វើការងារនគរបាល នេះមែន ។

**ស៖** សូមអរគុណ ។ ពេលឃើញដូច្នោះ វាពិតជាខុសពីគោលបំណងរបស់លោកកាលពេលថ្វាយបង្គំឪពុកម្ដាយ ដើម្បីធ្វើការតស៊ូ ។ តើអ៊ីចឹងមែនទេ?

**ឆ៖** វាពិតជាខុសហើយ ។

**ស៖** សូមអរគុណ ។ បើលោកឃើញខុសដូច្នោះហើយ ហេតុអ្វីក៏លោកមិនរត់ចេញពីពួកខ្មែរក្រហម?

**ឆ៖** ដូចខ្ញុំបានជម្រាបលោក ដូចខ្ញុំបានជម្រាបអង្គសវនាការ ហើយជម្រាបតាំងពីសម័យស៊ើបអង្កេតម្ល៉េះ ។ ខ្ញុំជឿទាំងស្រុងថា ខ្ញុំអត់បានសម្រេចចាប់អ្នកណាទេ ចាំទទួលតែមនុស្សដែលគេប្រគល់ឲ្យមកសួរចម្លើយ ហើយកម្ទេចចោលឲ្យគេទៅ ។ ឯចំណែកអ្នកទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រគេ ឯចំណែកការងារខ្លះដែលខ្ញុំធ្វើមិនកើត ឧទាហរណ៍ដូចជា រឿងកម្ទេចមនុស្ស សម្លាប់មនុស្សនេះខ្ញុំធ្វើមិនកើតទេ ខាងនោះ ខាងបង ឆាយ គឹមហ៊ី ហៅ ហុក នេះគាត់ទទួលថា ទុកឲ្យវណ្ណៈកសិករគេធ្វើទៅគ្រាន់បើជាងមិត្ត មិត្តចេះតែប្រើគេទៅបានហើយ ។

ដូច្នេះ សរុបមកគេទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ ខ្ញុំនេះមួយ ។ ទីពីរទៀត ទៅរត់ទៅឯណា? នៅតាមផ្លូវគ្រប់ច្រកគេមានរោងយាម គេចាប់នេះម្យ៉ាង ក៏ប៉ុន្តែប្រសិនបើរត់រួចមកដល់ លន់ នល់ រត់មកធ្វើស្អីបើខ្ញុំដឹងថា លន់ នល់ ចាញ់ ។ ខ្ញុំបានជម្រាបអង្គសវនាការហើយថា ខ្ញុំមានការជំពាក់ជំពិនជាមួយនឹងឪពុកមាខ្ញុំ ដែលត្រូវបានក្មួយលោកតា លន់ នល់ ធ្វើជាប្រពន្ធ ។ ខ្ញុំនៅចំពាក់គុណឪពុកមាខ្ញុំ ហើយនិងម្ដាយមីងខ្លាំងណាស់ តែខ្ញុំដឹងថា លន់ នល់ ចាញ់ ។ ខ្ញុំរត់មករកអ្នកចាញ់ធ្វើអី ។ នេះជារឿងពិតដែលខ្ញុំមិនរត់ ។

[១០:៥៦:៣២]

**ស៖** សូមអរគុណ ។ អ៊ីចឹងសូមលោកបញ្ជាក់ឡើងវិញ នៅស-២១ លោកមិនពេញចិត្តនឹងមុខងារជាប្រធានស-២១ ទេ ។ លោកមិនពេញចិត្តទេ តែលោកនៅខិតខំបំពេញការងារដើម្បីរស់ ព្រោះកាលនោះលោកឃើញ អ៊ិន ណាត ហៅ លន ជាប្រធានស-២១ ហើយក្រោយមកក៏ត្រូវបក្សកុម្មុយនីស្តកម្ពុជាចាប់យកមកកម្ទេចនៅស-២១ នេះដែរ ។ លោកក៏ចាប់ផ្ដើមភ័យថា កាលណាដល់វេនលោកហើយបើលោកមិនខិតខំធ្វើការ ក៏អង្គការចាត់តាំងថាលោកជាខ្មាំង លោកក៏ត្រូវតែស្លាប់ តើខ្ញុំនិយាយហ្នឹងលោកឯកភាពនឹងខ្ញុំឬទេ?

**ឆ៖** ច្រកចេញតែមួយដើម្បីរស់មានតែខំធ្វើការងារតាមគេ ។ ដូចខ្ញុំបានជម្រាបអង្គជំនុំជម្រះពីមុនមកហើយ អ្នកខ្លះគេវិភាគថាខ្ញុំនឹងខំធ្វើការហួសពីសេចក្ដីត្រូវការដើម្បីរស់ ។ ខ្ញុំប្រាប់ថា ខ្ញុំបញ្ជាក់ថាមិនមានលក្ខណៈវិនិច្ឆ័យអីដើម្បីកំណត់ថាអ្នកឯងធ្វើប៉ុណ្ណេះ អ្នកឯងបានរស់អ្នកឯងធ្វើប៉ុណ្ណេះ លើសពីនេះទៅទៀតហួស ។ ក្នុងរបប ប៉ុល ពត, ប៉ុល ពត ចាប់អាម្មរណ៍ជានិច្ចអានេះវាក្បត់អញ វាធ្វើអីចឹងវាក្បត់អញៗ ។ ដូច្នេះ យើងខំធ្វើដើម្បីឲ្យបានរស់ម៉្ងៃទៅម៉្ងៃៗ ដូច្នេះគឺរឿងនេះវានៅជាប្រចាំ ។ អើបើនិយាយទៅធម្មតាទេ យើងជាមនុស្សកំសាកហើយ ។ នេះជារឿងពិត ។

[១០:៥៨:៣០]

**ស៖** សូមអរគុណ ។ ថ្ងៃ៧ មករា ១៩៧៩-- សូមទោសថ្ងៃ-- អ៊ីចឹងហើយ ៧ មករា ១៩៧៩ វេលាម៉ោងពីរ លោកចេញពីស-២១ ពេលហ្នឹងលោកមានលទ្ធភាពនឹងរត់ចេញពីពួកខ្មែរក្រហម ដូចលោកមានប្រសាសន៍អំមិញនឹងដែរ ថាដុំមួយដុំមួយដែលវានៅក្នុងស្ពឺយកចេញបានទាល់តែមាស៊ីននោះ វាគាំងឈប់ដើរ អាហ្នឹងបានលួកដៃយកបាន បើវានៅដើរយកវាមិនបានទេ ។ ឥឡូវនេះថ្ងៃ ៧ មករានោះ ត្រូវខ្មែរក្រហមចាញ់ បានសេចក្ដីថា ម៉ាស៊ីនរបស់ខ្មែរក្រហមត្រូវគាំង ហេតុអ្វីក៏លោកមិនរត់គេចចេញពីពួកខ្មែរក្រហម លោកនៅតែរត់តត្រុកតាមពួកខ្មែរក្រហមទៅវិញ? សូមលោកបញ្ជាក់អំពីគំនិតរបស់លោក ។

**ឌ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំគិតថាសក្ខីកម្មដែលអ្នកជំនាញ វ៉ាអ៊ួល ម៉ាកចេនណា លោកមានប្រសាសន៍ម្សិលមិញ អាចឆ្លុះបញ្ចាំងបញ្ហានេះបាន ។ បក្សកុម្មុនីយស្តវៀតណាម ខ្ញុំចោទបញ្ហាសួរថា តើប្រសិនបើជាខ្ញុំរត់ចូលទៅ គេទុកចិត្តខ្ញុំទេ? នេះបញ្ហាមួយធំ ។ បញ្ហាទីពីរ ខ្ញុំមានគ្នីគ្នារាប់រយនាក់ ខ្ញុំរត់ចេញទៅ តើកូនចៅខ្ញុំគេចាប់ខ្ញុំចង ឬយ៉ាងម៉េច? នេះជាបញ្ហាពីរដែលធ្វើឲ្យខ្ញុំមិនប៊ានរត់ នៅតែតត្រុកតទៅទៀត ។ នេះខ្ញុំសូមលើកកត្តាធំៗពីរនេះ យកមករាយការណ៍ជូន ។

**ស៖** សូមអរគុណ ។ កន្លងមកលោកបានលើកដៃសំពះ សូមទោសជនរងគ្រោះ សូមទោសគ្រួសារជនរងគ្រោះចំពោះកំហុសឆ្គងរបស់លោកដែលជាប្រធានស-២១ ប៉ុន្តែជនរងគ្រោះ គ្រួសារជនរងគ្រោះ ថាការសូមទោស សុំខមាទោសរបស់លោកមិនមែនផុសចេញពីចិត្ត ដោយសុទ្ធចិត្តរបស់លោកនោះទេ ។ អ៊ីចឹង លោកអាចបញ្ជាក់ឡើងវិញបានទេ ថាការសូមទោស ការសុំខមាទោសនេះរបស់លោកនេះ វាពិតជាចេញមកដោយសុទ្ធចិត្ត ឬយ៉ាងណា? សូមលោកបញ្ជាក់ ។

**ឌ៖** សូមជម្រាបបញ្ជាក់ជូនលោកមេធាវី! ការអប់រំរបស់បក្សកុម្មុយនីស្តកម្ពុជា ជនទាំងឡាយណាដែលគេចាប់បញ្ជូនទៅស-២១ ជាខ្មាំង ។ ត្រូវតែកម្ទេច ព្រោះជាមនុស្សមានទោស ព្រោះជាមនុស្សប្រឆាំងនឹងគេ ។

នៅពេលដែលខ្ញុំនិយាយថា ខ្ញុំសុំទោសជនរងគ្រោះ សុំទោសគ្រួសារជនរងគ្រោះ រហូតដល់សុំទោសបុគ្គលិករបស់ខ្ញុំ ។ ពេលនុ៎ង ខ្ញុំអត់មានចាត់ទុកអ្នកដែលស្លាប់ទៅទាំងអស់នុ៎ងថាជា ឧក្រិដ្ឋជន ជាជនមានកំហុសត្រូវតែស្លាប់នោះទេ គឺបក្សកុម្មុយនីស្តកម្ពុជារបស់ខ្ញុំនេះវិញទេដែលជាជនឧក្រិដ្ឋ ។ ដូច្នេះកំហុសដែលខ្ញុំធ្វើទៅលើជាតិ ប្រជាជនខ្ញុំ ខ្ញុំត្រូវតែសុំទោស ដោយខានមិនបាន ព្រោះខ្ញុំដឹងខ្លួនថា ខ្ញុំ

ខុស ពិតជាខុស ។ អត់យកអ្វីមកកែប្រែបានទេ គឺខ្ញុំសុំទោសដោយសុទ្ធចិត្ត ។

អ្នកដែលគេមិនព្រមសុំទោសប្រជាជនកម្ពុជា គេនៅតែតាំងខ្លួនថាឧក្រិដ្ឋកម្មរបស់គេជាការត្រឹមត្រូវ ស្នេហាជាតិ អាហ្នឹងវាជារឿងមួយដោយឡែក ។ ដូច្នេះ សូមជាតិប្រជាជន លោកថ្លឹងមើលចុះ តើខ្ញុំសូមទោសដោយសុទ្ធចិត្ត ឬក៏ជាការក្លែងបន្លំ សារជាតិវានៅត្រង់ហ្នឹង ។ សារជាតិនៅហ្នឹង ដែលខ្ញុំទទួលថា ជនដែលស្លាប់ទៅហ្នឹងគ្មានកំហុស គ្មានទោសពៃរ៍។ នេះខ្ញុំសូមទោស ។

ដូច្នេះ ខ្ញុំសូមទោសនេះ វាជារឿងមួយ។ សេចក្ដីសម្រេចរបស់តុលាការជារឿងមួយទៀត ដាច់ដោយឡែកពីគ្នា ។

[១១:០៣:២៩]

**ស៖** សូមអរគុណ ។ បើខ្ញុំចាំមិនច្រឡំទេ ពីម្សិលមិញ ឬក៏ពីម្សិលម៉្ងៃ លោកព្រះរាជអាជ្ញាជាតិបានលើកឡើងថា ការសារភាពរបស់លោក គឺសារភាពបានតែហាសិបភាគរយទេ មានន័យថាលាក់ហាសិបភាគរយ ។ អ៊ីចឹង សូមលោកបញ្ជាក់ជូនអង្គសវនាការមើល តើលោកបានសារភាពមួយរយភាគរយហើយ ឬនៅកន្លងមក?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! រឿងខ្លះដែលចៅក្រមស៊ើបអង្កេតលោកសួរខ្ញុំ ខ្ញុំឆ្លើយ ។ លោកសួរត្រង់ណា ខ្ញុំឆ្លើយត្រង់នុ៎ង ដោយស្មោះអស់ពីចិត្ត ។ នេះជារឿងពិត ។ មកដល់នៅក្នុងអង្គសវនាការនេះ ចៅក្រមនៃអង្គសវនាការក្ដី ព្រះរាជអាជ្ញាក្ដី ឬក៏មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្ដី លោកសួរខ្ញុំថែមទៀត ខ្ញុំឆ្លើយទៀត ។ រឿងអីដែលខ្ញុំថា ខ្ញុំឆ្លើយនឹងចៅក្រមស៊ើបអង្កេតពេញលេញហើយ ខ្ញុំប្រាប់ថា អាហ្នឹងពេញលេញហើយ ។ រឿងអីដែលខ្ញុំនឹកឃើញថែមទៀត សំណួរមកថ្មីទៀត ខ្ញុំឆ្លើយថ្មីទៀត បញ្ហានេះ។ ដូច្នេះខ្ញុំអត់មានប្រាថ្នាលាក់ទេ នេះជារឿងធំ ។ ឧក្រិដ្ឋកម្មដែលយើងធ្វើ យើងត្រូវតែចេញមុខទទួលស្គាល់ ។ ដូចខ្ញុំតែងនិយាយអ៊ីចឹង ដំរីស្លាប់ ពាក្យខ្មែរបុរាណថា “កុំយកចង្អេរទៅបាំង” អ្ហ៊ឺ! ខ្ញុំមិននិយាយអ៊ីចុងទៅទៀត ។ ខ្ញុំថាអស់លោកទាំងឡាយអើយ សូមមេត្តាកុំយកស្លឹកអំពិលពីរសន្លឹកហ្នឹង ទៅបាំងឧក្រិដ្ឋកម្មរបស់លោកនុ៎ង មិនបានទេ ។ ខ្ញុំអត់បាំងទេ ។ ខ្ញុំអត់លាក់ទេ ខ្ញុំនិយាយទាំងអស់ នេះជារឿងពិត ។

**ស៖** អរគុណ ។ ពេលដែល ប៉ុល ពត នៅរស់ ប៉ុល ពត ប្រកាសមិនទទួលស្គាល់ស-២១ ។ តើលោកមានអារម្មណ៍យ៉ាងណា?

**ឆ៖** រឿងនេះ នេះជារឿងទីពីរទៅហើយទេ ។ រឿងទីមួយ កាលខ្ញុំទៅនៅប៉េងកាំង យន់ យ៉ាត ប្រពន្ធ សុន សេន ហ្នឹង គាត់និយាយថា អ្នកជំនាញនៃប្រទេសស៊ុយអែដ គេមកមើលឆ្អឹងខ្មោចហ្នឹង ។ ដល់មកមើលឆ្អឹងខ្មោចហ្នឹង គេសន្មតថា ឆ្អឹងខ្មោចនោះជាឆ្អឹងខ្មោចក្រោយ ៧មករា អីចេះមិនដឹង ។ គេសន្និដ្ឋានអីចឹង ។ ខ្ញុំថា ហ្នឹងជារឿងឈានទៅដើម្បីផ្លាស់ប្តូរប្រវត្តិសាស្ត្រហើយ បក្សកុម្មុយនីស្តកម្ពុជាក៏មានបាតដៃឧក្រិដ្ឋក្នុងរឿងនេះបន្តិប្រវត្តិសាស្ត្រហ្នឹងដែរ ។ នេះដំណើរនៅឯណោះរួចមកហើយ ដល់ក្រោយមកបាន នេត ថាយ៉ូរ នេះ វាទៅប្រាប់ខ្ញុំថា “ប៉ុល ពត បដិសេធថា នៅក្នុងភ្នំពេញកាលដែលគាត់នៅកាន់អំណាច គ្មានស-២១ ទេ” ។ ស្រាប់តែគាត់ទៅដល់ព្រំដែនថៃឯណោះ បានឃើញកាសែតថៃ វាចុះ ថានៅភ្នំពេញមានស-២១ ។

ដូច្នេះ ប៉ុល ពត និយាយបែបនេះបានន័យថា វៀតណាមជាអ្នកប្រឌិតស-២១ នេះឡើង ។ ខ្ញុំទទួលមិនបានទេ ។ ជម្រាបប្រសាសន៍ដោយត្រង់ ប្រវត្តិសាស្ត្រកម្ពុជាខ្ញុំចេះដែរ ខ្ញុំទទួលមិនបានទេ រឿងហ្នឹងជាសំខាន់មួយ ។ នេះគឺសូមជម្រាបបញ្ជាក់ដោយស្មោះត្រង់ទៅ ។ ខ្ញុំប្រធានមន្ទីរ ស-២១ អ៊ំ! ថាខ្ញុំយួនបង្កើតម៉េចកើត ខ្ញុំអត់ដែរចូលបក្សកុម្មុយនីស្តវៀតណាមផង ។

**ស៖** សូមអរគុណ ហើយសំណួរខ្ញុំជាទីបញ្ចប់ សូមឲ្យលោកបញ្ជាក់ឡើងវិញ ក្រោយពីលោកបានយល់ដឹងនូវទំព័រប្រវត្តិសាស្ត្រថ្មី ក្រោយពីលោកបានទទួលស្គាល់នូវកំហុសរបស់លោក ក្រោយពីលោកបានឃើញ យល់ឃើញថា អ្នកដែលស្លាប់ទៅ គឺស្លាប់ដោយអយុត្តិធម៌គ្មានកំហុសអ្វីទាំងអស់ ។ តើលោកមានការសោកស្តាយចំពោះឧក្រិដ្ឋកម្មទាំងនោះយ៉ាងណាខ្លះ? សូមលោកបញ្ជាក់ឡើងវិញ ។

[១១:០៨:៣៥]

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំបាននិយាយហើយថា ខ្ញុំធ្វើបដិវត្តន៍ដើម្បីរំដោះជាតិ ប្រជាជនខ្ញុំ សងគុណជាតិ ប្រជាជនខ្ញុំ សងគុណមាតាបិតាខ្ញុំ ដែលខំបង្កើតខ្ញុំ ហើយនិងចិញ្ចឹមបីបាច់ថែរក្សាខ្ញុំ ។ តែបែរជាមកធ្លាក់ឲ្យជាតិប្រជាជន អន្តរាយរកទីបំផុតគ្មាន ។ គ្រាន់តែអាយុជីវិតមនុស្សបាត់បង់រហូតទៅជាងមួយលាននាក់ ។ សេដ្ឋកិច្ចរលំរលាយ វប្បធម៌ខ្ទេចខ្ទី សព្វបែបយ៉ាងខ្ទេចទាំងអស់ ។ តើឲ្យខ្ញុំឆ្លើយទម្លាក់កំហុសទៅលើអ្នកណា ខ្ញុំកើតមកជាកូនប្រុស កើតមកជាអ្នកស្រលាញ់យុត្តិធម៌ ខ្ញុំឆ្លើយដាក់ទៅលើអ្នកណាមិនកើតទេ ទទួលស្គាល់ហើយថានេះ គឺជាស្នាដៃរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលក្នុងនោះមាន ខ្ញុំជាសមាជិកមួយរូប ។

ដូច្នេះហើយបានជាខ្ញុំនិយាយថា ឧក្រិដ្ឋកម្មទាំងអស់នៅកម្ពុជា ខ្ញុំសូមទទួលខុសត្រូវខាងផ្លូវចិត្ត ជាតិប្រជាជនខ្ញុំ លោកថ្កោលទោសយ៉ាងម៉េច? លោកចង្អុលទោស មុខខ្ញុំយ៉ាងម៉េច? លោកថាយ៉ាងម៉េច ថាចុះ ។ ខ្ញុំទទួលដោយឱនលំទោន ហើយដោយស្មោះ ។

ដោយឡែក ឧក្រិដ្ឋកម្មនៅស-២១ ដែលខ្ញុំជាប្រធាន ខ្ញុំទទួលតែម្នាក់ឯង អត់មានទាក់ទងនឹងកូនចៅណាម្នាក់ទេ ទាំងខាងផ្លូវច្បាប់ ទាំងខាងផ្លូវចិត្ត សុំទោសជនរងគ្រោះ សុំទោសក្រុមគ្រួសារជនរងគ្រោះ ទទួលសេចក្តីវិនិច្ឆ័យរបស់អង្គជំនុំជម្រះដោយស្មោះ ។ នេះជាការប្តេជ្ញាចិត្តរបស់ខ្ញុំ ចំពោះមុខប្រវត្តិសាស្ត្រជាតិ ដែលខ្ញុំបានចូលរួមទៅក្នុងអំពើខុសឆ្គងរួមមកហើយនោះ ។ នេះជាបញ្ហាធំ ហើយនៅចុងបញ្ចប់ខ្ញុំបានសួរដែរ អ្នកជំនាញខាងចិត្តសាស្ត្រ ខ្ញុំសួរថាតើៗត្រូវឲ្យខ្ញុំធ្វើដូចម្តេច ដើម្បីឲ្យមនុស្សជាតិ លោកទទួលខ្ញុំ ស្គាល់ខ្ញុំជាមនុស្សម្នាឡើងវិញ ។ ខ្ញុំចោទបញ្ហានេះ ។ ខ្ញុំចោទបញ្ហានេះជាប់ជានិច្ច។ នេះសូមជម្រាបបញ្ជាក់ជូនប៉ុណ្ណោះ ។

[១១:១១:២៦]

**លោក ការ សាវុត្ថ៖**

សូមអរគុណ ។ សូមលោកប្រធានមេត្តាអនុញ្ញាតឲ្យលោកមេធាវីអន្តរជាតិការពារអន្តរជាតិមេត្តាសួរបន្ត ។ សូមអគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីអន្តរជាតិ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកប្រធាន ។

**ស៖** ឌុច ឥឡូវនេះយើងចូលមកដល់ជិតដល់ចុងបញ្ចប់នៃការជំនុំជម្រះនេះហើយ ។ គឺជាការបញ្ចប់នៃការផ្តល់សក្ខីកម្ម សេចក្តីថ្លែងការណ៍របស់លោក មេធាវីរបស់លោកដូច ដែលលោកបានយល់ហើយ យើងចង់ផ្តល់ឱកាសជូនលោកដើម្បីឲ្យផ្តល់នូវសេចក្តីពន្យល់ចុងក្រោយ ។ លោកដឹងហើយហើយលោកក៏បានយល់ច្បាស់ដែរអំពីសំណួរមួយចំនួនរបស់សហព្រះរាជអាជ្ញានោះ ។ ហើយនៅមានការសង្ស័យមួយចំនួននៅឡើយដែលទាក់ទងទៅនឹងការទទួលស្គាល់នូវពិរុទ្ធភាពរបស់លោក ដែលក្រៅពីអ្វីដែលលោកបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍របស់លោក ។ ប៉ុន្តែ តើគេនៅមានសង្ស័យអំពីការសូមខមាទោសរបស់លោក គឺមិនមែនដោយស្មោះត្រង់ទេ ។ ដូច្នេះ គឺថាមានបញ្ហាពីរ ឬបីប៉ុណ្ណោះ ប៉ុន្តែ

លោកបាននិយាយមួយច្រើនរួចមកហើយ ។

ទាក់ទងទៅនឹងការទទួលស្គាល់ ខ្ញុំជឿថាខ្ញុំអាចស្នើជូនលោកថាយើងអានជាមួយគ្នាឡើងវិញ នូវអ្វីដែលសហព្រះរាជអាជ្ញារំពឹងចង់បានពីលោកពេលនោះ ។ បន្ទាប់មក ខ្ញុំនឹងសួរសំណួរឲ្យលោកឆ្លើយចម្លើយថា "បាទ ឬ ទេ" ទៅនឹងសំណួរទាំងនោះ ។ ដោយសារថាលោកដឹងអង្គហេតុនៅក្នុងគម្ពីរ ឬក៏នៅក្នុងសៀវភៅដែលលោកនិយាយថា "បើបាទ ប្រាកដជាបាទ បើទេ ប្រាកដជាទេ" ។ ដូច្នេះ ឌុច នៅក្នុងសេចក្តីថ្លែងការណ៍ដំបូងរបស់សហព្រះរាជអាជ្ញានោះ នៅថ្ងៃទី៣១ មីនា ឆ្នាំ២០០៩ នោះ នៅក្នុងទំព័រ៦៩ នៃអត្ថបទភាសាបារាំង បន្ទាត់២២ សហព្រះរាជអាជ្ញាអន្តរជាតិ លោក រ៉ូបឺត ពេទីត បាននិយាយដូចខាងក្រោមនេះ៖

ដូច្នេះប្រសិនបើនៅចុងបញ្ចប់នៃការជំនុំជម្រះរឿងក្តីនេះ យើងត្រូវតែបង្ហាញឲ្យឃើញការពិតនូវអ្វីដែលបានកើតឡើងនៅស-២១ ។ ខ្ញុំត្រូវ-- សូមគោរពបញ្ជាក់ថា យើងនឹងត្រូវប្រឈមមុខជាមួយជនជាប់ចោទ ជាមួយអង្គហេតុនានានៃរឿងក្តីឲ្យបានត្រឹមត្រូវតាមសមហេតុផល និងសេចក្តីសន្និដ្ឋានដែលត្រូវទាញចេញពីបញ្ហាទាំងនេះ ។ ក្រៅពីរូបភាពមួយចំនួននៃមនុស្សមួយចំនួនដែលធ្វើឡើងប្រឆាំងនឹងឆន្ទៈរបស់គាត់ គឺការជំនុំជម្រះ ដែលព័ត៌មានទាំងអស់ដែលផ្តល់ជូននៅក្នុងការជំនុំជម្រះនោះ គឺមិនបានដឹងអំពីអំពើឃោរឃៅ ដែលត្រូវបានប្រព្រឹត្តឡើងនៅជុំវិញគាត់ដោយកូនចៅរបស់គាត់ នៅពេលដែលគាត់រវល់ក្នុងការងាររបស់គាត់នៅក្នុងមន្ទីរ ។

ដូច្នេះគាត់បានកត់សម្គាល់ចំណុចមួយ គឺថាគាត់ ជាសម្តីរបស់ រ៉ូបឺត ពេទីត៖ "តាមពិត ជាក់ស្តែងហ្នឹង គាត់ជាមនុស្សមួយរូប ដែលពេញចិត្ត និងការទុកចិត្តមេរបស់ខ្លួន ហើយក៏បានអនុវត្តការងារដោយស្មោះត្រង់ ដោយយកចិត្តទុកដាក់ ធ្វើការចោទប្រកាន់នូវជនមួយចំនួនរបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងមនុស្សមួយចំនួននៅស-២១ ។ ដូច្នេះ គាត់ទទួលស្គាល់ថា នៅពេលនោះ ហើយមានតែកាលនោះប៉ុណ្ណោះទេ ដែលជនជាប់ចោទអាចអះអាងឲ្យស្មោះត្រង់អំពីការសារភាពចំពោះបទឧក្រិដ្ឋរបស់គាត់ ហើយទទួលបានផលនៃការទទួលស្គាល់នេះ ។

ឌុច ឥឡូវនេះយើងដល់ពេលចុងបញ្ចប់នៃសវនាការនេះហើយ ។ ហើយទាក់ទងទៅនឹងគំនិតនេះ ខ្ញុំមានតែមួយដែលសួរទៅលោក ។ តើលោកទទួលស្គាល់ថា ក្នុងការពិតលោកធ្លាប់បានជាមនុស្សម្នាក់ដែលពេញចិត្តលើការទុករបស់មេរបស់លោកក្នុងការបំពេញការងារដោយស្មោះត្រង់ ដោយយកចិត្តទុកដាក់នូវការចោទប្រកាន់ ដែលធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងពលរដ្ឋកម្ពុជានៅស-២១

តើលោកទទួលស្គាល់ហេតុការណ៍នេះដែរឬទេ? បាទ ឬ ទេ?

**ឆ៖** បាទ, ខ្ញុំទទួលស្គាល់ទាំងស្រុង ។

[១១:១៩:០១]

**ស៖** លោកសហព្រះរាជអាជ្ញា! ឥឡូវនេះយើងចូលដល់ចុងបញ្ចប់នៃដំណើរការនីតិវិធីហើយ ។ ខ្ញុំមិនមានចម្ងល់អ្វីទេថា លោកនឹងមានលទ្ធភាពនឹងទាញសេចក្ដីសន្និដ្ឋានជាផលវិបាក ដែលចេញមកពីការទទួលសារភាពនៃពិរុទ្ធភាពនេះ ។

ឌុច ពីម្សិលមិញនៅក្នុងថ្លែងការណ៍របស់លោក ស្ដេហ្វិន ហាស្សែល បញ្ហាលោក អាល់ប៊ីត ស្ពែរ បានលើកឡើង ដែលគាត់នោះ គឺជាមនុស្សម្នាក់នៅក្នុងប្រឈមមុខការជំនុំជម្រះនៅតុលាការនូរីមប៊ឺក ។ ដូចដែលលោកបានរងការជំនុំជម្រះនោះដែរ ។ លោក អាល់ប៊ីត ស្ពែរ ក៏បានទទួលស្គាល់ពិរុទ្ធរបស់គាត់មុនពេលនឹងជំនុំជម្រះរបស់គាត់ចប់នោះដែរ ។

បន្ទាប់ពីនោះមក សហព្រះរាជអាជ្ញាមួយក្នុងចំណោមនោះ គឺឈ្មោះ ហិនរី យើង ក៏បានទទួលឱ្យមកផ្ដល់សក្ខីកម្មក្នុងរឿងក្ដីរបស់លោកដែរ ហើយលោក ហិនរី យើង ក៏បានទៅជួបជាមួយលោក អាល់ប៊ីត ស្ពែរ ជាញឹកញាប់នៅពេលដែលគេវត្តមាននៅក្នុងរឿងក្ដីនោះ ។ គេបានជជែកគ្នាជាច្រើនពីបញ្ហារឿងក្ដី ហើយគេបានជួបគ្នាជាញឹកញាប់ក្រោយពេលដែលលោក អាល់ប៊ីត ស្ពែរ ត្រូវបានគេដោះលែង ។ លោក ហិនរី យើង ក៏បានសរសេរនូវអត្ថបទស្នាដៃមួយចំនួន ដែលគាត់ចង់ចែករំលែកជូនអង្គជំនុំជម្រះនេះ ។

ហើយខ្ញុំមានសំណួរមួយជូនលោក ឌុច ។ ប្រសិនបើលោក ស្ទីត ឬលោកស្រី ជា លាង ចង់ជួបជាមួយលោកនៅមន្ទីរឃុំខ្លួនរបស់លោក តើលោកមានឆន្ទៈថានឹងនិយាយជាមួយពួកគាត់ដែរ ឬទេ?

**ឆ៖** ឱ្យតែលោកមេធាវី (សូមទោស) ឱ្យតែលោកព្រះរាជអាជ្ញាទាំងអស់ មិនថាលោកណាម្នាក់ទេ បើលោកស្ម័គ្រចិត្តអញ្ជើញទៅ ខ្ញុំអរគុណ ហើយទទួលលោកដោយស្មោះ ។ លោកចង់សួរបញ្ជាក់ខ្ញុំរឿងអី ខ្ញុំជម្រាបថែមទៀតដោយស្មោះ ។

**ស៖** ឥឡូវនេះយើងចូលទៅដល់ចំណុចមួយ គឺសំណួរនិយាយអំពីភាពស្មោះត្រង់ ឬក៏ភាពសុទ្ធចិត្តដែលលោកថ្លែងនៅក្នុងខមាទោសនោះ ។ សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយនោះដែលយើងបានអានជាច្រើនដង ម្ដងហើយម្ដងទៀតបានបញ្ជាក់ថា លោកពិតជាបានសម្ដែងនូវការខមាទោស ឬក៏វិប្បដិសារីនៅក្នុងដំណាក់ស៊ើបអង្កេតចំពោះជនរងគ្រោះ ហើយនិងបញ្ជាក់ផងដែរថា

សហការជាមួយសហចៅក្រមនៅក្នុងដំណាក់ស៊ើបអង្កេតទាំងស្រុង ។

ហើយក្នុងចំណោមបញ្ហាផ្សេងៗទៀតនោះ លោកបានទទួលស្គាល់ ដើម្បីចូលរួមក្នុងការសម្តែងឡើងវិញនៅជើងឯក ហើយនិងនៅស-២១ ផងដែរ ។

[១១:២៣:១៤]

មេធាវីរបស់លោកទាំងពីររូប យើងក៏បានទៅជួបលោកច្រើនដង ហើយជួបលោក-- ហើយសួរថាតើលោកមានចេតនាថា ទៅនឹងទៅមើលជើងឯក និង ស-២១ ឡើងវិញទេ? លោកក៏ប្រាប់យើងថា ខ្ញុំត្រៀមខ្លួនជានិច្ចនឹងទៅ ។

ដូច្នេះហើយនៅកាលនោះមេធាវីទាំងពីររូបរបស់លោក ក៏បានទាក់ទងទៅសហចៅក្រមស៊ើបអង្កេត ហើយប្រាប់ពួកគាត់ថា ប្រសិនបើលោកចង់អនុវត្តនូវការសម្តែងឡើងវិញ ជនជាប់ចោទមានចេតនាថានឹងធ្វើដូច្នោះ ស្ម័គ្រចិត្តថានឹងធ្វើដូច្នោះ ។

ហើយនិងមានការរៀបចំឲ្យមានការសម្តែងឡើងវិញនោះ ជាលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ដែលជនជាប់ចោទបានត្រឡប់ទៅទីកន្លែង ដែលជាកន្លែងខ្លួនគាត់បានប្រព្រឹត្តបទល្មើស ។ គឺជាលើកទីមួយគត់ដែលលោកខ្លួនឯងបានត្រឡប់ទៅកន្លែងកើតហេតុនោះ ដែលថាលោកមិនមែនជាប្រធាននោះតទៅទៀតទេ ។ ប៉ុន្តែ នៅក្នុងចំណោមឆ្មាំគុកពីរនាក់ នៅក្នុងចំណោមសហព្រះរាជអាជ្ញា ប៉ុន្តែលោកបានសម្រេចថា ទៅជើងឯក ហើយនិងទៅស-២១ ។

សំណួរខ្ញុំចំពោះលោក លោក ឌុច ខ្ញុំនិយាយទៅកាន់មនុស្សជាបុរសមួយរូប តើលោកយល់ដូចម្តេច ឬក៏មានអារម្មណ៍ដូចម្តេចនៅខែកុម្ភៈព្រឹក ២០០៨ នោះ? សូមប្រាប់យើថា តើៗក្នុងការចិត្ត ក្នុងបេះដូងរបស់លោកគិតដូចម្តេចនៅពេលដែលយើងទាំងអស់គ្នាទៅដល់ជើងឯកនោះ? សូមប្រាប់យើងអំពីអារម្មណ៍ខាងក្នុងរបស់លោក នៅកាលនោះ? សូមអញ្ជើញ ។

[១១:២៥:៣៧]

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ជើងនេះ កាលដែលខ្ញុំនៅធ្វើជាប្រធានមន្ទីរស-២១ ខ្ញុំចៀសជាអតិបរមាថានឹងមិនទៅ ប៉ុន្តែចៀសវាមិនរួចតម្រូវឲ្យទៅម្តង ។ ខ្ញុំទៅពេលនោះមិនមែនក្នុងបំណងបង្ហាញថាខ្ញុំជាមនុស្សមានអំណាចទៅលើបុគ្គលអ្នកស្លាប់ទៅនោះទេ ។ ក៏ប៉ុន្តែទៅបង្គប់កិច្ចព្រោះមេប្រើដល់ទៅបីដងហើយ តឿនបីដងហើយបានខ្ញុំទៅ ។

ដោយឡែកខ្ញុំទៅលើកទីពីរ ក្នុងដំណើរការដែលសហចៅក្រមស៊ើបអង្កេតលោកនាំទៅ ។ ខ្ញុំមិន

ដឹងទេ ទើបនឹងដឹងថ្ងៃនេះថា ជាលើកទីមួយដែលឧក្រិដ្ឋជនម្នាក់ ជាដំបូងទៅមើលកន្លែងឧក្រិដ្ឋកម្មដែលខ្លួនបានបញ្ជាឲ្យគេសម្លាប់មនុស្ស ។ នៅពេលដែលខ្ញុំសម្រេចចិត្តនេះ ខ្ញុំនឹកឃើញដល់វិញ្ញាណក្ខន្ធមួយម៉ឺននាក់ជាង ។ ខ្ញុំនឹកឃើញដល់ជីវិតកុមារ ដែលគេសម្លាប់ ហើយអាចសម្លាប់ដោយវិធីមួយ គួរឲ្យខ្ពើមរអើមបំផុត គឺចាប់ជើងគ្នាបោកនឹងក្បាលទៅនឹងគល់ឈើ ។

ខ្ញុំតាំងចិត្តថាត្រូវតែទៅ ។ ទៅដើម្បីលុតជង្គង់ ថ្វាយបង្គំ សូមទោសវិញ្ញាណក្ខន្ធទាំងអស់នោះ។ ហើយក៏ទៅដើម្បីអធិដ្ឋានចំពោះវិញ្ញាណក្ខន្ធអ្នកទាំងអស់នោះ ក្នុងឋានៈខ្ញុំជាគ្រីស្ទសៀនមួយរូប។ ដូច្នេះខ្ញុំទៅនេះក្នុងអារម្មណ៍បែបនេះ សកម្មភាពខ្ញុំដែលធ្វើនៅទីនេះក៏នៅក្នុងអារម្មណ៍បែបនេះ ។

ខ្ញុំសូមបញ្ចប់អំពីអារម្មណ៍របស់ខ្ញុំដែលមាននៅពេលដែលខ្ញុំទៅជើងឯកប៉ុណ្ណេះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានជាទីគោរព! ចំពោះសំណួរបន្តទៀត ខ្ញុំចង់ឲ្យធ្វើការបញ្ចាំងនូវដំណាកស្រង់ចេញពីខ្សែរូបភាពវីដេអូសម្តែងឡើងវិញតាមរយៈអេក្រង់របស់យើង ។ អ៊ីចឹង ខ្ញុំសូមអនុញ្ញាតលោកប្រធានឲ្យអង្គភាពខាងសោតទស្សន៍ បង្ហាញនូវដំណាកស្រង់នៅក្នុងខ្សែវីដេអូ គឺខ្សែវីដេអូលេខ D48/2 ដែលនៅចំណុចចុងក្រោយនៃការសម្តែងឡើងវិញ ។ អ៊ីចឹងសូមឲ្យអនុញ្ញាតបញ្ចាំងទៅលើចំណុចខ្សែវីដេអូនេះ។ នៅចុងការសម្តែងឡើងវិញនៅមន្ទីរស-២១ នៅពេលនោះ ឌុច ស្នើសុំឲ្យគាត់អនុញ្ញាតអាននូវសេចក្តីថ្លែងការណ៍របស់គាត់ជូនជនរងគ្រោះនៅកន្លែងនោះតែម្តង ដោយនៅពេលនោះមានវត្តមានរបស់ភាគីចូលរួម ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានឲ្យធ្វើការបញ្ចាំងនូវខ្សែភាពយន្តដកស្រង់នៅត្រង់ចំណុចចុងក្រោយដែលលោកជនជាប់ចោទគាត់បានធ្វើសេចក្តីថ្លែងការណ៍។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វីលៀម ស្មីត៖**

ខ្ញុំហាក់ដូចជាមិនយល់ច្បាស់ពីគោលបំណងនៃការចាក់ផ្សាយរូបភាពវីដេអូនោះទេ ។ យើងបានធ្វើម្តងហើយ ដូច្នេះហើយគឺការបង្ហាញនូវភស្តុតាងនោះ គឺយើងគួរតែបង្ហាញនៅក្នុងដំណាក់កាលសន្និដ្ឋានបញ្ចប់នោះទេ ។ ដូច្នេះហើយខ្ញុំមិនយល់អំពីគោលបំណងនៃការបញ្ចាំងខ្សែវីដេអូនោះទេ ហើយខ្ញុំមិនដឹងថាតើសំណួររបស់គាត់ ចង់សួរពាក់ព័ន្ធយ៉ាងម៉េចទៅនឹងខ្សែវីដេអូដែលគាត់ចង់បញ្ចាំងនោះ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកសហព្រះរាជអាជ្ញា! ខ្ញុំដឹងថាសហសេវិកសហព្រះរាជអាជ្ញានេះ មិនបានចូលរួមនៅក្នុងសវនាការគ្រប់ដំណាក់កាលនោះទេ ។ ដូច្នេះហើយគាត់ប្រហែលជាមិនយល់ និងដឹងអំពីចំណុចដែលយើងចង់បញ្ចាំងនៅពេលនេះ ដែលយើងមិនបានបង្ហាញកាលពីលើកមុន ។ ហើយខ្ញុំមិនដឹងថាតើលោកអាចរារាំងខ្ញុំយ៉ាងម៉េច ដែលយើងចង់បង្ហាញខ្សែវីដេអូ ភស្តុតាងដែលមានលក្ខណៈល្អនៅទីនេះសម្រាប់តុលាការ ។ ដូច្នេះហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញទៅលើខ្សែវីដេអូនេះនៅពេលដែលយើងសម្តែងឡើងវិញ ។ ដូច្នេះ ហើយខ្ញុំយល់ឃើញថា វាមិនមានការប៉ះពាល់ទៅដល់ខាងសហព្រះរាជអាជ្ញានោះទេ ប្រសិនបើយើងបញ្ចាំងទៅលើខ្សែវីដេអូនេះ ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៤:១៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតឲ្យបញ្ចាំងតាមការស្នើសុំរបស់មេធាវីការពារ ។ មន្ត្រីតុលាការរៀបចំចាត់ចែងដាក់បញ្ចាំងនូវវីដេអូ D48/2 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ដើម្បីបញ្ជាក់ទៅលើខ្សែវីដេអូនេះខ្ញុំសូមលើកឡើងថា នៅពេលដែលយើងបញ្ចាំងខ្សែវីដេអូនេះពីមុនគឺយើងបង្ហាញនូវខ្សែខាងដើមនៅក្នុងខ្សែវីដេអូ ដែលនៅពេលនោះជនជាប់ចោទបានស្នើសុំអានទៅលើអត្ថបទសេចក្តីថ្លែងការណ៍នោះ ប៉ុន្តែនៅពេលនោះជនជាប់ចោទគាត់ឈប់ ដោយសារតែនៅពេលនោះគាត់រំជួលអារម្មណ៍ហើយយំ ។ ហើយនៅពេលនេះគឺយើងសូមបញ្ចាំងវគ្គចុងក្រោយនៅក្នុងការថតការសម្តែងឡើងវិញដែលជនជាប់ចោទគាត់ចង់ គាត់បានថ្លែងសេចក្តីថ្លែងការណ៍របស់គាត់នៅដំណាក់កាលនោះ ។ ដូច្នេះហើយ ខ្ញុំមានបំណងសូមឲ្យលោកប្រធានបញ្ចាំងទៅលើចំណុចនេះ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ខាងផ្នែកខាងសោតទស្សន៍យល់ហើយ គឺឲ្យបញ្ចាំងនៅផ្នែកខាងក្រោយតាមសំណើនេះ គឺផ្នែកខាងក្រោយនៃវីដេអូ D48/2 ។

*(ផ្នែកខាងសោតទស្សន៍រៀបចំបញ្ចាំងខ្សែវីដេអូ)*

[១១:៣៧:៣៦]

[បញ្ចាំងខ្សែវីដេអូ D48/2 ៖

**លោក កាំង ហ្គេកអ៊ាវ៖** លោកចៅក្រមទាំងពីរជាទីគោរព! លោកនិងលោកស្រីសហព្រះរាជអាជ្ញាជាទីគោរព! ខ្ញុំរន្ធត់ក្នុងចិត្តឥតឧបមា នៅពេលដែលបានឈានជើងចូលមកដល់ទីនេះ ហើយបានឃើញសភាពការណ៍ចាស់ ដែលជាសភាពការណ៍គួរឲ្យខ្លោចផ្សាបំផុតសម្រាប់ជាតិប្រជាជនខ្ញុំ ក៏ដូចជាសម្រាប់រូបខ្ញុំដែរ ។ ទីមួយ ខ្ញុំនឹកទៅដល់ជនរងគ្រោះដ៏អភ័ព្វ និងក្រុមគ្រួសាររបស់គេ ។ គេទាំងឡាយបានរងទុក្ខវេទនា រងទារុណកម្ម រងការប្រមាថមើលងាយដ៏សែនមហាអមនុស្សធម៌រាប់មិនអស់ មុននឹងបាត់បង់ជីវិតរលត់សង្ខារទៅ ។ ខ្ញុំមានវិប្បដិសារីជ្រាលជ្រៅដែលមិនអាចថ្លាថ្លែងបាន គឺវិប្បដិសារីដែលសុខចិត្តឱនក្បាលទទួលការជំនុំជម្រះតែម្នាក់ឯងក្នុងក្របខ័ណ្ឌស-២១ ហើយប្តេជ្ញាចិត្តយ៉ាងមុតមាំថានឹងធ្វើអ្វីៗទាំងអស់ ដើម្បីឲ្យជាតិប្រជាជនខ្ញុំ និងជនរងគ្រោះ និងក្រុមគ្រួសាររបស់គេបានស្គាល់នូវពន្លឺយុត្តិធម៌ ។ ព្រមជាមួយនេះ ខ្ញុំក៏មានការសោកស្តាយបំផុតចំពោះបុគ្គលិកទាំងអស់របស់ស-២១ ដែលត្រូវបានគេចាប់បង្ខំឲ្យបំពេញភារកិច្ចជាមួយខ្ញុំ គឺភារកិច្ចដែលសាមីខ្លួនរបស់គេស្អប់ខ្ពើម ដែលមាតាបិតារបស់គេស្អប់ខ្ពើម ហើយក្នុងនោះក៏មានបុគ្គលិកមួយចំនួនបានធ្លាក់ខ្លួនរងគ្រោះថ្នាក់នៅទីនេះឯងតែម្តង ។

រឿងអស់នេះ ខ្ញុំនឹកឃើញពេលណា ខ្ញុំខ្លោចផ្សាពេលនោះ ។ ខ្ញុំមានការសោកស្តាយដោយស្មោះ ដោយបានសុខចិត្តចុះចាញ់ទស្សនៈរបស់គេ និងដោយបានទទួលយកភារកិច្ចឧក្រិដ្ឋ ដែលគេប្រគល់ឲ្យខ្ញុំ ។ សកម្មភាពរបស់ខ្ញុំ ពិតជាគួចចូលទៅក្នុងចរន្តមួយដែលបាននាំមកនូវគ្រោះមហន្តរាយធ្ងន់ធ្ងររ៉ាំរ៉ៃដល់ជាតិប្រជាជនខ្ញុំ ។ នេះហើយជាបញ្ហាដែលខ្ញុំនៅតែនឹកឃើញជានិច្ច នឹកមិនភ្លេចសោះ នឹកឡើងណាដំបូងខ្ញុំខឹងនឹងក្បាលម៉ាស៊ីនដឹកនាំបក្ស ដែលបានប្រើគ្រប់មធ្យោបាយអូសទាញចលនានេះ ដែលទៅតាមផ្លូវសោកនាដកម្មទាំងស្រុងនិងដាច់ខាត ។ បន្ទាប់មក ខ្ញុំខឹងនឹងរូបខ្ញុំខ្លួនឯង ដែលសុខចិត្តចុះចាញ់ទស្សនៈរបស់គេ ម្ល៉ោះហើយគោរពបទបញ្ជាឧក្រិដ្ឋរបស់គេទាំងងងឹតងងល់ ។ នេះហើយជាគន្លឹះដែលនាំឲ្យខ្ញុំទទួលស្គាល់ ដោយខានមិនបានថា ក្នុងឋានៈខ្ញុំជាប្រធានស-២១ បានរួមចំណែកក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងក្របខ័ណ្ឌនៃស-២១ ទាំងមូល ។

លោកចៅក្រមទាំងពីរជាទីគោរព! លោក និងលោកស្រីសហព្រះរាជអាជ្ញាជាទីគោរព! ខ្ញុំសូមគោរពអរគុណលោកដែលបាននាំខ្ញុំមកដល់ទីនេះ ។ សូមលោកទាំងបួនអនុញ្ញាតឲ្យខ្ញុំសុំទោសជនរងគ្រោះចំពោះទុក្ខវេទនា។

***លោក ការ សាវុត្ថ៖*** *គាត់អានលែងកើត ។*

***លោក ម៉ាសែល ឡឺម៉ុងដ៍៖*** *បើអ៊ីចឹងបញ្ចប់ប៉ុណ្ណឹងហើយបើសិនជា-- អានេះគឺឯកសារហ្នឹងអាចបញ្ចូលនៅក្នុងសំណុំរឿង ហើយភាគីទាំងអស់អាចមើលបាន ។*

***លោក កាំង ហ្គេកអ៊ាវ៖*** *ឲ្យខ្ញុំសូមទោសជនរងគ្រោះ ចំពោះទុក្ខវេទនាដ៏មហាខ្លោចផ្សាទាំងប៉ុន្មាន ដែលគេបានទទួលរងនៅទីនេះ រហូតដល់ថ្ងៃបាត់បង់ជីវិត ឬរហូតដល់ថ្ងៃ៧ មករា ១៩៧៩ ។ ឲ្យខ្ញុំសុំទោសក្រុមគ្រួសារជនរងគ្រោះ ដែលបានរស់នៅក្នុងទុក្ខសោកយ៉ាងក្រៃគ្រា ដោយបាត់បង់បុគ្គលជាទីស្រឡាញ់របស់ខ្លួនចំនួន៣៣ឆ្នាំហើយ ហើយមិនទាន់បានទទួលពន្លឺយុត្តិធម៌នៅឡើយ ។ ខ្ញុំដឹងហើយថាវិប្បដិសារីរបស់ខ្ញុំ ទោះបីចុកចាប់យ៉ាងណាក៏ដោយ ក៏នៅតែជាទឹកមួយដំណក់ក្នុងមហាសាគរធំធេង និងជ្រាលជ្រៅនៃទុក្ខវេទនាដ៏សែនខ្លោចផ្សារបស់ជនរងគ្រោះនិងក្រុមគ្រួសារ ។ ខ្ញុំសូមលោកចៅក្រម លោក និងលោកស្រីព្រះរាជអាជ្ញាដែលជាអ្នកស្វែងរកយុត្តិធម៌ជូនជនទាំងអស់ខាងលើនេះ អនុញ្ញាតឲ្យខ្ញុំចូលសុំទោសគេទាំងឡាយនោះ ដោយស្មារតីលំឱនបំផុត និងដោយវិប្បដិសារីចុកចាប់យ៉ាងក្រៃគ្រា ។ សូមលោកមេត្តាទុកទ្វារនេះឲ្យនៅចំហជានិច្ច ។ ពេញមួយថ្ងៃហើយដែលខ្ញុំបានទៅមើលស្ថានទីនោះ ដូច្នេះខ្ញុំសូមអរគុណលោកទាំងប្អូនដែលបាននាំខ្ញុំមកដល់ទីនេះ ហើយបានឃើញមុខជនរងគ្រោះជាដំបូង ហើយខ្ញុំសូមទោស ។*

***លោក ជុំ ម៉ី៖*** *ខ្ញុំសុំមានមតិបន្តិចបានទេ?*

***ឆ្លើយ៖*** *ខ្លីៗបំផុត ។*

***លោក ជុំ ម៉ី៖*** *ខ្ញុំសូមគោរពលោកចៅក្រម សូមគោរពលោកព្រះរាជអាជ្ញា សូមគោរពលោកលោកស្រី ។ អានេះហើយដែលការខ្ញុំចង់បាន ។ ដែលខ្ញុំចង់បានៗរកអារឿងសិទ្ធិសេរីភាព ពេលនេះសិទ្ធិសេរីភាពខ្ញុំមានមកដល់ហើយ ។ ពីមុនឡើយខ្ញុំអត់មានសិទ្ធិសេរីភាពនឹងតវ៉ារបៀបនេះទេ បើប៊ានអ្នកណាមួយប៊ានតវ៉ា គឺថាក្បាលត្បូងចប ក្បាលគល់ឫស្សី ក្បាលផ្លូវរទេះ ។ អ៊ីចឹងខ្ញុំអរគុណលោកឌុច ណាស់ដែលគាត់មកឆ្លើយចំពោះមុខតុលាការទាំងអស់ គាត់ទទួលកំហុសគាត់ ហើយខ្ញុំក៏មិនបានទៅចងគំនុំគុំកួនអីនឹងគាត់ដែរ ខ្ញុំគ្រាន់តែស្វែងរកដើម្បីយុត្តិភាព សន្តិភាពសម្រាប់ប្រជាជនខ្ញុំជាងមួយលាននាក់ដែលស្លាប់ទៅ ។ ខ្ញុំអរគុណណាស់ ខ្លាចតែគាត់មិនឆ្លើយស្មោះត្រង់ចំពោះមុខតុលាការ ខ្ញុំអរគុណណាស់ ។*

***លោក យូ ប៊ុនឡេង:*** *អ៊ីចឹងយើងបញ្ចប់ប៉ុណ្ណេះ ប៉ុន្តែជាចុងក្រោយខ្ញុំបញ្ជាក់ម្តងទៀតណ៎ា សហការីរបស់ខ្ញុំហ្នឹងបានបញ្ជាក់រួចហើយថា-- ចប់]*

[១១:៤៩:០៥]

**សួរដោយលោក ហ្វេង់ស្វ័រ រូ៖**

**ស៖** ឌុច ថាតើការបញ្ចាំងខ្សែវីដេអូនេះ វាអាចរំឭកលោកអំពីដំណាក់កាលមួយដែលសំខាន់នៅក្នុងដំណើរការក្តីរបស់យើងដែរឬទេ? ខ្ញុំគិតថា វីដេអូនេះ អាចរំឭកអំពីខ្សែជីវិតដ៏សំខាន់របស់លោក ។ លោកបានឮហើយថា ជនរងគ្រោះមួយចំនួនមិនទាន់ពេញចិត្តនៅឡើយទេ នៅពេលដែលតុលាការរបស់យើងកំពុងតែឈានទៅដល់ចុងបញ្ចប់ហើយនោះ។ ហើយយើងក៏បានឮផងដែរនូវអ្វីដែលអ្នកជំនាញគាត់បានលើកឡើង។ អ្នកជំនាញបានលើកឡើងថា ចំពោះជនរងគ្រោះវាជាដំណើរការទាំងមូលតែម្តង ។ ហើយដំណើរការនេះកំពុងតែចាប់ផ្តើម ម្តងបន្តិចៗ ដូច្នេះហើយវាអាចជួយឲ្យពួកគេអាចកសាងនូវជីវិតរបស់ពួកគេឡើងវិញ ហើយការជំនុំជម្រះនេះគឺជាដំណាក់កាលមួយឈានទៅដល់ការផ្សះផ្សាជាតិ ។ ដូច្នេះហើយចំណុចនេះ ខ្ញុំចង់សួរលោកសំណួរចុងក្រោយ ថាតើ ឌុច លោកអនុញ្ញាតឲ្យខ្ញុំជម្រាបទៅដល់ជនរងគ្រោះដែរឬទេ ប្រសិនបើជនរងគ្រោះគាត់ចង់បាននោះ ។ គឺថាជនរងគ្រោះគាត់អាចមកជួបលោកដោយផ្ទាល់នៅក្នុងមន្ទីរឃុំឃាំងរបស់លោក បានន័យថា លោកចង់បើកទ្វារចំហបន្ទប់មន្ទីរឃុំឃាំង ដើម្បីសុំការអនុញ្ញាតឲ្យមានការជួប ឲ្យជនរងគ្រោះអាចជួបលោក ហើយក៏លោកបើកនូវចិត្តរបស់គាត់ផងដែរ ។ ហើយផ្លូវដែលលោកដើរ និងផ្លូវដែលលោកសុំទោស គឺមិនទាន់បញ្ចប់នៅពេលនេះទេ បានន័យថា ស្ពាន ឬក៏ផ្លូវដែលផ្សារភ្ជាប់រវាងជនរងគ្រោះ និងលោក គឺនៅតែមានជារៀងរហូត ។

[១១:៥១:២៤]

**ឆ៖** ខ្ញុំពេញចិត្តណាស់ហើយ ជនរងគ្រោះណាក៏ដោយ ឲ្យតែលោកអញ្ជើញទៅ ខ្ញុំទទួលទាំងអស់ ។ បើកទ្វារខាងផ្លូវចិត្ត ទទួលរាក់ទាក់ នេះម៉្យាង ។ ក៏ប៉ុន្តែសំខាន់ទៅទៀត គឺបើកទ្វារខាងផ្លូវចិត្តដដែលហ្នឹងដើម្បីបង្ហាញឲ្យឃើញថា ការពិតវាយ៉ាងម៉េច ចិត្តខ្ញុំវាយ៉ាងម៉េច ការទទួលស្គាល់កំហុសរបស់ខ្ញុំវាយ៉ាងម៉េច ដើម្បីឲ្យវាមានពាក្យភាពថា ជនរងគ្រោះទាំងនោះ គេសុខចិត្តថា អើ! ខ្ញុំបានទទួលស្គាល់កំហុសរបស់គេ បានឱនលំទោនចំពោះគេ បានអីៗ តាមដែលគេចង់បាន ខ្ញុំធ្វើតាមទាំងអស់ អត់ប្រកាន់ថា អ្នកណាជាអ្នកណាទេ ឲ្យតែជាជនរងគ្រោះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានជាទីគោរព! ខ្ញុំគិតថា យើងបានឈានចូលមកដល់ហើយនៅក្នុងដំណាក់កាលដេញដោលរបស់យើង ជាពិសេសទាក់ទងទៅនឹងការតាំងសំណួររបស់មេធាវីការពារក្តី ។

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ដំណើរការនៃកិច្ចពិភាក្សាអំពីអត្តចរិតជនជាប់ចោទ ឃើញថាដល់ទីបញ្ចប់ហើយ ហើយអង្គជំនុំជម្រះមុននឹងប្រកាសសម្រាកនៅពេលបាយនេះ សូមជូនដំណឹងជម្រាបដល់ភាគីជ្រាបថា នៅរសៀលនេះអង្គជំនុំជម្រះនឹងបន្តកិច្ចដំណើរការនីតិវិធីសវនាការ ទទួលនូវការដាក់ឯកសារដែលភាគីប៉ុនប៉ងក្នុងការដាក់នូវឯកសារទាំងឡាយ ដែលភាគីយល់ឃើញថាឯកសារទាំងនោះមិនទាន់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ ហើយអង្គជំនុំជម្រះ នឹងប្រឹងប្រែងដើម្បីពិនិត្យពិចារណាលើការដាក់ឯកសាររបស់ភាគីនៅរសៀលនេះ ហើយបើសិនជាធ្វើមិនទាន់ទេ គឺយើងនៅបន្តនៅថ្ងៃព្រឹកថ្ងៃស្អែកទៀត ។ ដូច្នេះ ភាគីសូមជម្រាបអំពីកិច្ចនេះ ហើយបញ្ហានេះគឺអង្គជំនុំជម្រះបានជម្រាបជូនភាគីពីដំបូងហើយថា យើងនឹងកំណត់ពេលវេលាចុងក្រោយនៃសវនាការរបស់យើងទទួលយកនូវឯកសារដែលភាគីនឹងលើកឡើង ដែលនៅសេសសល់ហើយមិនទាន់បានលើក គឺនៅលើកនៅចំពោះមុខអង្គជំនុំជម្រះនៅសវនាការចុងក្រោយដូច្នេះនៅរសៀលនេះ គឺយើងចាប់ដំណើរការ សូមជ្រាប ។

ហើយដូចឥឡូវពេលត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ហើយសវនាការលើកទៅបន្តនៅរសៀលចាប់ពីម៉ោងមួយនិងសាមសិបនាទី ។

អនុរក្សមន្ទីរឃុំឃាំង ឲ្យនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង១១:៥៦នាទីដល់ម៉ោង១៣:៣២នាទី ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ ដំណើរការសវនាការនៅរសៀលនេះ ដូចអ្វីដែលខ្ញុំបានប្រាប់ភាគីអំពីព្រឹកមិញហើយ អំពីកាលវិភាគដែលត្រូវធ្វើ

សវនាការនៅរសៀលនេះ គឺអង្គជំនុំជម្រះទទួលនូវការដាក់ឯកសាររបស់ភាគី ដែលភាគីមានបំណងក្នុងការដាក់នូវឯកសារចំពោះមុខអង្គជំនុំជម្រះ ដែលមិនបានរៀបចំក្នុងការដាក់ឯកសារនៅក្នុងអំឡុងពេលនៃដំណើរការពិភាក្សាដេញដោលកន្លងមក ។ ហើយមានបញ្ហាដែលសេសសល់ គឺសូមអញ្ជើញដាក់នៅពេលនេះ ហើយតាមព័ត៌មានថ្មីៗឃើញថា អាចនឹងមានបញ្ហារវាងការដាក់ឯកសារថ្មី ដើម្បីសម្រួលដល់កិច្ចការនេះ សូមបញ្ជាក់ថា ប្រសិនបើមានឯកសាររវាងចាស់និងថ្មី គឺសូមញែកឲ្យបានច្បាស់លាស់ គឺបង្ហាញក្នុងការដាក់ឯកសារ ដោយបង្ហាញអំពីអត្តសញ្ញាណនៃឯកសារដែលសុំលើកឡើងនៅចំពោះមុខជំនុំជម្រះ ហើយបន្ទាប់មក គឺសូមដល់បញ្ហាទីពីរ គឺឯកសារថ្មីដែលមានបំណងសុំដាក់ជូនជាភស្តុតាងក្នុងសំណុំរឿងដើម្បីឲ្យភាគីដទៃទៀតមានការអាចពិនិត្យនូវឯកសារទាំងនោះមុននឹងអង្គជំនុំជម្រះសម្រេចថាតើទទួលដាក់ឲ្យកិច្ចពិភាក្សា ក្នុងការពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ឬក៏អត់នោះ ។

ដើម្បីឲ្យបាននីតិវិធីប្រព្រឹត្តទៅស្រួល សូមអញ្ជើញខាងតំណាងសហព្រះរាជអាជ្ញា ប្រសិនបើមានការស្នើសុំនូវដាក់ឯកសារ សូមអញ្ជើញ។

**លោក អានីស អះមេដ៖**

លោកប្រធាននៅចំពោះមុខលោកប្រធាន និងនៅក្នុងចំពោះមុខអង្គសវនាការនេះ គឺថានៅថ្ងៃនេះយើងបានបញ្ចប់ការស្តាប់នូវភស្តុតាងនានា គឺនៅក្នុងការអនុវត្តក្នុងការស្វែងរកយុត្តិធម៌សម្រាប់ប្រទេសកម្ពុជានិងប្រជាជនកម្ពុជា ។ ហើយសវនាការនេះត្រូវបានកើតឡើង ដោយពឹងផ្អែកទៅច្បាប់ជាតិ និងអន្តរជាតិ ហើយតុលាការនេះក៏ត្រូវបានបង្កើតផងដែរនៅក្នុងគោលបំណងក្នុងការស្វែងរកយុត្តិធម៌ដោយសហគមន៍ជាតិ និងអន្តរជាតិទាំងអស់ ។ ដូច្នេះ ខ្ញុំដឹងអំពីភាពសំខាន់នៃអង្គសវនាការ របស់យើង និងការបញ្ចប់ការស្តាប់នូវភស្តុតាងទាក់ទងទៅនឹងសំណុំរឿងនេះ ។

ខ្ញុំមានកិត្តិយសណាស់ដែលខ្ញុំបានក្រោកឈរនៅចំពោះមុខអង្គសវនាការ ដែលខ្ញុំចង់បង្ហាញនូវឯកសារមួយចំនួនដែលមានជាស្រេចហើយនៅក្នុងសំណុំរឿង ។ ហើយដែលឯកសារទាំងហ្នឹងចួនកាលអាចត្រូវបានលើកយកមកនិយាយនៅក្នុងអង្គសវនាការ ។ ក៏ប៉ុន្តែចួនកាលឯកសារខ្លះទៀតមិនទាន់ត្រូវបានលើកយកនៅឡើយទេនៅក្នុងកំឡុងពេលប្រាំមួយខែនៃអង្គសវនាការនេះ ។ ខ្ញុំចង់បង្ហាញផងដែរ ជាកំណត់ត្រានៅក្នុងសវនាការនេះ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅស-២១ និងបរិបទនានាទាក់ទងទៅនឹងព្រឹត្តិការណ៍ ទាក់ទងទៅនឹងបទឧក្រិដ្ឋអស់ទាំងនោះ ។

[១៣:៣៦:៤១]

នៅក្នុងនីតិវិធីនៅចំពោះមុខអង្គសវនាការនេះ លោកចៅក្រម បានអនុញ្ញាតឲ្យធ្វើការពិនិត្យដេញដោលទៅលើ សាក្សីជាច្រើន ពីព្រោះគឺថាលោក លោកស្រីចៅក្រម គឺជាអ្នកកាត់ក្តីទៅលើអង្គហេតុជាអ្នកស្វែងរកការពិត ហើយសហចៅក្រមស៊ើបអង្កេត គឺជាអ្នកពិនិត្យក្នុងតួនាទីមួយជាអ្នកអញ្ញាក្រឹត្យជាអ្នកស៊ើបអង្កេតអញ្ញាក្រឹត្យ ឯករាជ្យទៅលើភស្តុតាងនានា ដែលគេបានដាក់នៅចំពោះមុខរបស់ពួកគេដោយភាគីនានាផ្សេងៗ ឬក៏ដោយគេប្រមូលបានដោយឯករាជ្យរបស់ខ្លួនគាត់ ។ ហើយនៅក្នុងដំណាក់កាលនេះដែរ វិធានដែលបានប្រគល់ឲ្យតាមរយៈកិច្ចប្រជុំពេញអង្គ គឺជាបន្ទុកដ៏សំខាន់របស់សហព្រះរាជអាជ្ញា ក្នុងការបង្ហាញឲ្យហួសវិមតិសង្ស័យ អំពីបន្ទុកអស់ទាំងហ្នឹង គឺទាក់ទងនឹងវិធាន៨៧.១ ហើយនៅថ្ងៃនេះ ខ្ញុំមិនធ្វើការបង្ហាញនូវឯកសារអ្វីបន្ថែមទៀតនោះទេ ។ ក៏ប៉ុន្តែ គឺជាសំណើមួយ ដោយពឹងទៅលើការ អាស្រ័យទៅលើការវិភាគទៅលើឯកសារនានា ដែលយើងបានពិនិត្យមើលរួចហើយនៅក្នុងអង្គសវនាការនេះ ។ ហើយជាឯកសារបន្ថែមទៅលើឯកសារដែលយើងបានពិនិត្យមើលរួចហើយនោះ ហើយដែលឯកសារមួយចំនួននេះ គឺនឹងជួយដល់អស់លោក លោកស្រី ក្នុងការធ្វើសេចក្តីសម្រេចក្នុងការសម្រេចទៅលើសំណុំរឿងនេះឲ្យបានមានភាពងាយស្រួលជាងនេះ ។

ដូច្នេះ គឺលោកស្រីនឹងអាចមានភស្តុតាងដ៏ច្រើនល្អប្រសើរនៅចំពោះមុខលោក លោកស្រីចៅក្រមដើម្បីធ្វើការពិចារណា ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្ញុំមុននេះ គឺខ្ញុំបាននិយាយថា អង្គសវនាការនេះត្រូវបានបង្កើតឡើង គឺដោយមានផ្សំនូវវិធានការ និងនូវច្បាប់របស់ជាតិនិងអន្តរជាតិ ដែលអនុវត្តទៅតាមបទដ្ឋានរបស់អន្តរជាតិ ដែលត្រូវបានអនុម័តនៅក្នុងអង្គជំនុំជម្រះផ្សេងៗទៀត ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលមានទំហំធំធេង និងមានភាពស្មុគស្មាញដូចឧក្រិដ្ឋកម្មនេះដែរ ។ ដូច្នេះ តុលាការជាតិកម្ពុជានៅក្នុងយុត្តិសាស្ត្ររបស់ប្រទេសកម្ពុជានោះ នឹងអាចទទួលយកនូវសំណុំរឿងទាំងអស់នោះថាជាសំណុំរឿងដើម្បីធ្វើការពិចារណានៅក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន និងនៅក្នុងសវនាការ ។ ក៏ប៉ុន្តែជាការត្រឹមត្រូវផងដែរ ដោយសារតែភាពស្មុគស្មាញ ជាក់លាក់ និងវិសាលភាពដ៏ធំនៃនីតិវិធីនេះ និងដោយសារតែឧក្រិដ្ឋកម្មដ៏ច្រើនរាប់រយ ហើយនិងបទឧក្រិដ្ឋរាប់សិបពាន់ ដែលត្រូវបានចោទប្រកាន់ចំពោះបុគ្គលិកនីមួយៗក្នុងអំឡុងពេលបីឆ្នាំប្រាំបីខែនិងម្ភៃថ្ងៃនោះ គឺជាការត្រឹមត្រូវណាស់ ដែលថាឯកសារពេញលេញទាំងអស់ត្រូវតែមាននៅចំពោះមុខអង្គសវនាការ ដើម្បីជួយនៅក្នុងការធ្វើការវិនិច្ឆ័យនោះ ។ ហើយនៅចុងបញ្ចប់នៃការធ្វើសវនាការ នៅពេលដែលយើងអាចធ្វើការវាយតម្លៃឲ្យបានជាក់ច្បាស់អំពីអ្វីដែលមានដាក់បង្ហាញជូននៅចំពោះមុខអង្គសវនាការនេះ និងអ្វីទៀតដែលអាចជួយអស់លោក លោក

ស្រីបាន នៅពេលដែលធ្វើការវិនិច្ឆ័យនោះ គឺមានន័យថា ផ្តល់នូវភស្តុតាងដ៏ល្អប្រសើរបំផុតដល់លោក លោកស្រីចៅក្រម ដើម្បីឲ្យលោក លោកស្រីចៅក្រមធ្វើការវិនិច្ឆ័យដោយមានភាពងាយស្រួលច្បាស់លាស់ជាងមុន ។

[១៣:៤០:០៨]

ដូច្នេះខ្ញុំយល់ថា នេះគឺជាភារកិច្ចរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងអនុវិធាន៨៧.១ ហើយនេះគឺជាបន្ទុករបស់យើងក្នុងការបង្ហាញនូវការចោទប្រកាន់អស់ទាំងហ្នឹង ។ ហើយវិធាន ៨៧.២ និង ៨៧.៣ នោះក៏បានបង្ហាញផងដែរថា ឯកសារដែលអាចដាក់នូវចំពោះមុខអង្គសវនាការបាន គឺអាស្រ័យទៅលើការពិនិត្យរបស់អង្គសវនាការ ។ ដូច្នេះ គឺមានយន្តការនៃការពិនិត្យ ត្រងយកនូវឯកសារដ៏ល្អៗសម្រាប់ការពិចារណារបស់លោក លោកស្រី ហើយមានន័យថា គឺនៅពេលដែលលោកស្រីធ្វើការវិនិច្ឆ័យនោះ គឺវិនិច្ឆ័យតែទៅលើអង្គហេតុដែលសំខាន់ៗតែប៉ុណ្ណោះ ។ ចំណែកមេធាវីការពារក្តី និងជនជាប់ចោទនោះ គឺថាបានឯកភាពគ្នាទៅលើអង្គហេតុមួយចំនួនដែលបានព្រមព្រៀងគ្នារួចទៅហើយ ។ ហើយក៏អាចជាការជួយផងដែរនៅពេលដែលជនជាប់ចោទនេះបានធ្វើការសហការជាមួយនឹងខាងសហព្រះរាជអាជ្ញា ។

ដូច្នេះ ខ្ញុំនឹងធ្វើការបង្ហាញអំពីសំណើរបស់ខាងសហព្រះរាជអាជ្ញានេះ អ្វីដែលយើងធ្វើនេះ គឺមិនមែនធ្វើការក្នុងការបង្ហាញអំពីឯកសារណាដែលវាមិនចាំបាច់ ដែលវាមិនសំខាន់នោះទេ។ ក៏ប៉ុន្តែនេះគឺជាការលើកឡើងនូវឯកសារដែលជាវិធីសាស្ត្រមួយល្អ ដើម្បីបង្ហាញនូវឯកសារ និងភស្តុតាងបន្ថែមទៀតទៅលើអ្វីដែលយើងមានរួចមកហើយនោះ ។

ទាក់ទងទៅនឹងឯកសារទាំងបួនផ្នែកធំៗ ដែលខ្ញុំនឹងបង្ហាញជូននូវចំពោះមុខ លោក លោកស្រីចៅក្រមនេះ គឺខ្ញុំបានពិភាក្សារួចហើយជាមួយនឹងលោក ហ្វ្រង់ស្វ័រ រូ ហើយគឺពួកយើងបានឯកភាពគ្នាទៅលើចំណុចមួយចំនួន ។ ហើយដែលខ្ញុំមិននិយាយទេ ប៉ុន្តែខ្ញុំទុកឱកាសឲ្យគាត់ឡើងនិយាយប្រាប់ដល់អស់លោក លោកស្រីចៅក្រម ។ ឯកសារដែលខ្ញុំចង់ដាក់បង្ហាញនេះ គឺជាឯកសារដែលខាងសហព្រះរាជអាជ្ញានឹងចង់ធ្វើការលើកឡើង ហើយបើសិនជាខាងមេធាវីការពារក្តីចង់ធ្វើការជំទាស់ទៅលើឯកសារអស់ទាំងនុ៎ង គឺខ្ញុំនឹងអាចបង្ហាញអំពីចំណុចជាក់លាក់បន្ថែមទៀតអំពីហេតុអ្វីបានជាឯកសារអស់ទាំងហ្នឹងគួរតែត្រូវយកមកកំណត់ឲ្យបានច្បាស់លាស់នៅក្នុងមុខអង្គសវនាការនេះ ។

[១៣:៤២:២២]

ទាក់ទងទៅនឹងឯកសារទាំងបួនប្រភេទធំៗដែលខ្ញុំចង់ដាក់នៅចំពោះមុខអង្គសវនាការនេះ គឺដើម្បីឲ្យអស់លោក លោកស្រីចៅក្រម យកមកពិចារណានិងប្រើប្រាស់នៅក្នុងអង្គសវនាការ ។ លោក លោកស្រីចៅក្រមបានបង្កើតនូវវិធីសាស្ត្រមួយចំនួនក្នុងការដាក់បង្ហាញឯកសារនៅចំពោះមុខអង្គសវនាការនេះ។ នៅក្នុងសេចក្តីសម្រេចរបស់លោក លោកស្រីចៅក្រម ដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការកាលពីខែមិថុនា ឆ្នាំ២០០៨ នោះ បើសិនជាឯកសារហ្នឹងមានការកំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់នោះ គឺអាចកំណត់ថាដាក់នៅចំពោះមុខអង្គសវនាការបាន ។ មានន័យថា មិនចាំបាច់យកមកអាននៅក្នុងសវនាការនេះទេ ឬក៏មិនចាំបាច់យកមកធ្វើសេចក្តីសង្ខេបនោះទេ ។ ក៏ប៉ុន្តែ ជាសំខាន់បំផុត គឺកំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់នូវឯកសារនោះ ឈ្មោះឯកសារនោះ និងលេខ ERN របស់ឯកសារនោះ និងចំណុចពាក់ព័ន្ធមួយចំនួនទៀតដែលត្រូវបានដាក់នៅក្នុងកំណត់ហេតុ ហើយនៅក្នុងកំឡុងពេលពីរបីនាទីខាងមុខទៀត ខ្ញុំនឹងបង្ហាញអំពីចំណុចអស់ទាំងនោះ ។

ឯកសារទាំងបួនប្រភេទដែលយើងខ្ញុំនឹងចង់ដាក់ជូននៅចំពោះមុខលោក លោកស្រីចៅក្រមនេះ គឺថា ចំណុចទីមួយ ទាក់ទងទៅនឹងវិធាន៩២ គឺថាវិធាននេះអនុញ្ញាតឲ្យយើងខ្ញុំដាក់នូវឯកសារជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គសវនាការនៅក្នុងកំឡុងពេលសវនាការរហូតដល់សវនាការបានបញ្ចប់ គឺឯកសារនោះអាចជាឯកសារ ឬក៏អាចទស្សនីករណ៍ ដែលយើងយល់ថាវាជាសារសំខាន់សម្រាប់សំណុំរឿង ហើយគឺយើងមានសិទ្ធិក្នុងការបង្ហាញឯកសារអស់ទាំងហ្នឹងនៅចំពោះមុខអង្គសវនាការ ។

ខ្ញុំចង់ចាប់ផ្តើមអំពីចំណុចនេះពីដំបូង ឯកសារប្រភេទដំបូង គឺជាផែនទីដែលយើងចង់ យើងខ្ញុំចង់ដាក់នៅចំពោះមុខអង្គសវនាការ ដែលផែនទីនេះ គឺជាឧបសម្ព័ន្ធ “ក” ដែលខាងសហចៅក្រមស៊ើបអង្កេតបានដាក់នៅភ្ជាប់ជាមួយនិងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលដែលលោកស្រីចៅក្រមបានទទួលនូវដីកាបញ្ជូនទៅជំនុំជម្រះកាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ មកនោះ គឺមានឧបសម្ព័ន្ធអ៊ីរួចហើយ ។ គឺមិនមានលេខERN សម្រាប់លេខនេះទេ គឺវាជាឧបសម្ព័ន្ធ “ក” ខ្ញុំអាចបង្ហាញបាននៅចំពោះមុខអង្គសវនាការ គឺនៅពេលដែលធ្វើការវាយតម្លៃទៅលើភស្តុតាង ។ ឯកសារនេះបង្ហាញអំពីចំណុចលម្អិតផ្សេងៗទៀត ទាក់ទងទៅនិងទីតាំងរបស់ស-២១ គឺមានឯកសារនោះ មានលេខ 00210940 ដែលជាឧបសម្ព័ន្ធ “ក” ភ្ជាប់ជាមួយនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ។

ឯកសារទីពីរដែលខ្ញុំចង់ដាក់នៅចំពោះលោក លោកស្រីចៅក្រម គឺជាឯកសារដែលយើងបានដាក់ជូនកាលពីថ្ងៃទី២៩ ខែ៤ នៅចំពោះមុខអង្គសវនាការនេះ ។ ឯកសារនេះគឺទាក់ទងទៅនឹងការបង្កើត

នូវជម្លោះប្រដាប់អាវុធអាទិភាពនៃជម្លោះប្រដាប់អាវុធ នៅក្នុងអំឡុងពេលយុត្តាធិការរបស់តុលាការនេះ នៅក្នុងទូទាំងប្រទេសកម្ពុជាដែលជាជម្លោះប្រដាប់អាវុធរវាងកម្ពុជានិងវៀមណាម ។ ហើយជនជាប់ចោទដែលមានមុខនៅចំពោះលោក លោកស្រីចៅក្រមនេះ បានសារភាពនៅក្នុងអង្គហេតុដែលបានព្រមព្រៀងគ្នានោះថាគឺមានអាទិភាពរវាងជម្លោះអាវុធរវាងកម្ពុជានិងវៀតណាមពីថ្ងៃទី៣១ ខែធ្នូ ៧៧ រហូតដល់ចុងបញ្ចប់នៃយុត្តាធិការរបស់តុលាការនេះ ។

នៅពេលដែលបានឯកភាពនៅលើចំណុចនេះ ប៉ុន្តែគឺសហព្រះរាជអាជ្ញាមានការយល់ថាតាមពិតជម្លោះប្រដាប់អាវុធមានអាទិភាពរវាងកងទ័ពកម្ពុជាដែលជាកងទ័ពរបស់ខ្មែរក្រហម និងកងកម្លាំងរបស់ប្រទេសវៀតណាម ។ នៅក្នុងអំឡុងពេលទាំងស្រុង នៃយុត្តាធិការពេលវេលារបស់តុលាការនេះ ។ ចំណែកមេធាវីការពារក្តីវិញ មិនបានបដិសេធអំពីអាទិភាពនៃជម្លោះប្រដាប់អាវុធនោះទេ ។ នៅចន្លោះពេលឆ្នាំ៧៥ ដល់ឆ្នាំ៧៧ នោះ គឺថាពួកគាត់បានទុកឱកាសឲ្យលោក លោកស្រីចៅក្រម ធ្វើការវិនិច្ឆ័យទៅលើភស្តុតាងដែលមានដាក់បង្ហាញជូននៅចំពោះមុខអង្គសវនាការនេះថាតើមានជម្លោះប្រដាប់អាវុធដែរឬទេ ពីចន្លោះឆ្នាំ៧៥ ដល់ខែធ្នូ ឆ្នាំ៧៧ នោះ?

លោក លោកស្រីចៅក្រម នៅអាចចាំបានថារបាយការណ៍របស់លោក ណាយ៉ាន់ ចាន់ដា ដែលបានបង្ហាញនៅក្នុងសក្ខីកម្មរបស់គាត់ថា ពិតជាមានអាទិភាពរបស់ជម្លោះប្រដាប់អាវុធនៅក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់តុលាការនេះ ។ ដូច្នេះ ឯកសារដែលយើងខ្ញុំដាក់ជូននៅចំពោះមុខសវនាការនេះ ហើយដែលមានដាក់នៅក្នុងសំណុំរឿង កាលពីថ្ងៃ២៩ ខែ៤ ឆ្នាំ២០០៩ នោះ គឺជាឯកសារដែលមានលេខ E61 ហើយឯកសារដែលភ្ជាប់មកជាមួយហ្នឹង គឺជាឯកសារនានាដែលយើងចង់ស្នើសុំឲ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះដើម្បីជួយដល់អស់លោក លោកស្រីចៅក្រម ក្នុងការកំណត់អាទិភាពនៃជម្លោះប្រដាប់អាវុធ នៅក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់តុលាការនេះ ។ ឯកសារអស់ទាំងនោះ គឺជាឯកសារដែលរកបានមកថ្មីៗ ហើយដែលបានត្រូវបានបង្កើតឡើងដោយរបបខ្មែរក្រហម ខ្លះទៀតគឺជាឯកសារ-- គឺជាសេចក្តីប្រកាស និងជាទំនាក់ទំនងរវាងអង្គសហប្រជាជាតិ ឬក៏ជាអត្ថបទកាសែត ឬក៏ជាទស្សនាវដ្តី ហើយនិងលិខិតឆ្លើយឆ្លងមួយចំនួនផងដែរ ។ ហើយនៅក្នុងករណីដែរថាយើងមិនមានភស្តុតាងក្នុងការបង្ហាញសក្ខីកម្មទាំងអស់ទាំងហ្នឹង គឺភស្តុតាងអស់នុ៎ងហើយ ជាភស្តុតាងដែលល្អប្រសើរបំផុតសម្រាប់ជួយដល់អស់លោក លោកស្រីចៅក្រម ក្នុងការធ្វើសេចក្តីសន្និដ្ឋានថា ជាពិតអាទិភាពជម្លោះប្រដាប់អាវុធរវាងកម្ពុជានិងវៀតណាម ពិតប្រាកដមែន ។

[១៣:៤៩:០៧]

ឯកសារទាំងអស់ហ្នឹង ត្រូវបានបញ្ជូនជាឧបសម្ព័ន្ធ “ក” បន្ថែមទៅលើឯកសារ E61 ដែលបានចុះកាលពី-- ដាក់បញ្ជូនកាលពីថ្ងៃទី២៩ ខែ៤ ឆ្នាំ២០០៩ ។ ហើយដូចជាលោកចៅក្រម បានប្រាប់អ៊ីចឹងគឺឯកសារទីមួយ មានលេខ ERN បន្ទាប់មកទៀត យើងនឹងបង្ហាញជូនអំពីឧបសម្ព័ន្ធ “ក” បង្ហាញអំពីឯកសារដែលបានដាក់ភ្ជាប់ជាមួយនោះ ។ លេខ ERN នុ៎ង គឺមានដូចខាងក្រោម៖

ជាភាសាអង់គ្លេស ឯកសារនេះគឺឯកសារថ្ងៃទី២៩ ខែ៤ ឆ្នាំ២០០៩ នោះ គឺមានលេខ ERN 00326308 រហូតដល់លេខ 00326309 ហើយឯកសារនេះ អានថាការដាក់ជូនតាមវិធាន៩២ ការបង្ហាញអំពីអាទិភាពនៃជម្លោះប្រដាប់អាវុធដែលត្រូវបានដាក់ជូនទៅចំពោះមុខអង្គជំនុំជម្រះ ដោយអនុវត្តន៍ទៅតាមវិធាន៨៧.២ ។ ឯកសារនេះ ជាភាសាខ្មែរ គឺមានលេខ ERN00326310 រហូតដល់លេខ 00326312 ។ នោះជាសំណើរបស់ខាងព្រះរាជអាជ្ញាសម្រាប់ដាក់បញ្ជូននូវឯកសារជាឧបសម្ព័ន្ធ “ក” នោះ ។ ឯកសារឧបសម្ព័ន្ធ “ក” នោះ គឺមានលេខ 0033057 រហូតដល់លេខ 00333141 ជាភាសាខ្មែរ ។ ជាភាសាអង់គ្លេសវិញ មានលេខ 00326313 រហូតដល់លេខ 00326348 ។ ការពិភាក្សារវាងយើងខ្ញុំជាមួយនឹងមេធាវីការពារក្តី ទាក់ទងទៅនឹងឯកសារពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធនោះ គឺខាងមេធាវីការពារក្តីបានធ្វើការកត់សម្គាល់នៅក្នុងសវនាការនេះថា កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ នោះ ខ្ញុំសូមអាននូវកំណត់ហេតុពីនីតិវិធីនោះ គឺនៅទំព័រ៦៧នៃប្រតិចារឹកជាភាសាអង់គ្លេសគឺគាត់បាននិយាយថា ខ្ញុំបានប្រាប់ទៅខាងការិយាល័យសហព្រះរាជអាជ្ញា ថានេះគឺសេចក្តីសង្ខេបដែលមួយទំព័រនៃអត្ថបទកាសែតនោះ ។ សេចក្តីសង្ឃឹមរបស់ខ្ញុំនុ៎ង គឺថាខាងសហព្រះរាជអាជ្ញានឹងគួរប្រមូលបាននូវឯកសារ ឬអត្ថបទកាសែតអស់ទាំងហ្នឹងឲ្យបានច្រើន ដើម្បីបង្ហាញអំពីចំណុចនេះ ។ បើសិនជាការកត់សម្គាល់របស់ខ្ញុំត្រឹមត្រូវទៅលើអ្វីដែលគាត់បាននិយាយនោះ គឺថាគាត់ចង់ទទួលបាននូវអត្ថបទកាសែតទាំងអស់ហ្នឹង ពីទូទាំងពិភពលោក ដែលអត្ថបទនោះខ្លះអាចជាភាសាអង់គ្លេស ឬក៏អាចជាភាសាខ្មែរនិងភាសាបារាំង ។ ដូច្នេះ ជម្រើសប្រសើរបំផុត គឺយើងគួរតែធ្វើការបកប្រែនូវឯកសារទាំងអស់ទាំងនុ៎ង ជាឯកសារភាសាទាំងបី ។ ប៉ុន្តែចំណុចជម្រើសផ្សេងទៀត ដែលគាត់បានផ្តល់ឲ្យយើងនោះ គឺថាគាត់ចង់ឲ្យយើងផ្តល់នូវសេចក្តីសង្ខេបនៃឯកសារអស់ទាំងហ្នឹង ។

ដូច្នេះ សំណើរបស់យើងនៅពេលនេះ គឺយើងផ្តល់តែនូវសេចក្តីសង្ខេបនៃឯកសារអស់ទាំងនុ៎ងតែប៉ុណ្ណោះ ។ ហើយបើសិនជាមេធាវីការពារក្តី គាត់ត្រូវការឯកសារបន្ថែមឲ្យបានពេញលេញនោះ គឺ

ថាយើងនឹងសប្បាយចិត្តក្នុងការផ្តល់ជូន ។ នេះគឺជាសំណើទីពីរ លោកចៅក្រម ។

ការធ្វើសំណើទីបីរបស់យើងខ្ញុំគឺទាក់ទងទៅនឹងឯកសារដែលបានភ្ជាប់ជាមួយនឹងការដាក់ជូននៅពេលថ្មីៗនេះ គឺកាលពីថ្ងៃទី១៩ ខែ៨ ឆ្នាំ២០០៩ ។ គឺការដាក់ជូននេះ មានការដាក់ជាភាសាអង់គ្លេស ហើយខ្ញុំសូមអាន សំណើរបស់សហព្រះរាជអាជ្ញាក្នុងការដាក់ជូននូវសេចក្តីថ្លែងការណ៍ បទសម្ភាសន៍ដែលពាក់ព័ន្ធនឹងឯកសារស-២១ ដែលមានចំណាររបស់ជនជាប់ចោទដែលបានប្រមូលក្នុងដំណាក់កាលស៊ើបអង្កេត ។

ឯកសារទាំងអស់នេះ ដោយធ្វើតាមសំណើទៅតាមការបង្ហាញ និងការណែនាំរបស់លោកចៅក្រម គឺមានលេខ E1-52 ហើយមានលេខ ERN00364635 ជាភាសាអង់គ្លេស រហូតដល់លេខ 00364649 ជាភាសាខ្មែរវិញមានលេខ 00364650 រហូតដល់លេខ 00364672 ។ ការដាក់ជូននូវឯកសារកាលពីថ្ងៃទី១៩ ខែ៨ ឆ្នាំ២០០៩ នេះ គឺមានឧបសម្ព័ន្ធភ្ជាប់ជាមួយចំនួនបួន ហើយឧបសម្ព័ន្ធ "ក" ដែលភ្ជាប់នោះ ហើយខ្ញុំសូមលើកឡើងថា ឯកសារអស់ទាំងហ្នឹង គឺទទួលយកបានដោយឆ្លងការពិនិត្យយ៉ាងច្បាស់លាស់របស់ខាងសហចៅក្រមស៊ើបអង្កេត ។ ដំបូងគឺឧបសម្ព័ន្ធ "ក" ដែលរួមមានសេចក្តីថ្លែងការណ៍ដែលជនជាប់ចោទនេះ បានធ្វើនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត រួមបញ្ចូលទាំងកំណត់ហេតុនៃការសួរដេញដោលដែលបានធ្វើឡើង និងកំណត់ហេតុនៃការសម្តែងឡើងវិញ ដែលបានលើកឡើងកាលពីព្រឹកមិញនេះ ។ ហើយគឺសហចៅក្រមស៊ើបអង្កេតជាអ្នករៀបចំឯកសារអស់ទាំងនេះ ។ ចំណែកឧបសម្ព័ន្ធ "ខ" នៃសំណើនេះ គឺជាសេចក្តីថ្លែងការណ៍របស់សាក្សី ហើយជាថ្មីម្តងទៀតដែលបានធ្វើឡើងដោយអ្នកស៊ើបអង្កេតដែលមានភាពឯករាជ្យ និងអព្យាក្រឹត្យរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតនោះ ។ ហើយឯកសារទាំងហ្នឹង គឺបានផ្តល់ជូនដល់ភាគីនានា នៅពេលដែលបានទទួលយកនោះ ។ ចំណែកឧបសម្ព័ន្ធ "ខ" និង "គ" វិញ នៃឯកសារកាលពីថ្ងៃទី១៩ ខែ៨ ឆ្នាំ២០០៩ នោះ គឺជាឯកសារចំនួនហុកសិប ដែលឯកសារនុ៎ង ត្រូវបានធ្វើចំណារដោយជនជាប់ចោទនៅក្នុងអំឡុងពេលគាត់ជាប្រធានស-២១ ។

[១៣:៥៦:៥០]

ហើយឯកសារទាំងហ្នឹង គឺសហចៅក្រមស៊ើបអង្កេតបានយកមកប្រើប្រាស់នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេត ហើយត្រូវបានយកមកដាក់បង្ហាញជូននៅចំពោះមុខសាក្សីមួយចំនួនដែរ ហើយនៅក្នុងសវនាការក៏ឯកសារអស់ទាំងហ្នឹង ក៏ត្រូវបានដាក់បង្ហាញជូន និងសួរដល់ជនជាប់ចោទផងដែរ និង

សម្រាប់សាក្សីមួយចំនួនផ្សេងៗទៀតឲ្យពួកគេធ្វើការអត្ថាធិប្បាយទៅលើឯកសារអស់ទាំងនុ៎ង ។ ដូច្នេះ នៅក្នុងសំណើរបស់យើងខ្ញុំ ឯកសារទាំងអស់នេះគឺបង្ហាញថា បង្ហាញអំពីចំណុចសំខាន់ដែលមាននៅចំពោះមុខលោក លោកស្រីចៅក្រម ដូច្នេះហើយគឺបង្ហាញអំពីតួនាទី និងទំហំនៃការចូលរួមរបស់ជនជាប់ចោទទៅលើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ប្រឆាំងនឹងគាត់ ។ ឯកសារទាំងហ្នឹង គឺជាឯកសារដែលបានប្រមូលផ្តុំឡើងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ជនជាប់ចោទ ដែលជនជាប់ចោទនេះបានចុះហត្ថលេខា បានពិនិត្យមើល ចុះហត្ថលេខា និងបានធ្វើចំណារដោយមិនមានការបារម្ភអំពីការទទួលខុសត្រូវផ្នែកឧក្រិដ្ឋកម្មនោះទេ ។ គឺគាត់ធ្វើក្នុងតួនាទីរបស់គាត់ជាប្រធានស-២១ ដូច្នេះឯកសារនេះ គឺឯកសារដ៏សំខាន់ក្នុងការជួយដល់លោក លោកស្រីចៅក្រម ក្នុងការសន្និដ្ឋានទៅលើទំហំ និងវិសាលភាព និងកត្តាផ្សេងៗនៃការដាក់ទម្ងន់ទោស ឬក៏បន្ថយទោសទៅលើស្ថានភាពនានាដែលពាក់ព័ន្ធទៅនឹងជនជាប់ចោទនេះ។ យើងក៏បានពិភាក្សាផងដែរពីឯកសារអស់ទាំងហ្នឹងជាមួយនឹងមេធាវីការពារក្តី ហើយខ្ញុំទុកឲ្យគាត់ជាអ្នកឆ្លើយតបអំពីបញ្ហាអស់ទាំងនេះ នៅចំពោះមុខលោក លោកស្រីចៅក្រមទៅចុះ ។

[១៣:៥៨:៣៥]

ឯកសារចុងក្រោយដែលខ្ញុំចង់ធ្វើការដាក់បង្ហាញជូននៅចំពោះមុខអង្គសវនាការនេះ តាមពិតមិនមែនជាឯកសារច្រើនទេ គឺឯកសារតែមួយតែប៉ុណ្ណោះ ។ ឯកសារនោះ គឺជាសៀវភៅ ហើយសៀវភៅនេះ គឺជាគ្រឹះមូលដ្ឋាននៃការធ្វើសំណើរបស់យើង ដែលយើងបានដាក់ជូននូវចំពោះមុខលោក លោកស្រីចៅក្រម កាលពីថ្ងៃទី២៤ ខែ៨ ឆ្នាំ០៩ ដែលមានលេខ 00369927 រហូតដល់លេខ 00369928 ហើយជាភាសាខ្មែរវិញ គឺមានលេខ 00369929 រហូតដល់លេខ 00369930 ។ ឯកសារនេះរៀបរាប់ថា គឺជាឯកសារ E1-60 ដែលមានចំណងជើងថា កំណត់សម្គាល់របស់សហព្រះរាជអាជ្ញាក្នុងការដាក់សៀវភៅរបស់លោក នីក ដងឡុប ដែលមានចំណងជើង “ពេជ្ឈឃាដបាត់ខ្លួន” បញ្ចូលទៅក្នុងសំណុំរឿង និងក្នុងការដាក់បញ្ចូលជាភស្តុតាងនៅក្នុងសវនាការ ។ យើងបានព្យាយាមអស់ប្រឹងប្រែងក្នុងការស្វែងរកសៀវភៅជាភាសាបារាំងផងដែរ ក៏ប៉ុន្តែជាបច្ច័យអាក្រក់ ហើយអ្នកនិពន្ធក៏គាត់មិនបានធ្វើការបកប្រែ ឬក៏បោះពុម្ពផ្សាយសៀវភៅនោះជាភាសាបារាំងទេ ។ ដូច្នេះ សៀវភៅនោះ គឺមានតែជាភាសាអង់គ្លេស និងជាភាសាខ្មែរតែប៉ុណ្ណោះ ។ ហើយលោក លោកស្រីចៅក្រម និងសហចៅក្រមស៊ើបអង្កេតបានយោងសៀវភៅនេះជាច្រើន ហើយជនជាប់ចោទក៏ត្រូវបានសួរសំណួរជាច្រើនទាក់ទងទៅនឹងសៀវភៅនេះផងដែរ និងនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត ។

នៅក្នុងការដាក់ជូននូវសំណើនេះ សៀវភៅគឺវាបានផ្តល់ការរៀបរាប់ពេញលេញទៅលើសកម្ម-ភាពរបស់ជនជាប់ចោទ ។ នៅក្នុងរបបខ្មែរក្រហម គឺបានន័យថា រហូតមកដល់ខែមករា ឆ្នាំ១៩៧៩ ជនជាប់ចោទដូចដែលគាត់បានសហស៊ើបអង្កេត-- បានប្រាប់សហចៅក្រមស៊ើបអង្កេតបានអានសៀវភៅនេះ។ ដូច្នេះ ហើយសៀវភៅនេះគួរតែដាក់មាននៅចំពោះមុខអង្គជំនុំជម្រះ ជាពិសេសដូចដែលមេធាវីការពារក្តីបានលើកឡើងទៅលើរឿងរ៉ាវទាំងឡាយនៅក្នុងតុលាការនេះ ថាតើវាអាចជាស្ថានសម្រាលទោសចំពោះការសុំទោសនិងវិប្បសារី ហើយនិងការទទួលស្គាល់អំពីពិរុទ្ធភាពដែលបានបង្ហាញដោយជនជាប់ចោទនេះក៏អត់ ។ លេខ ERN របស់សៀវភៅនេះ ដែលយើងបានដាក់ចូលទៅក្នុងសំណុំរឿងមានដូចតទៅ៖ លេខERN ជាភាសាអង់គ្លេស គឺបានន័យថា យើងដាក់សៀវភៅនេះទាំងមូលតែម្តងចូលទៅក្នុងសំណុំរឿង គឺមានលេខ 00369932 រហូតដល់លេខ 00370270 ។ នៅលេខ ERN ជាភាសាខ្មែរគឺមានលេខ 00377027 រហូតដល់លេខ 00370539 ។

លោក លោកស្រីចៅក្រម អាចជម្រាបសួរខ្ញុំដែលឲ្យខ្ញុំសួរសំណួរទៅខ្លួនឯងថា តើសៀវភៅនេះគួរតែដាក់ទាំងមូលចូលទៅក្នុងសំណុំរឿង ឬក៏យ៉ាងម៉េច? ហើយវាជាបន្ទុកទៅដល់អង្គជំនុំជម្រះ ឬយ៉ាងម៉េច? ដើម្បីវាយតម្លៃជាភស្តុតាង ។ លោក លោកស្រី ចៅក្រម ខ្ញុំសូមលើកឡើងថា ចំណុចនេះវាជាការលើកលែង ។ សៀវភៅមួយនេះ ត្រូវបាននិពន្ធឡើងដោយអ្នកកាសែតដែលបានរកឃើញជនជាប់ចោទ និងជីវិតរបស់ជនជាប់ចោទ គាត់បានរៀបរាប់នៅក្នុងហ្នឹង ។ ដូច្នេះ ហើយយើងខ្ញុំសូមស្នើសុំសហចៅក្រមស៊ើបអង្កេតឲ្យកោះហៅ នីក ដងឡុប ជាអ្នកនិពន្ធសៀវភៅនេះជាសាក្សីទៅលើអង្គហេតុ ឬក៏ក្នុងនាមជាអ្នកជំនាញ ។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតនៅពេលដែលយើងបានដាក់សំណើនេះនៅពេលដែលបញ្ចប់កិច្ចស៊ើបសួរបានលើកឡើងថា សហព្រះរាជអាជ្ញាគួរតែលើកសំណើនេះក្នុងជំនុំជម្រះ ដោយសារតែសហចៅក្រមស៊ើបអង្កេតកំពុងតែស្ថិតនៅក្នុងដំណាក់កាលបិទកិច្ចស៊ើបសួរ និងដាក់ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះឲ្យលឿន។ យើងខ្ញុំក៏បានស្នើសុំនៅចំពោះមុខអង្គជំនុំជម្រះឲ្យធ្វើការកោះហៅសាក្សី នីក ដងឡុប នេះផងដែរ ។

[១៤:០៣:៥៩]

អង្គជំនុំជម្រះ! លោក លោកស្រីចៅក្រម បានសន្និដ្ឋាននិងសម្រេចថា វាមិនសមរម្យក្នុងការកោះហៅសាក្សីនេះទេ។ ដូច្នេះហើយដោយពិចារណាទៅលើចំណុចទាំងអស់នេះ យើងខ្ញុំស្នើសុំដូច្នេះថាដោយសារតែសៀវភៅនេះបានយោងលើ-- ដូច្នេះ ហើយវាជាផលប្រយោជន៍នៃការរកយុត្តិធម៌ដែលត្រូវ

មានសៀវភៅដាក់ចំពោះមុខអស់លោក លោកស្រីចៅក្រម ។ ដូច្នេះ ទាក់ទងទៅនឹងចំណុច ខ្ញុំសូមលើកចំណុចចំនួនពីរ បន្ទាប់មកខ្ញុំនឹងបញ្ចប់សេចក្ដីសន្និដ្ឋានរបស់ខ្ញុំ ។

ការលើកឡើងរបស់ខ្ញុំ ទីមួយ គឺខ្ញុំយើងខ្ញុំបានដាក់សំណើនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតស្ដីពីការដាក់ឯកសារដែលវាស្ថិតនៅក្នុងយល់ដឹង ការប្រាប់ជូនសាធារណជន ។ សហចៅក្រមស៊ើបអង្កេតទាំងពីរ គឺគាត់អនុវត្តទៅតាមប្រព័ន្ធច្បាប់ស៊ីវិលនិងយុត្តាធិការជាតិ ហើយបានប្រាប់មកសហព្រះរាជអាជ្ញានៅក្នុងដីការបស់ពួកគាត់ ដែលចុះនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ ។ នៅក្នុងនុំង គឺមានលើកឡើងអំពីការរបាយការណ៍ដែលថា ការជំនុំជម្រះមួយនេះ គឺផ្អែកទៅលើភស្ដុតាងសាក្សីរស់និងស្មារតីការចងចាំរបស់សាក្សីនិងជនរងគ្រោះ ។ ដូច្នេះហើយ ក្រោយមកចៅក្រម ឬក៏មន្ត្រីទាំងឡាយ គឺនៅពេលដែលគាត់ធ្វើការសម្រេចនោះ គាត់អាចពិនិត្យលើសក្ខីកម្មទាំងអស់នោះបាន ។

យើងមិនមែនលើកឡើងថា វាជាយុត្តិសាស្ត្រសម្រាប់យើងទាំងអស់គ្នានោះទេ ។ ប៉ុន្តែ យើងខ្ញុំលើកឡើងថា ឯកសារនោះគឺជាឯកសារសាធារណៈ ហើយបានយោងយ៉ាងច្រើននៅក្នុងដំណាក់ស៊ើបអង្កេតនិងការជំនុំជម្រះ ហើយជនជាប់ចោទគាត់បានពិនិត្យមើល ហើយក៏មានការដាក់ដេញ ឲ្យដេញដោលផងដែរ ។ ដូច្នេះហើយឯកសារទាំងអស់នេះ គួរតែដាក់បញ្ចូលទៅក្នុងការពិចារណារបស់ចៅក្រមក្នុងការសរសេរសាលក្រម ។

[១៤:០៦:១១]

លោកស្រីចៅក្រម! នេះជាការសង្កេតបឋមរបស់ខ្ញុំ ប្រសិនបើមេធាវីការពារក្ដីមានការជំទាស់ណាមួយនោះ ឬក៏អង្គជំនុំជម្រះមានសំណួរណាមួយនោះ ខ្ញុំស្វាគមន៍ដោយគោរព ស្វាគមន៍នឹងរង់ចាំឆ្លើយទៅលើសំណួរទាំងឡាយដែលដាក់ជូនយើងខ្ញុំ ។

សូមអរគុណ ខ្ញុំដាក់ជូននូវសេចក្ដីសន្និដ្ឋានរបស់ខ្ញុំដោយគោរព ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្ដីមានអ្វីធ្វើការសង្កេត ឬក៏ជំទាស់អ្វីទេនូវការដាក់ឯកសាររបស់សហព្រះរាជអាជ្ញានេះ?

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោកប្រធាន និងលោកចៅក្រមជាតិ និងអន្តរជាតិ និងសូមគោរពអង្គសវនាការទាំងមូល ។ ខ្ញុំគ្រាន់តែលើកជាមតិឡើង ហើយការសម្រេចវាជាឆន្ទានុសិទ្ធិ

របស់លោកចៅក្រម បើលោកចៅក្រមសម្រេចយ៉ាងណា ខ្ញុំសូមគោរពទៅតាមនោះ ក៏ប៉ុន្តែខ្ញុំសុំគ្រាន់តែលើកមតិឡើង ។ ខ្ញុំលើកនេះ លើកចំពោះជម្លោះប្រដាប់អាវុធរវាងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនិងរដ្ឋាភិបាលវៀតណាម។ អ៊ីចឹងជម្លោះប្រដាប់អាវុធនេះវាកើតឡើងរវាងថ្នាក់កំពូលរដ្ឋាភិបាលប្រទេសខ្មែរនិងរដ្ឋាភិបាលរបស់វៀតណាម ហើយបើយើងបញ្ចូលឯកសារនេះទៅក្នុងសំណុំរឿងលេខ០១ ដើម្បីទម្លាក់កំហុសទៅឲ្យ តាឌុច វាហាក់ដូចជាធ្ងន់ពេកមិនអាចទទួលយកបាន ។ នេះម្យ៉ាង ។

ម្យ៉ាងទៀត ខ្ញុំធ្លាប់បានជូនជាមតិថា បើសិនជាដាក់សំណុំឯកសារនេះទៅក្នុងសំណុំរឿងលេខ ០០២ ប្រហែលជាអាចត្រឹមត្រូវជាង ពីព្រោះជម្លោះប្រដាប់អាវុធរវាងរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលវៀតណាម គឺវាកើតរវាងរដ្ឋាភិបាលនិងរដ្ឋាភិបាល វាមិនមែនកើតឡើងដោយតា ឌុច ទេ ។ ហើយរដ្ឋាភិបាលកម្ពុជា គឺវាមានបួននាក់ មាន ប៉ុល ពត, មាន អៀង សារី, មាន វន វេត និង សុន សេន ស្លាប់អស់បីហើយ នៅសល់តែ អៀង សារី មួយ ។ អ៊ីចឹងបើដាក់ទៅក្នុងសំណុំរឿងលេខ០០២ ចាំសួរ អៀង សារី ប្រហែលអាចជាល្អជាង ។ នេះខ្ញុំជូនជាយោបល់ពេលនោះក៏ធ្លាប់អ៊ីចឹងដែរ ។ ហើយខ្ញុំសូម-- ពេលនោះ ខ្ញុំបានបញ្ជាក់ថែមទៀតកន្លងមកថា បើសិនណាជាយើងយករឿងជម្លោះប្រដាប់អាវុធរវាងកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យនិងកងទ័ពរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម យកមកកាត់ទោសតែខ្មែរ ហាក់ដូចជាមិនមានយុត្តិធម៌ ។ ខ្មែរស្លាប់អស់មួយគរគោកហើយ មកកាត់ថែមពីលើទម្លាក់កំហុសលើហ្នឹងទៀត ខ្ញុំនិយាយនេះ ខ្ញុំមិនមែនកាន់ជើងរបបកម្ពុជាប្រជាធិបតេយ្យទេខ្ញុំអត់កាន់ជើង ខ្ញុំស្អប់របបនុ៎ងណាស់ ។ ប៉ុន្តែយើងយ៉ាងណាក៏ដោយ យើងត្រូវរកដើម្បីបង្ហាញយុត្តិធម៌ដល់សាកលលោកក៏ដូចជាប្រជាជនកម្ពុជាដែរ ពីព្រោះថា បើយកជម្លោះប្រដាប់អាវុធហ្នឹងយកមកដាក់កាត់នៅហ្នឹង ទៅលើរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ចុះរដ្ឋាភិបាលរបស់សង្គមនិយមវៀតណាមដែលកាប់សម្លាប់កងទ័ពកម្ពុជាប្រជាធិបតេយ្យដែលចូលក្នុងទឹកដីវៀតណាម ម៉េចក៏គេចោទថាឧក្រិដ្ឋកម្មសង្គ្រាម? ម៉េចក៏មិនយកមកកាត់ទោស? មកកាន់ទោសអីតែទ័ពខ្មែរ គេចូលមកទឹកដីខ្មែរ ខ្មែរចាប់ចាប់យកមកសម្លាប់ចោទ រួចចុះខ្មែរក៏រងកម្មម្ល៉េះ? នេះជាចំណាប់អារម្មណ៍របស់ខ្ញុំ ។

[១៤:១០:២៧]

អ៊ីចឹងទេ ខ្ញុំសំណូមពរថា គួរតែដាក់សំណុំ-- អាដែងជម្លោះប្រដាប់អាវុធនេះទៅក្នុងសំណុំរឿងលេខ០០២ ហាក់ដូចជាត្រឹមត្រូវជាង ។ ឯការសម្រេចយ៉ាងណានេះ ក៏ស្រេចតែឆន្ទានុសិទ្ធរបស់លោកចៅក្រម ខ្ញុំគ្រាន់តែមានមតិទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីជាទីគោរព! ខ្ញុំសូមផ្តល់ជាយោបល់បន្ថែមទៅលើចំណុចអម្បាញ់មិញ ។ បន្ទាប់ពីការដាក់សន្និដ្ឋានយ៉ាងវែងពីខាងការិយាល័យសហព្រះរាជអាជ្ញា ខ្ញុំសូមលើកឡើងដោយសង្ខេប ហើយខ្ញុំមិនមានការលើកឡើងដោយឆោតល្ងង់ទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធនោះទេ ។ រយៈពេលប្រាំមួយខែហើយដែលខ្ញុំបាននិយាយជាមួយនឹងការិយាសហព្រះរាជអាជ្ញា ប្រសិនបើការិយាល័យសហព្រះរាជអាជ្ញាមានបំណងក្នុងការដាក់ឯកសារសារព័ត៌មានជាងពីររយសារព័ត៌មាននោះ ដែលមានតែភាសាអង់គ្លេស នេះជាការទទួលខុសត្រូវរបស់ខាងសហព្រះរាជអាជ្ញា ។ ប៉ុន្តែ ខាងខ្ញុំដែលស្នើសុំឲ្យលោកបំពេញការងារនោះ គឺឲ្យបង្កើតយ៉ាងហោចណាស់ឯកសារសង្ខេបមួយច្បាប់ដែលនិយាយអំពីខ្លឹមសារនៃការដកស្រង់ចេញពីសារព័ត៌មានទាំងអស់នោះ ថាតើមានការលើកឡើងអ្វីខ្លះ? ដើម្បីឲ្យខ្ញុំបានដឹងថា លោកបានបង្កើតឯកសារផ្អែកទៅលើចំណុចហ្នឹង មិនមែនទៅលើសារព័ត៌មាន មិនមែនទៅលើព័ត៌មាន ឬក៏អត្ថបទឯកសារផ្សេង ។ ដូច្នេះហើយគឺជាការទទួលខុសត្រូវរបស់លោក ហើយខ្ញុំរយៈពេលប្រាំមួយខែហើយរង់ចាំឯកសារសង្ខេបមួយទំព័រនេះ ហើយពេលនេះ យើងមិនទាន់ទទួលបាននៅឡើយ ។

[១៤:១២:៥១]

ដូច្នេះហើយអ្វីដែលខ្ញុំស្នើសុំនោះ គ្រាន់តែចង់ឲ្យលោកធ្វើការសង្ខេបទៅលើឯកសារសារព័ត៌មានដែលលោកដកស្រង់ចេញពីសារព័ត៌មានជាងពីររយអត្ថបទ ហើយដែលលោកបានលើកឡើងថា បង្ហាញពីជម្លោះប្រដាប់អាវុធដែលលោក ការ សាវុត្ថ បានលើកឡើង ។ ដូច្នេះ ហើយគួរតែពិចារណាជម្លោះប្រដាប់អាវុធនៅក្នុងសំណុំរឿងលេខ០២ ។ ដូច្នេះហើយខ្ញុំនាពេលនេះកំពុងតែរង់ចាំសេចក្តីសង្ខេបមួយទំព័រដែលលោកផលិតជូនយើងខ្ញុំ ។

យើងខ្ញុំសូមលើកឡើងទាក់ទងទៅនឹងការពិភាក្សានៅទីនេះ ។ យើងដឹងហើយខាងការិយាល័យសហព្រះរាជអាជ្ញាគាត់កំពុងតែពិចារណា និងសិក្សាទៅលើឯកសារសារព័ត៌មាន ហើយចំពោះខ្ញុំផ្ទាល់បានបង្ហាញការយល់ឃើញថា ឯកសារព័ត៌មានជាងពីររយទំព័រនោះហាក់ដូចជាវាលើស ហើយអ្វីដែលខ្ញុំរកឃើញនោះ នៅក្នុងការយល់ព្រមរបស់ខ្ញុំផងដែរនោះ គឺយើងឃើញមានតែសៀវភៅប្រាំក្បាល មាន

ឯកសាររបស់យោធា តេឡេក្រាមនិងឯកសារវីដេអូខាងយោធា ។ ហើយខ្ញុំមិនដែលយល់ព្រមទៅលើឯកសារទាំងអស់នោះទេ ខ្ញុំមិនដែលទាល់តែសោះតែម្តង ។ ដូច្នេះ ហើយយើងឃើញថា នៅពេលដែលខ្ញុំលើកឡើងថា ប្រសិនបើខាងសហព្រះរាជអាជ្ញាចង់ដាក់ឯកសារសារព័ត៌មានជាងពីររយឯកសារនោះគឺវាច្រើនពេក ប៉ុន្តែវាជាកាតព្វកិច្ច និងការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញាក្នុងការសង្ខេបមួយទំព័រជូនយើងខ្ញុំ ។ ហើយសូមឲ្យលោកកុំទាញផលប្រយោជន៍ពីចំណុចហ្នឹង ។ ដូច្នេះហើយកុំហាក់ដូចជាដាក់នូវឯកសារទាំងឡាយដែលខ្ញុំតាំងពីដើមមកខ្ញុំមិនមានការយល់ស្របទៅលើឯកសារទាំងអស់នោះ ។

នៅពេលនេះ គឺខ្ញុំលើកឡើងអំពីផែនទី ប៉ុន្តែខ្ញុំមិនមានការសង្កេតទៅលើចំណុចនេះទេ ។ ទៅលើចំណុចទីបី ដែលបានលើកឡើងខាងសហព្រះរាជអាជ្ញា គឺទាក់ទងទៅនឹងសក្ខីកម្ម និងយោបល់ដែលធ្វើដោយជនជាប់ចោទ ។

[១៤:១៥:២២]

សហព្រះរាជអាជ្ញាបានលើកឡើងអំពីឧបសម្ព័ន្ធ "ក" និងសំណើថ្មីរបស់សហព្រះរាជអាជ្ញា ហើយសហព្រះរាជអាជ្ញាហាក់ដូចជាមិនប្រាកដសោះក្នុងពេលដែលគាត់សំណើសុំដាក់ឯកសារពីមួយទៅមួយ ហើយខ្ញុំឃើញដែរ គឺគាត់បានដាក់សំណើនៅថ្ងៃទី១៩ សីហា ឆ្នាំ២០០៩ ដែលមាន១៥ទំព័រ ។ ហើយយើងមិនទាន់មានឃើញការបកប្រែជាភាសាបារាំងនៅឡើយទេ ហើយខ្ញុំមិនដឹងថាភាសាខ្មែរមានឬក៏អត់នោះទេ? ហើយចំពោះលក្ខខណ្ឌនៃការដាក់ឯកសារបែបនេះ គឺយើងមិនអាចទទួលយកបានឡើយ ។ ដូច្នេះ អ្វីដែលខ្ញុំយល់ពីការដាក់ពាក្យស្នើសុំនៅថ្ងៃទី១៩ ខែសីហា នោះខាងការិយាល័យសហព្រះរាជអាជ្ញាមានបំណងឲ្យសុំដាក់ឯកសារនុំងដាក់ចូលទៅក្នុងសំណុំរឿង គឺឯកសារនោះរួមមានរបាយការណ៍ និងការសួរចម្លើយ-- កំណត់ហេតុសួរចម្លើយរបស់សហចៅក្រមស៊ើបអង្កេត ។

ចំពោះខាងមេធាវីការពារក្តីយើងខ្ញុំពុំមានការជំទាស់ឡើងក្នុងការដាក់ជូនអង្គជំនុំជម្រះ ឬក៏ដាក់នៅចំពោះមុខសាលាដំបូងនៅរបាយការណ៍កំណត់ហេតុលាយលក្ខណ៍អក្សរសួរចម្លើយ ដែលធ្វើឡើងដោយជនជាប់ចោទនោះទេ ។ ដូច្នេះហើយការិយាល័យសហព្រះរាជអាជ្ញាគាត់មានឱកាស មានលទ្ធភាពក្នុងការជ្រើសរើសឯកសារទាំងឡាយ មានលេខ D-20 ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ ។ ដូច្នេះហើយខ្ញុំសូមទាញការចាប់អារម្មណ៍អង្គជំនុំជម្រះថា កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរចម្លើយទាំងអស់នោះ យើងខ្ញុំសូមដាក់ចូលទៅក្នុងសំណុំរឿងទីពីរ ។ យើងមិនគួរដាក់ចូលទៅក្នុងសំណុំរឿង

ទីមួយនោះទេ ។

[១៤:១៧:២៧]

ដូច្នេះយើងឃើញថា កំណត់ហេតុជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត យើងឃើញថា វាស្ថិតនៅក្នុងសំណុំរឿងលេខមួយនោះ គឺខ្ញុំទទួលយកចំពោះកំណត់ហេតុនៅក្នុងសំណុំរឿង០០១ ហើយចំពោះយោបល់ដែលបានលើកឡើងដោយជនជាប់ចោទ តាមសំណើរបស់សហចៅក្រមស៊ើបអង្កេត មិនថាវាជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុជាលាយលក្ខណ៍អក្សរទាំងអស់នោះ ឬក៏ផ្តល់ជូនដោយជនជាប់ចោទនោះទេ ។ ជាការពិត ឯកសារទាំងអស់នោះគឺជាការងារដែលសហស៊ើបអង្កេតធ្វើឡើងដើម្បីសន្សំពេលវេលា ។ ដូច្នេះហើយសហចៅក្រមស៊ើបអង្កេតគឺបានផ្តល់ឯកសារទាំងអស់នោះទៅកាន់ជនជាប់ចោទក្នុងវត្តមានរបស់សហព្រះរាជអាជ្ញា ដើម្បីឲ្យគាត់ផ្តល់យោបល់ ។ ដូច្នេះឯកសារទាំងអស់នោះ គឺស្ថិតនៅក្នុងសំណុំរឿងស៊ើបអង្កេត ហើយឯកសារទាំងអស់នោះ គឺយើងបានធ្វើការតវ៉ាទៅលើចំណុចនោះដែរ ។ ប៉ុន្តែ មេធាវីការពារក្តីយល់ស្របទៅលើការដាក់ឯកសារទាំងអស់នោះចូលទៅក្នុងសំណុំរឿង ។ ប៉ុន្តែ នៅពេលដែលយើងមើលទៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា លោកសហព្រះរាជអាជ្ញាបានភ្លេចទៅលើឯកសារកំណត់ហេតុការសម្តែងឡើងវិញចំនួនពីរ ហើយលោកបានលើកឡើងតិចទៅលើចំណុចនេះ ហើយខ្ញុំគិតថា វាជាឯកសារចម្បង ។

[១៤:១៩:០២]

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ដូច្នេះខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការពិចារណាឲ្យបានប្រុងប្រយ័ត្ន មិនត្រឹមតែកំណត់ហេតុសម្តែងឡើងវិញតែមួយនោះទេ គឺទាំងពីរគួរតែដាក់ចូលតែម្តង រួមទាំងកំណត់ហេតុនៅជើងឯកនិងស-២១ ផងដែរ ។ ដូច្នេះ យើងខ្ញុំស្នើសុំឲ្យការដាក់នូវឯកសារនោះក៏រួមទាំងខ្សែវីដេអូរនៃការសម្តែងឡើងវិញផងដែរ រួមទាំងរូបភាពខ្សែវីដេអូរដែលយើងបានបង្ហាញព្រឹកមិញនេះ ស្នើឡើងដោយខាងមេធាវីការពារក្តីផងដែរ ។

ចំពោះឧបសម្ព័ន្ធ “ខ” វិញដែលនៅក្នុងនោះយើងឃើញមានចម្លើយសាក្សីចំនួន៦៩ ដែលបានប្រមូលបាននៅក្នុងដំណាក់កាលស៊ើបអង្កេត ។ មេធាវីការពារក្តីពុំមានការជំទាស់នៅក្នុងការដាក់ឯកសារទាំងនេះទេ។ ប៉ុន្តែខ្ញុំហាក់ដូចជាភ្លេចនៅក្នុងឧបសម្ព័ន្ធទីពីរនេះ គឺខ្ញុំឃើញមានការលើកឡើងអំពីឯកសារចំនួន៦០ ប្រមូលបានពីស-២១ ដែលឯកសារនោះចោទប្រកាន់ ហើយខ្ញុំនិយាយចំណុចនេះឲ្យបានច្បាស់ដែលចោទប្រកាន់ថា វាជាចំណារដែលធ្វើឡើងដោយជនជាប់ចោទដែលរួមមានការបកប្រែអមមកជាមួយ

នូវឯកសារផងដែរ ។ ដូច្នេះហើយខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការកត់សម្គាល់ទៅលើអង្គហេតុដែលថា ខាងមេធាវីការពារក្តី គឺសូមធ្វើការជំទាស់យ៉ាងខ្លាំងទៅលើការដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារដែលបានប្រមូលមកពីស-២១ ដែលឯកសារទាំងអស់នោះមិនបានយកមកដេញដោលនៅចំពោះមុខអង្គសវនាការរបស់យើង ។ ហេតុអ្វីបានជាយើងពុំទទួលយក? ដោយសារតែនៅក្នុងដំណាក់កាលស៊ើបអង្កេត ហើយនិងការដេញដោលរបស់អង្គសវនាការរបស់យើង យើងទាំងអស់គ្នាចងចាំហើយថា យើងបានផ្ទៀក ហើយយើងឃើញថា មានកំហុសបកប្រែជាច្រើនទាក់ទងទៅនឹងឯកសារទាំងឡាយដែលប្រមូលបានមកពីស-២១ ។

[១៤:២២:០៥]

ហើយជាការពិតខ្ញុំចងចាំថា នៅក្នុងដំណាក់កាលស៊ើបអង្កេតវិញ យើងឃើញមានពេលមួយនោះដែលការិយាល័យសហព្រះរាជអាជ្ញាគាត់មានអំនួតក្នុងការប្រើពាក្យៗថា មានអំនួត ដែលគាត់បានប្រើព្រឹកមិញផងដែរ គឺគាត់មានអំនួតក្នុងការបង្ហាញនូវឯកសារដែលប្រមូលបាននៅស-២១ ហើយវាហាក់ដូចជាបង្ហាញថា វាមានហត្ថលេខារបស់ជនជាប់ចោទ ។ ហើយវាហាក់ដូចជាការដែលចុះហត្ថលេខានោះ គ្រាន់តែចុះនៅចុងទំព័រតែប៉ុណ្ណោះ ។ ដូច្នេះខ្ញុំជឿថា-- ខ្ញុំជឿតែទៅលើចំណុចមួយតែប៉ុណ្ណោះការដេញដោលរបស់យើងទល់មុខគ្នា ហើយមិនមាននរណាម្នាក់បដិសេធទេថា យើងឃើញជនជាប់ចោទសហការជាមួយនឹងសហចៅក្រមស៊ើបអង្កេត រួមទាំងអង្គជំនុំជម្រះសាលាដំបូងផងដែរ ចំពោះការសម្រេចទៅលើឯកសារទាំងឡាយដែលបានបង្ហាញជូនគាត់ ។ ដូច្នេះយើងសូមអរគុណទៅកាន់ ឌុច ហើយនិងការសហការរបស់គាត់ ដែលយើងអាចធ្វើការវិភាគទៅលើឯកសារទាំងឡាយដែលបានដាក់ជូនគាត់ ។ ដូច្នេះហើយយើងក៏សូមថ្លែងអំណរគុណចំពោះការពិនិត្យតទល់ផ្សេងៗ ដែលយើងអាចធ្វើការកំណត់ឃើញនូវកំហុសបកប្រែមួយចំនួនដែលមាននៅក្នុងឯកសារ ។

ដូច្នេះហើយ ខ្ញុំសូមលើកឡើងជូនសហព្រះរាជអាជ្ញាថា ខាងលោកមានរយៈពេលមួយឆ្នាំនៅក្នុងអំឡុងពេលស៊ើបអង្កេត បានន័យថាមួយឆ្នាំមុនពេលការជំនុំជម្រះ ។ ដូច្នេះ ហើយលោកមានជម្រើសលោកអាចធ្វើការជ្រើសរើសទៅលើសាក្សីចូលមកកាន់អង្គជំនុំជម្រះ ។ ដូច្នេះហើយលោកមានជម្រើសទៅលើទាំងអស់នេះ ដូច្នេះ ហើយលោកគួរតែដាក់ឯកសារទាំងអស់នោះដេញដោល ហើយយើងឃើញហើយថា លោកមិនបានធ្វើឡើង ហើយលោកនៅថ្ងៃនេះមិនអាចសុំការអនុញ្ញាតដើម្បីដាក់ឯកសារទាំងអស់នោះដែលយើងមិនមានការពិនិត្យដេញដោលគ្នាតទល់នោះទេ ។

ចំណុចចុងក្រោយចំពោះសៀវភៅរបស់លោក នីក ដងឡុប ។ ខ្ញុំនៅចាំថា ឌុច បានលើកឡើងទៅលើការគិតរបស់គាត់ ទៅលើសៀវភៅនេះ ជាពិសេសយ៉ាងហោចណាស់ក៏វាទាក់ទងទៅនឹងអត្ថបទមួយចំនួននៅក្នុងសៀវភៅ ។ ប៉ុន្តែ យើងនឹងអនុវត្តទៅតាមការយល់ឃើញ និងការតាំងសំណួររបស់អង្គជំនុំជម្រះ ។ ទាំងអស់នេះហើយ គឺជាការសង្កេតរបស់មេធាវីការពារក្តី ហើយមេធាវីការពារក្តីនៅពេលក្រោយ គឺសូមអនុញ្ញាតនៅក្នុងការបង្ហាញនៅឯកសារមួយចំនួនតូច ជាជាងការបង្ហាញនូវឯកសាររាប់រយឯកសារ ។

[១៤:២៥:២៩]

ជាថ្មីម្តងទៀតខ្ញុំមានការសោកស្តាយណាស់ ដែលសហព្រះរាជអាជ្ញាហាក់ដូចជាបង្ហាញថា វាមានភាពចាំបាច់ណាស់ដែលនៅពេលដែលសវនាការយើងដឹងហើយថា ជនជាប់ចោទគាត់បានបញ្ជាក់ទៅលើអង្គហេតុទាំងអស់ ។ ហើយសហព្រះរាជអាជ្ញាហាក់ដូចជាបង្ហាញអំពីហេតុផលនិងសារសំខាន់ក្នុងការបង្ហាញទៅលើឯកសារទាំងឡាយដែលគាត់ចង់ដាក់ ដែលឯកសារទាំងអស់នោះវាចំណាយធនធានច្រើននៅក្នុងការបកប្រែ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក អានីស អះមេដ៖**

សូមអរគុណលោកមេធាវីជាតិ និងមេធាវីអន្តរជាតិចំពោះការសង្កេត និងលើកឡើងរបស់លោកទាំងពីរ ។ នៅពេលដែលយើងគិតទៅលើយោបល់របស់លោក ខ្ញុំសូមលើកឡើងទៅលើយោបល់និងសង្កេតរបស់លោក ការ សារុត្ត ទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ ។ ជនជាប់ចោទនៅក្នុងសំណុំរឿងទីពីរដែលគួរតែយើងពិចារណាទៅលើបញ្ហាជម្លោះប្រដាប់អាវុធនេះ ដោយសារតែ ប៉ុល ពត និងមេដឹកនាំជាន់ខ្ពស់នៅថ្នាក់លើៗដែលគួរទទួលខុសត្រូវទៅលើករណីជម្លោះប្រដាក់អាវុធ មិនមែនជនជាប់ចោទ។ យើងគួរតែគិតពិចារណាទៅលើចំណុចនេះ លោក លោកស្រីចៅក្រមជាទីគោរព! ប៉ុន្តែបញ្ហាចោទរបស់ខាងសហព្រះរាជអាជ្ញានៅក្នុងការបង្ហាញឲ្យហួសពីវិមតិសង្ស័យ គឺថាប្រសិនបើបទចោទរបស់សហចៅក្រមស៊ើបអង្កេត គាត់ចោទប្រកាន់ទៅលើការរំលោភបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវនោះ យើងដឹងហើយថា ជនជាប់ចោទនេះគាត់ប្រឈមនឹងការចោទទៅលើឧក្រិដ្ឋកម្មមួយចំនួនដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ហើយនៅក្នុងបទចោទនោះ គឺបានតម្កល់ដោយអង្គបុរេជំនុំជម្រះ

ដែលក្នុងនោះមានការចោទប្រកាន់ទៅលើការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ ។

[១៤:២៧:៤៨]

មេធាវីការពារក្តីគាត់បានដឹងយ៉ាងច្បាស់ថា ក្នុងការបង្ហាញការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ យើងត្រូវតែបង្ហាញក្នុងនាមជាសហព្រះរាជអាជ្ញាដែលសហព្រះរាជអាជ្ញាត្រូវតែធ្វើ។ យើងត្រូវតែបង្ហាញអំពីអាទិភាពនៃជម្លោះប្រដាប់អាវុធ ហើយនិងភាពពាក់ព័ន្ធគ្នាដែលទាមទារឲ្យយើងបង្ហាញរវាងឧក្រិដ្ឋកម្មដែលជនជាប់ចោទបានប្រព្រឹត្តឡើងពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធនោះ ។

ប្រសិនបើយើងមិនអាចបង្ហាញអំពីទំនាក់ទំនងនិងបង្ហាញអំពីជម្លោះប្រដាប់អាវុធអន្តរជាតិនោះទេ បទចោទទៅលើការរំលោភបំពានអនុសញ្ញាទីក្រុងហ្សឺណែវនឹងមិនអាចចោទប្រកាន់បានឡើយ ។ ខ្ញុំមិនចង់លើកឡើងអំពីប្រវត្តិនៃរឿងក្តីដែលវាបានបញ្ជូនមកលោក លោកស្រីចៅក្រម នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ មុនពេលសហចៅក្រមស៊ើបអង្កេត មុនពេលដែលអស់លោក លោកស្រីចៅក្រមនៅក្នុងអង្គជំនុំជម្រះនេះ ជនជាប់ចោទគាត់គួរតែចោទប្រកាន់នៅក្នុងបទចោទក្នុងស្រុកតាមច្បាប់ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។

មេធាវីការពារក្តីគាត់បានជំទាស់ទៅលើការចោទប្រកាន់តាមច្បាប់ជាតិ ។ ហើយប្រសិនបើជនជាប់ចោទ ត្រូវបានចោទប្រកាន់ពីបទចោទក្នុងច្បាប់ស្រុក-- ច្បាប់ជាតិវិញ អ៊ីចឹងយើងឃើញថា ការទំនាក់ទំនងរវាងជម្លោះប្រដាប់អាវុធអន្តរជាតិមិនចាំបាច់យើងបង្ហាញឡើយ ។ មេធាវីការពារក្តី គឺមិនបានតវ៉ាទៅលើបទចោទតាមច្បាប់ក្នុងស្រុកដែលវាទាក់ទងទៅនឹងច្បាប់ជម្លោះប្រដាប់អាវុធអន្តរជាតិដែលយើងឃើញហើយថា មានបទចោទទៅលើជនជាប់ចោទ ។ ដូច្នេះហើយយើងគោរពទៅតាមច្បាប់អន្តរជាតិ ហើយដែលយើងត្រូវបង្ហាញអំពីជម្លោះប្រដាប់អាវុធអន្តរជាតិ ។

លោក លោកស្រីចៅក្រម គឺខ្ញុំមិនលើកឡើងទៅលើយុត្តិសាស្ត្រ ឬទឡ្ហីករណ៍ផ្លូវច្បាប់ច្រើនជូនអស់លោក លោកស្រីចៅក្រមនោះទេ ។ ប៉ុន្តែ គឺខ្ញុំសូមលើកឡើងដោយសង្ខេបទៅលើជម្លោះប្រដាប់អាវុធអន្តរជាតិតាមទៅអ្វីដែលមានសរសេរនៅក្នុងសាលក្រមដែលនិយាយអំពីច្បាប់អន្តរជាតិ ។ សាលាឧទ្ធរណ៍របស់តុលាការយូហ្គោស្លាវី នៅក្នុងរឿងក្តី តាឌីក ។ សាលាឧទ្ធរណ៍មានចៅក្រមប្រាំរូប ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំសូមទោសដែលបានខ្ញុំឡើងមកជំអាក់ខាងសហព្រះរាជអាជ្ញា ប៉ុន្តែខ្ញុំយល់ថា ពេលនេះមិនមែនជាពេលក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ចុងក្រោយនោះទេ ហើយពេលនេះក៏មិនមែនជាពេលវេលាក្នុងការបង្ហាញអំពីឧក្រិដ្ឋកម្មសង្គ្រាមនោះដែរ ។ នៅទីនេះយើងមិនមែនធ្វើការកាត់ក្តីទៅលើឧក្រិដ្ឋកម្មសង្គ្រាមនោះទេ ។ ដូច្នេះហើយខ្ញុំមិនយល់ថា អ្វីដែលសហព្រះរាជអាជ្ញាកំពុងតែធ្វើនោះទេ ។

**លោក អានីស អះមេដ៖**

លោកចៅក្រម ខ្ញុំមិនមែននៅទីនេះដើម្បីធ្វើការបង្ហាញ ឬក៏បង្រៀនដល់លោកបណ្ឌិតផ្នែកច្បាប់នោះទេ ។ ប៉ុន្តែ ខ្ញុំគ្រាន់តែចង់លើកឱ្យលោក លោកស្រីបានដឹងអំពីតម្រូវការនៃឯកសារមួយចំនួន ដើម្បីបង្ហាញអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធតែប៉ុណ្ណោះ ។ ហេតុដូច្នេះហើយបានជាខ្ញុំសូមអានអំពីនិយមន័យនៃជម្លោះប្រដាប់អាវុធ ហើយដែលខ្ញុំនឹងមិនអានឱ្យលម្អិតទេទៅតាមសំណើរបស់ខាងមេធាវីការពារក្តីនោះ ។ ប៉ុន្តែនៅក្នុងសេចក្តីសម្រេចរបស់ ស្តាឌីក នោះ គឺមានការបង្ហាញថា ត្រូវតែមានអំពើហិង្សាដែលអូសបន្លាយពេលរវាងរដ្ឋពីរ ។ ដូច្នេះ ដើម្បីធ្វើការបង្ហាញអំពីអំពើហិង្សា ដែលអូសបន្លាយរវាងរដ្ឋនោះ នៅក្នុងអំឡុងពេលបីឆ្នាំប្រាំបីខែនិងម្ភៃថ្ងៃ ដែលយើងកំពុងតែប្រឈមមុខក្នុងសវនាការរបស់អង្គជំនុំជម្រះយើងនេះ គឺយើងចាំបាច់ត្រូវការបង្ហាញនូវភស្តុតាងដើម្បីបង្ហាញអំពីនិរន្តរភាព អំពីជម្លោះការប្រយុទ្ធគ្នា ការប៉ះទង្គិចគ្នា ដោយសារទំហំធំតូច ដើម្បីបង្ហាញឱ្យបានពេញលេញនូវជម្លោះប្រដាប់អាវុធ នៅក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់តុលាការនេះ ។ ដូច្នេះ អត្ថបទសារព័ត៌មានអស់ទាំងនេះ គឺមិនមែនជាអត្ថបទដែលនិយាយដដែលៗនោះទេ ប៉ុន្តែ គឺជាឯកសារដែលចាំបាច់ត្រូវតែមានដើម្បីបង្ហាញអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ ដែលបានអូសបន្លាយពេលវេលារវាងរដ្ឋពីរនោះ ដូចជារដ្ឋដែលជាប្រទេសកម្ពុជានិងវៀតណាមនោះ ។

ដូច្នេះហើយ នេះគឺជាការស្នើរបស់ខាងសហព្រះរាជអាជ្ញា ដែលថា អ្វីដែលយើងដាក់នោះ គឺមិនមែនជាការនិយាយដដែលៗនោះទេ ប៉ុន្តែគឺជាតម្រូវការចាំបាច់ ។ បើសិនជាលោកប្រធាន មានគោលបំណងក្នុងការធ្វើការសន្និដ្ឋានអំពីអត្ថិភាព នៃជម្លោះប្រដាប់អាវុធ ដែលអាស្រ័យទៅលើឯកសារតែមួយនោះ ឬមួយក៏ចម្លើយនៃការទទួលស្គាល់របស់ជនជាប់ចោទនោះ គឺថាមិនអាចនឹងទទួលយកបានទេពីចៅក្រមណាក៏ដោយ ដោយថាការទទួលស្គាល់របស់ជនជាប់ចោទនោះ អាចបង្ហាញអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធនៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់តុលាការនេះ ។

[១៤:៣៣:៥៤]

ទាក់ទងទៅនឹងសេចក្តីសង្ខេប លោក លោកស្រីចៅក្រម បានបង្ហាញនៅក្នុងឯកសារថ្ងៃទី ២៩ ខែ៤ ឆ្នាំ២០០៩ ដែលជាឯកសារសង្ខេបមួយសន្លឹក អំពីអ្វីដែលមាននៅក្នុងឧបសម្ព័ន្ធនោះ គឺតាមពិតឯកសារនៅក្នុងឧបសម្ព័ន្ធហ្នឹង គឺជាឯកសារដែលបានប្រមូលផ្តុំឡើង ចងក្រងឡើង ហើយដោយពេញលេញ គឺបានរៀបរាប់យ៉ាងពេញលេញនៅក្នុងឯកសារ E61 ដែលចុះនៅថ្ងៃទី ២៩ ខែមេសា ២០០៩ នោះ ។ បើសិនជាមេធាវីការពារក្តីមានបំណងប្រាថ្នា ហើយបើសិនជាការិយាល័យសហព្រះរាជអាជ្ញាខ្លួនឯងផ្ទាល់ នឹងផ្តល់ជូននូវសេចក្តីសង្ខេបមួយទៀតឲ្យដល់មេធាវីការពារក្តី ដើម្បីឲ្យខាងពួកគាត់សប្បាយចិត្តអំពីសំណើនេះ ។

លោក លោកស្រីចៅក្រម គឺថាខាងសហព្រះរាជអាជ្ញាពុំមានគោលបំណងក្នុងការលុបចោលនូវអត្ថបទ ឬក៏របាយការណ៍នៃការសម្តែងឡើងវិញនោះទេ ហើយខាងសហព្រះរាជអាជ្ញាសូមបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនេះថា គឺឯកសារទីពីរនៃរបាយការណ៍នៃការសម្តែងឡើងវិញ ឬក៏ឯកសារពាក់ព័ន្ធនានាគួរតែត្រូវបានដាក់បញ្ចូលទាំងអស់ សន្មតថាដាក់នៅចំពោះមុខអង្គជំនុំជម្រះនេះ ។ ហើយទាក់ទងទៅនឹងសៀវភៅរបស់លោក នីក ដងឡុប គឺថាយើងជាសហព្រះរាជអាជ្ញាមិនបានស្នើថា លោក លោកស្រីចៅក្រមគួរតែពឹងអាស្រ័យទៅលើសៀវភៅហ្នឹង នៅក្នុងការធ្វើសេចក្តីវិនិច្ឆ័យចុងក្រោយរបស់លោក លោកស្រីចៅក្រម គឺយើងស្នើឲ្យលោក លោកស្រីចៅក្រម ធ្វើការពិចារណាទៅលើសៀវភៅនោះ ហើយគឺវាជាសេចក្តីសន្និដ្ឋានរបស់លោក លោកស្រីចៅក្រមផ្ទាល់ទេ ក្នុងការសន្និតថា តើតែគួរយកបាន-- ទទួលយកបានសៀវភៅនោះជាភស្តុតាងឬក៏អត់? គឺមានន័យថាលោក លោកស្រីចៅក្រមអាចធ្វើការពិនិត្យទៅលើសៀវភៅនោះ ក៏ដូចជាទៅលើឯកសារនានា ដែលបានដាក់បង្ហាញជូននៅចំពោះមុខអង្គសវនាការ ដើម្បីធ្វើសេចក្តីវិនិច្ឆ័យនៅចុងបញ្ចប់នៃសវនាការ ។

[១៤:៣៦:០៦]

ចំណែកចំណុចចុងក្រោយរបស់ខ្ញុំ អាចជាចំណុចប្រទាញប្រទង់មួយចំនួនពីខាងមេធាវីការពារក្តីនោះ គឺទាក់ទងទៅនឹងចំណាររបស់ជនជាប់ចោទ លើឯកសារនានាដែលបានធ្វើឡើងនៅស-២១ ។ ចំណុចដែលងាយស្រួលនឹងធ្វើសម្រាប់សហព្រះរាជអាជ្ញានោះ គឺថាត្រូវវិលត្រឡប់ទៅការិយាល័យរបស់ខ្លួនវិញ ហើយពិនិត្យមើលនូវឯកសារអស់ទាំងហ្នឹង ដែលឯកសារនោះវាមានមួយចំនួនដែលត្រូវបានដាក់ជូន ដាក់នៅចំពោះមុខជនជាប់ចោទ និងសាក្សីមួយចំនួនហើយ ទាំងក្នុងអំឡុងពេលស៊ើបអង្កេត

ទាំងនៅក្នុងអំឡុងពេលសវនាការលើអង្គសេចក្តីនៅចំពោះមុខអង្គជំនុំជម្រះនេះ ។

ដូច្នេះជាថ្មីម្តងទៀត យើងខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមធ្វើការពិចារណាទៅលើឯកសារអស់ទាំងនុ៎ង ហើយមិនមែនមានន័យថា ឯកសារអស់ទាំងហ្នឹង ទាំងអស់គួរតែទទួលយកធ្វើជាភស្តុតាងដើម្បីធ្វើការវិនិច្ឆ័យទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទនោះទេ ។ ដូច្នេះយើងខ្ញុំសូមស្នើថា ទាក់ទងទៅនឹងឧបសម្ព័ន្ធ "ឃ" យើងខ្ញុំនឹងត្រឡប់ទៅការិយាល័យរបស់យើងវិញ នឹងធ្វើបញ្ជីថ្មីមួយទៀត ហើយនិងធ្វើការពិភាក្សាជាថ្មីម្តងទៀត ជាមួយមេធាវីការពារក្តី ដើម្បីបង្ហាញនូវបញ្ជីដែលអាចទទួលបានទាំងពីរភាគី ហើយគឺថាយើងនឹងអាចធ្វើបានក្នុងពេលឆាប់ៗនេះ ដោយទាក់ទងទៅនឹងអ្វីដែលបានលើកឡើងដោយខាងមេធាវីការពារក្តីផងដែរ ។

យើងនៅតែរក្សាគោលជំហរថា ឯកសារអស់ទាំងនេះ គឺជាឯកសារដែលមានសារសំខាន់បំផុត ហើយដែលវាពាក់ព័ន្ធដោយផ្ទាល់ និងជាភស្តុតាងដ៏ប្រសើរបំផុតដែលតុលាការនេះមាននៅចំពោះមុខរបស់ខ្លួន ពីព្រោះថា សវនាការដែលមានទំហំនិងវិសាលភាពធំបែបនេះ ក៏ដូចជាសវនាការនៅ នូរឹមប៊ឺក ដែរ គឺអាស្រ័យតែទៅលើភស្តុតាងតែប៉ុណ្ណោះ ។ ពីព្រោះមិនមានសាក្សីណាមួយ ឬក៏ជនជាប់ចោទណាមួយអាចផ្តល់នូវរូបភាព ឬក៏ទ្រង់ទ្រាយពេញនូវអំពីអ្វីដែលកើតឡើងនៅស-២១នោះទេ និងអំពីតួនាទី និងវិសាលភាពនៃតួនាទី និងទំហំការងាររបស់ជនជាប់ចោទនៅក្នុងអំឡុងពេលបីឆ្នាំប្រាំបីខែម្ភៃថ្ងៃនោះទេ។

ដូច្នេះ គឺយើងត្រូវតែអាស្រ័យទៅលើភស្តុតាងដែលជាឯកសារនោះ ហើយទាក់ទងទៅនឹងឧបសម្ព័ន្ធ "ឃ" នោះគឺសូមឲ្យអនុញ្ញាតឲ្យខ្ញុំមានពេលមួយសប្តាហ៍ ដើម្បីធ្វើការពិភាក្សាជាមួយមេធាវីការពារក្តីមុននឹងយើង-- ខ្ញុំនឹងអាចចេញជាបញ្ជី*លីស្ត* ថ្មីមួយទៀតដាក់ជូននៅចំពោះមុខអង្គសវនាការ ។

ខ្ញុំសង្ឃឹមថា ខ្ញុំបានបំពេញបំណង ឬក៏ឆ្លើយតបឲ្យបានពេញលេញហើយទៅលើអ្វីដែលបានលើកឡើងដោយមេធាវីការពារក្តី ។ សូមអរគុណលោកប្រធាន ។

[១៤:៣៩:០១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រមហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំចង់លើកឡើងនូវសំណួរមួយចំនួនសម្រាប់ភាគីពាក់ព័ន្ធនានាទៅលើបញ្ហាដែលមាននៅចំពោះមុខនេះ គឺយើងមានឯកសារមួយចំនួន ។ ឯកសារមួយនោះគឺជាផែនទី

ហើយខ្ញុំយល់ច្បាស់ហើយថា គឺមានការព្រមព្រៀងគ្នារវាងភាគីទាំងពីរនេះក្នុងការដាក់ផែនទីនេះនៅចំពោះមុខអង្គសវនាការ និងមានឯកសារប្រភេទទីពីរ ទៅតាមសំណើរបស់សហព្រះរាជអាជ្ញា គឺមានអត្ថិភាពនៃជម្លោះប្រដាប់អាវុធ ។

អ្វីដែលខ្ញុំយល់ គឺថាចំណុចនេះ គឺជាគោលការណ៍ត្រូវបានជំទាស់ដោយមេធាវីការពារក្តីដោយថាឯកសារអស់ទាំងហ្នឹងវាមិនពាក់ព័ន្ធទៅនឹងសំណុំរឿងទីមួយនេះទេ ពីព្រោះអី? មេធាវី-- អ្នកដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យនោះ គឺវាមាននៅក្នុងសំណុំរឿងទីពីរ ហើយគឺតុលាការអន្តរជាតិដែលត្រូវធ្វើការកាត់សវនាការទៅលើឧក្រិដ្ឋកម្មសង្គ្រាមនោះ វាជារឿងមួយផ្សេងទៀត ។ ហើយមេធាវីការពារក្តីរបស់ជនជាប់ចោទហ្នឹង គឺអាចអនុញ្ញាតឲ្យខាងអង្គជំនុំជម្រះនេះ ធ្វើសេចក្តីសន្និដ្ឋាន ឬក៏សេចក្តីសម្រេចរបស់ខ្លួនទៅលើជម្លោះប្រដាប់អាវុធនេះ ហើយបើតាមខ្ញុំយល់គឺមានអត្ថបទសារព័ត៌មានហ្នឹងចំនួនពីររយ ហើយដែលមិនត្រូវបានធ្វើសេចក្តីសង្ខេបឲ្យបានសមរម្យ ឬក៏ត្រឹមត្រូវនោះទេ ហើយក៏មិនទាន់ត្រូវបានគេកំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់ដែរ ។

ដូច្នេះ គឺយើងអាចមានលទ្ធភាពពីរក្នុងការដាក់ឯកសារនៅចំពោះមុខអង្គសវនាការ ។ ទីមួយគឺត្រូវធ្វើជាសេចក្តីសង្ខេប ឬក៏ត្រូវផ្តល់អត្តសញ្ញាណឲ្យបានច្បាស់លាស់ ។ ក៏ប៉ុន្តែ ខ្ញុំនឹងបន្តបន្ថែមទៀត ហើយបន្ទាប់មកមេធាវីការពារក្តីអាចធ្វើការឆ្លើយតបបាន ។ បន្ថែមលើនេះទៀត បើសិនជាខ្ញុំយល់ដឹងច្បាស់លាស់នោះ គឺវាក៏មានសេចក្តីជំទាស់ផងដែរទៅលើការដាក់សំណើដាក់នៅចំពោះមុខអង្គសវនាការនូវឯកសារមួយចំនួន ដែលជារបាយការណ៍យោធា ជាសៀវភៅ និងជាវីដេអូ ។ នៅក្នុងដំណាក់កាលនេះ ខ្ញុំមិនបានឮពីសេចក្តីជំទាស់ទៅលើអង្គហេតុដែលថាឯកសារអស់ទាំងហ្នឹង គឺមានតែជាភាសាមួយក្នុងចំណោមភាសាទាំងបីរបស់តុលាការនេះទេ ។ ដូច្នេះ ខ្ញុំចង់ឲ្យមេធាវីការពារក្តីធ្វើការបញ្ជាក់ពីជំហររបស់ខ្លួនឲ្យបានច្បាស់ទៅលើភាសានៃឯកសារទាំងនេះ ។

[១៤:៤២:៣៥]

ទាក់ទងទៅនឹងរបាយការណ៍នៃកិច្ចសម្ភាសន៍ ឬក៏របាយការណ៍នៃការសម្តែងឡើងវិញ ខ្ញុំជឿថាអ្វីដែលខ្ញុំយល់នោះ គឺថាមានកិច្ចព្រមព្រៀងរវាងភាគីមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា ដែលថាឯកសារអស់ទាំងហ្នឹង គួរតែចាត់ទុកថាត្រូវបានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ ដូចគ្នានេះផងដែរ គឺទាក់ទងទៅនឹងសេចក្តីថ្លែងការណ៍របស់សាក្សីដែលត្រូវបានប្រមូលនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត ។

ទាក់ទងទៅនឹងឧបសម្ព័ន្ធ “ឃ” គឺឯកសារចំនួនហុកសិប ដែលមានចំណារដោយផ្ទាល់ដៃរបស់ឌុច ខ្ញុំយល់ថា ឯកសារអស់ទាំងនេះមួយចំនួននោះ គឺថាត្រូវបានដាក់ដេញដោលរួចហើយនៅចំពោះមុខអង្គសវនាការ ។ ដូច្នេះ ខ្ញុំមិនដឹងថាតើខាងសហព្រះរាជអាជ្ញាមានបានរៀបចំបញ្ជីឯកសារអស់ទាំងនេះឬទេ? ឬមួយបញ្ជីឯកសារដែលត្រូវបានដាក់បង្ហាញរួចហើយនៅចំពោះមុខអង្គសវនាការនោះ? ឬមួយថាឯកសារទាំងហុកសិប នេះជាឯកសារថ្មីស្រុងតែម្តង ដែលមិនទាន់បានដាក់ឲ្យសួរដេញដោលនៅចំពោះមុខអង្គសវនាការនោះទេ? បើដូច្នេះមែន នេះជារឿងមួយផ្សេងទៀត ។

ចំណុចចុងក្រោយនោះ គឺទាក់ទងទៅនឹងសៀវភៅរបស់លោក នីក ដងឡុប ខ្ញុំចង់ឲ្យខាងមេធាវីការពារក្តីបង្ហាញឲ្យបានច្បាស់លាស់ ថាតើសៀវភៅហ្នឹងជាភាសាអង់គ្លេស ដែលនេះជាចំណុចមួយអំពីថាតើមេធាវីការពារក្តីជំទាស់ទៅនឹងសៀវភៅនេះ ឬក៏ជំទាស់ទៅនឹងអង្គហេតុដែលថាសៀវភៅនេះមានតែជាភាសាអង់គ្លេសតែប៉ុណ្ណោះ?

**លោក អានីស អះមេដ៖**

សូមទោសលោកចៅក្រម តាមពិតសៀវភៅហ្នឹងក៏មានជាភាសាខ្មែរផងដែរ ។

[១៤:៤៤:៥៥]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកចៅក្រម ។ ទាក់ទងទៅនឹងឯកសារគាំទ្រ ទាក់ទងទៅនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធនោះ មេធាវីការពារក្តីសូមបង្ហាញឡើងវិញអំពីជំហររបស់ខ្លួន ទាក់ទងទៅនឹងអង្គហេតុដែលបានឯកភាពគ្នាមកហើយនោះ គឺជនជាប់ចោទបានទទួលស្គាល់អំពីអ្នកទោស ឬក៏ឈ្លើយសឹកដែលកើតមានក្រោយថ្ងៃទី៣១ ខែធ្នូ ឆ្នាំ៧៧ មកនោះ ។ តាមពិត សហព្រះរាជអាជ្ញាបានចាត់ទុកថាជាការចាំបាច់ណាស់ក្នុងការដាក់ជូនជាសំណើដល់អង្គជំនុំជម្រះសាលាដំបូងនេះ ដើម្បីឲ្យអង្គជំនុំជម្រះធ្វើការពិចារណា ថាតើជម្លោះប្រដាប់អាវុធនោះបានកើតមានរាលដាលទូទាំងប្រទេសនៅក្នុងអំឡុងពេលនោះ ឬក៏យ៉ាងម៉េច?

ពីដំបូងមកម្ល៉េះមេធាវីការពារក្តីបានលើកឡើងថា នេះមិនមែនជាចំណុចមួយ ដែលជាចំណុចសំខាន់នៅក្នុងសំណុំរឿងទីមួយនោះទេ គឺយើងបាននិយាយឃ្លាដូច្នេះតាំងពីដំបូងមកម្ល៉េះ ។ ហើយមេធាវីខាងសហព្រះរាជអាជ្ញា ក៏បានស្នើសួរមកមេធាវីការពារក្តីថាតើមេធាវីការពារបានព្រមព្រៀងឬទេទៅលើអត្ថបទសារព័ត៌មានប្រហែលជាពីររយនោះ ។ តាមពិត គឺវាលើសពីររយជាងឯនោះគឺដល់ទៅ២១៥

ហើយអត្ថបទសារព័ត៌មានអស់ទាំងហ្នឹង គឺវាមានតែជាភាសាអង់គ្លេសតែប៉ុណ្ណោះ ។ ដូច្នេះខ្ញុំបានប្រាប់ទៅខាងសហព្រះរាជអាជ្ញាវិញថា ប្រសិនបើពួកគាត់ចង់ដាក់ឯកសារនេះនៅចំពោះមុខអង្គសវនាការជាភាសាអង់គ្លេស គឺខ្ញុំចង់ឲ្យគាត់ធ្វើការទទួលខុសត្រូវក្នុងការរៀបចំនូវសេចក្ដីសង្ខេបមួយទំព័រនៃឯកសារនីមួយៗ ថាតើឯកសារអស់ទាំងហ្នឹងនិយាយអំពីអ្វី? ខ្ញុំយល់ថា មិនមែនជាចំណុចពិបាកពេកនោះទេ គឺសេចក្ដីសង្ខេបតែមួយទំព័រតែប៉ុណ្ណោះនោះ ។ ហើយជាការឆ្លើយតប គឺខ្ញុំទទួលបាននូវអត្ថបទជាភាសាអង់គ្លេស ដែលជាអត្ថបទសារព័ត៌មាននោះតែម្ដង ហើយបើសិនជាករណីនេះកើតមានមែន មានន័យថាខាងផ្នែកបកប្រែហ្នឹងនឹងទទួលបាននូវឯកសារដ៏ច្រើន ដែលត្រូវតែបកប្រែនោះ ។

ខ្ញុំនៅតែរក្សាគោលជំហរថា ឯកសារអស់ទាំងហ្នឹងគឺវាអត់ពាក់ព័ន្ធទេ ។ គឺមិនចាំបាច់ដាក់បន្ទុកមកដល់លើអង្គជំនុំជម្រះនេះនូវអត្ថបទសារព័ត៌មានជាងពីររយនោះទេ ។ ហើយខ្ញុំមិនបានស្នើសុំឲ្យធ្វើការបកប្រែឯកសារនោះដែរ គឺខ្ញុំគ្រាន់តែចង់ឲ្យធ្វើការសង្ខេបមួយទំព័រៗជាភាសាបារាំងតែប៉ុណ្ណោះដើម្បីបង្ហាញថាតើឯកសារនុ៎ងជាឯកសារអ្វី? នោះគឺជាសំណើរបស់ខ្ញុំច្បាស់លាស់បំផុត ដែលខ្ញុំបានស្នើឡើងកាលពីប្រាំមួយខែមុន ។

ទាក់ទងទៅនឹងសំណួរផ្សេងទៀតរបស់លោកចៅក្រម ដែលថាសហព្រះរាជអាជ្ញាអាចកត់សម្គាល់ឬក៏កំណត់អត្តសញ្ញាណទៅលើឯកសារស-២១ ដែលត្រូវបានដាក់បង្ហាញជូនរួចហើយនៅចំពោះមុខអង្គសវនាការនោះ នោះគឺជាបន្ទុករបស់ខាងសហព្រះរាជអាជ្ញា ពីព្រោះគឺខាងភាគីសហព្រះរាជអាជ្ញា ដែលជាអ្នកដាក់ឯកសារនៅលើអេក្រង់របស់អង្គជំនុំជម្រះនេះ ។ ហើយពួកគេគួរតែមានបញ្ជីឯកសារដែលត្រូវបានដាក់បង្ហាញរួចហើយនៅលើអេក្រង់នោះ ។

[១៤:៤៩:០៤]

ដូច្នេះឯកសារអស់ទាំងហ្នឹង និងឯកសារផ្សេងទៀតដែលបានដាក់ជូនដោយសហចៅក្រមស៊ើបអង្កេត ដែលជាបញ្ហានៃការលើកយកមកជជែកតវ៉ានោះ គឺខាងមេធាវីការពារក្ដីមិនមានការជំទាស់ទេ ។

ចុងក្រោយទាក់ទងទៅនឹងសៀវភៅរបស់លោក នីក ដងឡុក ដូចជាខាងសហព្រះរាជអាជ្ញាបាននិយាយអ៊ីចឹង ខ្ញុំចង់បង្ហាញអំពីជំហររបស់ខ្ញុំថា សៀវភៅហ្នឹង គឺមានជាភាសាខ្មែរ ប៉ុន្តែមិនមែនជាភាសាបារាំងទេ តែមានជាភាសាខ្មែរនិងភាសាអង់គ្លេស ។ ដូច្នេះ បើសិនជាអង្គជំនុំជម្រះយល់ថា ជាការចាំបាច់ ហើយអាចបកប្រែបានដោយខាងផ្នែកអង្គភាពបកប្រែជាភាសាបារាំងនោះ ខ្ញុំនឹងសប្បាយចិត្តនឹងទទួលបានជាភាសាបារាំង ។ ចំណែកភាសាខ្មែរ គឺសហសេវិករបស់ខ្ញុំអាចអានបាន គឺលោក

ការ សារុត្ត ។ ខ្ញុំសង្ឃឹមថា ខ្ញុំឆ្លើយតបអស់ហើយទៅនឹងសំណួររបស់លោកចៅក្រម ។

**ប្រធានអង្គជំនុំ៖**

ជា-- អញ្ជើញៗ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមទោសលោកប្រធាន នៅពេលនេះ គឺយើង-- នៅពេលដែលយើងពិភាក្សអំពីឯកសារ ដែលគួរតែថា សន្មតថាបានដាក់នៅចំពោះមុខអង្គសវនាការហើយនោះ ។ តាមទស្សនៈរបស់ខ្ញុំវិញ ខ្ញុំយល់ថា យើងគួរតែបន្ថែមនូវរបាយការណ៍នៃការវាយតម្លៃចិត្តសាស្ត្ររបស់ជនជាប់ចោទផងដែរ ។ ខ្ញុំគិតថាជាអត្ថប្រយោជន៍របស់អង្គជំនុំជម្រះ ដែលថាឯកសារទាំងអស់ទាក់ទងទៅនឹងការវាយតម្លៃផ្នែកផ្លូវចិត្ត ឬក៏ចិត្តសាស្ត្ររបស់ជនជាប់ចោទ គួរតែដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ សវនាការនេះ គឺជាសវនាការសាធារណៈ ។ ដូច្នេះ ជាការចាំបាច់ណាស់អ្នកដែលមានបំណងប្រាថ្នាចង់ពិនិត្យមើលឯកសារណាមួយនោះ ប្រសិនបើឯកសារទាំងអស់ហ្នឹងត្រូវបានពិភាក្សាជាសាធារណៈហើយនោះ ឬមួយដែលត្រូវបានចាត់ទុកថា ត្រូវបានដាក់ពិភាក្សាជាសាធារណៈហើយនោះ ។ នេះជាគោលការណ៍សំខាន់នៃដំណើរការនីតិវិធីរបស់យើងនេះ ។

[១៤:៥២:០១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញខាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើមានបំណងក្នុងការដាក់ឯកសារអ្វីដែរទេ? ហើយសូមញែកឲ្យច្បាស់លាស់រវាងឯកសារដែលមាននៅក្នុងសំណុំរឿងរួចហើយ ដោយបង្ហាញឲ្យបានច្បាស់លាស់នូវអត្តសញ្ញាណនៃឯកសារ ដើម្បីយើងអនុវត្តនៅតាមនីតិវិធីដែលយើងបានណែនាំអនុវត្តកន្លងមក ។ ហើយប្រសិនបើមានឯកសារថ្មី ដែលមានការបំណងដាក់នោះ គឺញែកឲ្យបានដាច់ស្រឡះពីគ្នារវាងឯកសារដែលមាននៅក្នុងសំណុំរឿងរួចហើយនិងឯកសារថ្មី ដើម្បីងាយស្រួលដល់អង្គជំនុំជម្រះពិនិត្យពិចារណាក្នុងរយៈពេលខ្លី ដើម្បីសម្រេចលើបញ្ហានោះ ។

អញ្ជើញក្រុមមួយមុនណ៎ា ។

**កញ្ញា ទី ស្រ៊ីនណា៖**

ជាបឋមនាងខ្ញុំ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល ។ នាងខ្ញុំឈ្មោះ ទី ស្រ៊ីនណា ជាមេធាវីតំណាងឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ និងសហភាតា

របស់ខ្ញុំ គឺលោក អាឡាំង វែនណឺ ។

ថ្ងៃនេះដូចដែល-- ថ្ងៃនេះ គឺជាថ្ងៃដែលបញ្ចប់នៃការដេញដោល ។ នាងខ្ញុំក៏សូមធ្វើសំណើពីរ ។ សំណើទាំងពីរហ្នឹងគឺជាសំណើដែលដាក់ឯកសារ ដើម្បីជូនដល់អង្គជំនុំជម្រះនៅក្នុងការពិនិត្យ និងពិចារណា ។ សំណើទីមួយរបស់ខ្ញុំ គឺទាក់ទងទៅនឹងឯកសារដែលមាននៅក្នុងសំណុំរឿងស្រាប់ ហើយ និងសំណើទីពីរ គឺជាសំណើសូមដាក់នូវឯកសារជាភស្តុតាងថ្មី ដែលពុំនៅក្នុងសំណុំរឿងនោះទេ ។

ឥឡូវនេះ នាងខ្ញុំសូមធ្វើលើកជាសំណើទីមួយដែលទាក់ទងទៅនឹងឯកសារ ដែលមាននៅក្នុងសំណុំរឿងស្រាប់ ។ នាងខ្ញុំសូមដាក់នូវឯកសារមួយចំនួន ដែលពាក់ព័ន្ធទៅនឹងចម្លើយសារភាពរបស់ ម៉ែន សាន ហៅ យ៉ា ដែលមានលេខ ERN ពីទំព័រលេខ 0009497 រហូត 00009682 ។ នៅរវាងទំព័រទាំងនេះ គឺនាងខ្ញុំសូមលើកនូវទំព័រមួយចំនួននៅក្នុង ERN ទាំងនេះ ដែលមានទំព័រ ERN 0000 9499 និង ERN ដែលមានលេខ 00009500 ត្រង់ចំណាររបស់ជនជាប់ចោទ និង ERN ដែលមានលេខ 00009574 ត្រង់សំបុត្រដែលជនជាប់ចោទសរសេរទៅកាន់ ម៉ែន សាន ហៅ យ៉ា ត្រង់ចំណុចឃ្លាចុងក្រោយនៃសំបុត្រ ។ ចំពោះ ERN ទំព័រចុងក្រោយមួយទៀត គឺដែលមានលេខ ERN 00009587 ត្រង់ចំណុចដែលជនជាប់ចោទសរសេរទៅកាន់សមមិត្ត ប៉ុន ត្រង់ចំណុចទីបីនៃសំបុត្រ ។

[១៤:៥៧:០០]

ចំពោះERN ជាភាសាអង់គ្លេសនិងភាសាបារាំង នាងខ្ញុំពុំអាចរកឃើញទេ នាងខ្ញុំសូមអភ័យទោស ប៉ុន្តែឯកសារទាំងនេះពិតជាមានការបកប្រែរួចជាស្រេច និងដាក់បញ្ចូលនៅក្នុងសំណុំរឿងរួចហើយ ។ នាងខ្ញុំសំណូមពរសូមឲ្យអង្គជំនុំជម្រះមេត្តាពិនិត្យទៅលើទំព័រទាំងនេះដោយលម្អិត ដើម្បីធ្វើការទុកជាមូលដ្ឋាននៅក្នុងការសម្រេចសេចក្តី ។

ចំពោះសំណើទីពីររបស់នាងខ្ញុំ ទាក់ទងទៅនឹងឯកសារថ្មីដែលពុំមាននៅក្នុងសំណុំរឿងនៅឡើយ។ នាងខ្ញុំសំណូមពរសូមលើកដាក់ជាសំណើដោយផ្ទាល់មាត់នូវឯកសារជាភស្តុតាងថ្មី ដែលទាក់ទងទៅនឹងមន្ទីរស-២១នេះ ដោយមូលហេតុថា ក្រុមនាងខ្ញុំបានធ្វើលិខិតជាលាយលក្ខណ៍អក្សររួចហើយ ហើយក្រុមយើងខ្ញុំក៏បានបញ្ជូនទៅខាងការិយាល័យបកប្រែ ដើម្បីធ្វើការបកប្រែ និងដាក់បញ្ចូលនៅក្នុងសំណុំរឿង ។ ប៉ុន្តែជាអកុសល ដោយសារតែខាងការិយាល័យបកប្រែនោះ មមាញឹកនឹងការបកប្រែឯកសារផ្សេងៗទៀតជាច្រើន ពុំអាចធ្វើការបកស្រាយជូនក្រុមយើងខ្ញុំទាន់ពេលវេលា ។

ដូច្នេះ នាងខ្ញុំស្នើសុំដាក់លិខិតជាលាយលក្ខណ៍អក្សរតាមក្រោយ មុននឹងបញ្ចប់ការសន្និដ្ឋាន

ការពារ ។

ចំពោះឯកសារ ដែលភស្តុតាងតែម្តង ដែលនាងខ្ញុំមានបំណងចង់ដាក់នោះ នាងខ្ញុំបានប្រគល់ជូនទៅខាងមេធាវីការពារក្តីដើម្បីធ្វើការពិនិត្យ និងពិចារណាកាលពីព្រឹកមិញនេះរួចហើយ ។ ទាក់ទងទៅនឹងឯកសារទាំងនោះ គឺនាងខ្ញុំមានគោលបំណងដាក់ឯកសារចំនួន១៨សន្លឹក ដោយសុទ្ធតែជាបញ្ជីក្តាប់កម្លាំងអ្នកទោសប្រចាំថ្ងៃនៅមន្ទីរស-២១ ។ នៅក្នុងឯកសារទាំងនោះហ្នឹងគឺមានចំណាររបស់ ហ៊ៃ ដែល អ៊ូ! សូមទោស គឺមានហត្ថលេខារបស់ ហ៊ៃ ដែលជាបុគ្គលិករបស់មន្ទីរស-២១ ដែលហត្ថលេខានេះ គឺឆ្លុះបង្ហាញថា បញ្ជីហ្នឹងគឺធ្វើឡើងដោយ ហ៊ៃ ដើម្បីធ្វើរបាយការណ៍ដាក់បញ្ជូនទៅថ្នាក់លើក្នុងការពិនិត្យស្ថានភាពប្រចាំថ្ងៃរបស់មន្ទីរស-២១ ។ នៅក្នុងបញ្ជីទាំងនុ៎ង គឺមានតារាងដែលគេធ្វើឡើង ដោយដាក់ចំនួនអ្នកទោសប្រចាំថ្ងៃ និងអ្នកទោសដែលត្រូវ ទើបនឹងបញ្ចូលមកថ្មី ក៏ដូចជាអ្នកទោសដែលបានស្លាប់នៅក្នុងមន្ទីរស-២១ ក៏ដូចជាអ្នកទោសត្រូវយកទៅកម្ទេច ។

ក្រុមនាងខ្ញុំគិតថាបញ្ជីនេះ គឺជាភស្តុតាងថ្មីមួយដែលសំខាន់ ដែលគួរគប្បីបញ្ចូលទៅក្នុងសំណុំរឿង០០១ នេះ គឺដោយសារតែបញ្ជីនេះ បង្ហាញអំពីស្ថានភាពរបស់អ្នកទោសនៅមន្ទីរស-២១ ដែលនៅក្នុងសំណុំរឿងពុំមានឯកសារជាលាយលក្ខណ៍អក្សរណាមួយ បង្ហាញអំពីស្ថានភាពជាក់ស្តែងនៅក្នុងមន្ទីរស-២១ នោះឡើយ ។ ចំណុចមួយទៀត បញ្ជីនេះក៏ឆ្លុះបង្ហាញយ៉ាងច្បាស់ផងដែរ គឺទាក់ទងទៅនឹងអ្នកទោសនៅមន្ទីរស-២១ ដែលបានស្លាប់ដោយមធ្យោបាយផ្សេងៗ ដែលផ្ទុយពីការយកទៅកម្ទេចនៅជើងឯក ។ នៅក្នុងការកម្ទេចនុ៎ង គឺ-- នៅក្នុងបញ្ជីទាំងហ្នឹងក៏បានបង្ហាញដែរ គឺការកម្ទេចដោយការយកឈាម និងអ្នកទោសនៅមន្ទីរស-២១ ហ្នឹង បានចងកសម្លាប់ខ្លួនឯង គឺមានន័យថា សម្លាប់ខ្លួនឯងនៅក្នុងបន្ទប់នៃមន្ទីរស-២១ ។ ហើយបញ្ជីនេះក៏បានបង្ហាញទៀតផងដែរថា មានអំពើទារុណកម្មដោយអ្នកទោសនៅក្នុងនោះគាត់បានស្លាប់ដោយអំពើទារុណកម្ម ស្លាប់ដោយជំងឺរាករូសផ្សេងៗទៀត និងស្លាប់ដោយទារុណកម្មនៅក្នុងអំឡុងពេលសួរចម្លើយនៅក្នុងមន្ទីរស-២១ ។

[១៥:០៣:០៤]

នៅក្នុងនោះដែរ ក្រុមនាងខ្ញុំក៏បានធ្វើការពិនិត្យពិច័យ និងធ្វើការប្រៀបធៀបបញ្ជីនេះជាមួយនឹងបញ្ជីដែលមាននៅក្នុងសំណុំរឿងស្រាប់ ដែលមានលេខ E68.1 ដែលជាបញ្ជីកម្ទេចអ្នកទោសដែលបានកែប្រែរួចហើយ ដែលអង្គសវនាការនេះលើកយកមកពិភាក្សាដេញដោល ដើម្បីឆ្លុះបង្ហាញថា អ្នកទោសឈ្មោះ និងអត្តសញ្ញាណរបស់អ្នកទោស ដែលបានស្លាប់នៅក្នុងមន្ទីរស-២១ ។ យើងបានធ្វើការប្រៀប

ធៀបទៅយើងឃើញថា ឈ្មោះអ្នកទោសដែលមាននៅក្នុងបញ្ជីក្តាប់កម្លាំងអ្នកទោសប្រចាំថ្ងៃនេះភាគច្រើន គឺពុំមាននៅក្នុងបញ្ជីកម្ទេចរបស់មន្ទីរស-២១ នោះទេ ។ នេះគឺជាហេតុមួយដែលបង្ហាញពីភាពខុសគ្នា ហើយក៏ជាឯកសារថ្មី ក៏ជាភស្តុតាងថ្មី តែមួយគត់ដែលយើងអាចយកមកបំភ្លឺ និងដើម្បីយកមកបំភ្លឺនៅក្នុងសាលសវនាការនេះ ។

[១៥:០៥:២៥]

ដូច្នេះហើយនាងខ្ញុំគិតថា បញ្ជីដែលនាងខ្ញុំរកឃើញថ្មីចំនួន១៨ នេះគួរគប្បីបញ្ចូលទៅក្នុងសំណុំរឿងព្រោះវាជាប្រយោជន៍ដល់អង្គសវនាការនៅក្នុងការបង្ហាញទៅការពិត និងដើម្បីជួយរកយុត្តិធម៌ដល់អ្នកទោសដែលបានស្លាប់នៅក្នុងមន្ទីរស-២១។ ដូច្នេះ នាងខ្ញុំសំណូមពរសូមឲ្យលោកប្រធានមេត្តាទទួលយកនូវបញ្ជីទាំងនេះធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង០០១ នេះចាប់ពីពេលនេះតទៅ ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ អាឡាំង វ៉ែនណឺ ។

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធានជាទីគោរព! លោក លោកស្រីចៅក្រម ខ្ញុំសូមលើកឡើងបន្ថែមទៅលើដែលសហភាតារបស់ខ្ញុំបានលើកឡើង ។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា ចំណុចទាំងឡាយលើកឡើងបានច្បាស់លាស់ទៅលើចំណុចចំនួនពីរ ។ ជាបឋម គឺទាក់ទងទៅនឹងការបកប្រែ ។ យើងដឹងហើយថាដើមបណ្តឹងរដ្ឋប្បវេណីមានការរវល់ណាស់ក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ ដោយសារតែក្រោយពីការចេញដីការបស់លោក លោកស្រីចៅក្រម យើងត្រូវការដាក់ទៅលើការទាមទារសំណង និងការទាមទារទៅលើសំណងសមូហភាពផ្សេងៗ ។ ដូច្នេះហើយយើងខ្ញុំ គឺបានពិភាក្សានៅក្នុងក្រុមរបស់ខ្ញុំ ។ យើងខ្ញុំមិនបានដាក់សំណើរបស់ខ្ញុំបកប្រែនៅអង្គភាពបកប្រែនោះទេ ។

ដូច្នេះហើយនេះជាមូលហេតុ ដែលយើងខ្ញុំបានដាក់ជូន និងផ្តល់ជូនមេធាវីការពារក្តីប្រហែលជាប៉ុន្មានម៉ោងមុននេះ ។ ហើយយើងសង្ឃឹមថា ឯកសារនេះនឹងបកប្រែរួចរាល់នៅក្នុងអាទិត្យក្រោយ ។ ដោយសារតែយើងដឹងហើយថា នៅថ្ងៃច័ន្ទនោះក៏យើងឈប់សម្រាកវិសមកាលផងដែរ ។

ដូច្នេះហើយខ្ញុំសូមឆ្លៀតឱកាសនេះដាក់ជូននូវសំណើអម្បាញ់មិញនេះដោយផ្ទាល់មាត់ ហើយយើងស្នើសុំ ហើយក៏បើកឲ្យមានការផ្តល់យោបល់ទៅលើចំណុចហ្នឹងផ្សេងៗផងដែរ ។ ហើយទាក់ទងទៅនឹងធាតុផ្សំផ្សេងៗដែលវាពាក់ព័ន្ធទៅនឹងសំណើរបស់យើងខ្ញុំដែលដាក់ជូននេះវាមានសារសំខាន់សម្រាប់

ដើមបណ្ដឹងរដ្ឋប្បវេណី។ មូលហេតុនោះ គឺដូចកញ្ញា ទី ស្រ៊ុនណា បានលើកឡើងអ៊ីចឹង។ យើងមាន បញ្ជី១៨ ហើយប្រសិនបើបញ្ជីក្នុងនោះគឺបានធ្វើឡើងជាប្រចាំថ្ងៃនោះគឺ យើងនឹងឃើញមានច្រើន ប៉ុន្តែ យើងឃើញថា នៅពេលនេះយើងនិយាយអំពីបញ្ជីចំនួន១៨ ។ ដូច្នេះ អ្វីដែលយើងនិយាយនោះឃើញថា នៅក្នុងបញ្ជីនោះមានឈ្មោះ១៨រូប ដែលជាប់ឃុំនៅស-២១ ។ ហើយនៅក្នុងសំណើរបស់យើង គឺមាន ការលើកឡើងអំពីសេចក្ដីថ្លែងការណ៍បញ្ជាក់ទៅលើអង្គហេតុដែលបានរកឃើញនៅស-២១ ។

ដូច្នេះហើយអ្នក១៨នាក់នោះ គឺមិនមែនត្រូវបានគេសម្លាប់ទេ គឺស្លាប់ដោយសារស្ថានភាព លក្ខខណ្ឌនៃការធ្វើទារុណកម្ម និងស្ថានភាពផ្សេងៗ ហើយម្នាក់ គឺគាត់សម្លាប់ខ្លួន ។ ដូច្នេះ ហើយយើង ឃើញថា១៨ បញ្ជីនេះ គឺយើងអាចយករួមបញ្ចូលជាមួយនឹងបញ្ជីរបស់សហព្រះរាជអាជ្ញា ហើយបញ្ជី ដែលយើងលើកឡើងនេះ មិនអាចរកឃើញនៅក្នុងបញ្ជីផ្សេងៗទៀតទេ ។ ហើយបញ្ជីនេះក៏បានលើក ឡើងថា អ្នកទាំងអស់នោះ គឺស្លាប់ ហើយមិនមែនត្រូវបានគេសម្លាប់នោះទេ ។ ហើយឈ្មោះរបស់អ្នក ទាំងអស់នោះ គឺមិនមាននៅក្នុងបញ្ជីរួម ហើយខ្ញុំក៏បានលើកឡើងទៅលើចំណុចហ្នឹងដែរ ច្រើនដែរនៅ ក្នុងសវនាការ ។ យើងមិនអាចដាក់ជូនឯកសារបន្ថែមដោយសារតែជនជាប់ចោទ និងមេធាវីរបស់គាត់ គឺបានដាក់ជូនអ៊ីចឹង គឺថាឈ្មោះរបស់កូនក្ដីរបស់ខ្ញុំ គឺទាក់ទងទៅនឹងជនរងគ្រោះរបស់កូនក្ដី របស់ខ្ញុំ គឺវា មិនឃើញមាននៅក្នុងបញ្ជីឈ្មោះរួម ។ ដូច្នេះហើយនៅពេលដែលយើងដាក់បញ្ជីថ្មី១៨ នេះគឺវាអាចធ្វើ ឲ្យយើងអាចបញ្ជាក់ទៅលើចំណុចករណីស្លាប់នេះ ដែលថា ជនទាំងអស់នោះមិនមែនស្លាប់ ដោយសារ ស្លាប់នឹងកាប់សម្លាប់នោះទេ គឺស្លាប់ដោយសារស្ថានភាពឃុំខ្លួន ការធ្វើទារុណកម្មផ្សេងៗ ។

ដូច្នេះហើយវាមានលក្ខណៈត្រឹមត្រូវដែរថាបញ្ជី១៨នេះ ហើយនិងឈ្មោះរបស់អ្នកទាំងអស់នេះ មិនមានគេបញ្ចូលនៅក្នុងបញ្ជីស្លាប់របស់អ្នកទោស។ ដូច្នេះហើយគឺថា យើងដាក់ជូនទៅនឹងបញ្ជីនេះ ហើយដូចដែលយើងបានបញ្ជាក់អ៊ីចឹង ឈ្មោះដែលថា មិនមាននៅក្នុងបញ្ជី មិនមានឈ្មោះនៅក្នុងបញ្ជី រួមនោះ វាមិនមែនថា មិនមានការស្លាប់របស់កូនក្ដីរបស់យើង ឬក៏ជនរងគ្រោះនៅក្នុងស-២១នោះទេ ។ ហើយនៅក្នុងខែមករា ដូចដែលលោក លោកស្រីចៅក្រមបានដឹងហើយ យើងមានលក្ខណៈកម្រិតនៅ ក្នុងក្រុមរបស់យើង ហើយយើងប្រឹងប្រែងក្នុងការពិនិត្យទៅលើឯកសារ ដែលការពិនិត្យទៅលើឯកសារ ទាំងអស់នោះយើងត្រូវការប្រុងប្រយ័ត្ន និងពេលវេលាច្រើន ។ ហើយយើងត្រូវការប្រុងប្រយ័ត្នដើម្បី យកបញ្ចូល យកឯកសារទាំងអស់នោះ យកមកបញ្ចូលនៅក្នុងសំណុំរឿងរបស់យើង ។

ដូច្នេះហើយយើងត្រូវតែពិនិត្យទៅលើឯកសារទាំងឡាយ ដើម្បីបញ្ជាក់ផ្សេងៗ ហើយយើង

សរសេរមកដាក់ចូលនៅក្នុងសំណើរបស់យើង ។ ដូច្នេះហើយយើងខ្ញុំគិតថា បញ្ជីចំនួន១៨នេះ វាមានសារសំខាន់ណាស់សម្រាប់កូនក្តីរបស់យើង ហើយក៏សម្រាប់រឿងក្តីរបស់យើងផងដែរ ។ ដូច្នេះហើយគឺខ្ញុំស្នើសុំឲ្យដាក់បញ្ជីទាំង១៨នេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយអាចបញ្ជាក់បានទេ? ទីមួយ ប្រភពនៃឯកសារដែលទើបរកបាន ។ ហើយទីពីរ ហេតុផលម៉េចទៅបានជាឯកសារទាំងនេះមានការយឺតយ៉ាវរហូតដល់ពេលហើយទើបតែស្នើសុំដាក់?

[១៥:១១:៥៣]

**កញ្ញា ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន ។ នាងខ្ញុំនឹងធ្វើការបំភ្លឺ ។ ទាក់ទងទៅនឹងឯកសារនេះគឺយើងរកបាននូវសារមន្ទីរទួលស្លែង ដោយនាងខ្ញុំបានខំប្រឹងចំណាយពេលវេលាយ៉ាងយូរ ដើម្បីធ្វើការស្វែងរកឯកសារដូចសហភាតារបស់ខ្ញុំបានលើកឡើងអម្បាញ់មិញ ទើបយើងរកបាននូវឯកសារទាំងនេះ ។ ហើយនៅក្នុងនោះដែរ យើងក៏បានធ្វើការស្នើសុំថតចម្លង ដោយការស្នើសុំថតចម្លងហ្នឹងយើងត្រូវការចំណាយពេលវេលាយូរ គឺយើងមានការស្នើសុំទៅខាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលជាក្រសួងគ្រប់គ្រងទៅលើសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នេះ ។ អ៊ីចឹងយើងធ្វើការស្នើសុំទៅគាត់សិន ដើម្បីសុំលិខិតអនុញ្ញាតនៅក្នុងការថតចម្លងឯកសារនៅសារមន្ទីរទួលស្លែង ។ ដល់ពេលយើង-- ទម្រាំនឹងយើងទទួលបាននូវលិខិតនេះ គឺយើងចំណាយពេលបីថ្ងៃទៅមួយអាទិត្យ ពីព្រោះថាភ្នាក់ងារនៅទីនោះចួនកាលគាត់ជាប់រវល់ពុំអាចធ្វើលិខិតនោះបាន អ៊ីចឹងមានការយឺតយ៉ាវ ។ ទម្រាំខ្ញុំទទួលបានលិខិតហ្នឹង គឺរហូតដល់ថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០៩ នេះទើបបានយើងទទួលបានលិខិតនោះ ។ នៅពេលដែលយើងទទួលបានហើយ យើងត្រូវការចំណាយពេលវេលាដើម្បីពិនិត្យទៅលើដើមបណ្តឹងរដ្ឋប្បវេណីយើងខ្ញុំដូចសហភាតាខ្ញុំបានលើកឡើងអម្បាញ់មិញអ៊ីចឹង ។ យើងត្រូវការចំណាយពេលវេលានិងដើម្បីពិនិត្យទៀត ។

ហើយចំណុចមួយទៀតពាក់ព័ន្ធជាមួយនឹងមូលហេតុនៃការយឺតយ៉ាវក្នុងការដាក់ឯកសារនេះ ។ នាងខ្ញុំសូមជម្រាបជូនអង្គសវនាការថា ក្រុមនាងខ្ញុំដែលបានកកើតឡើង ដើម្បីចូលរួមនៅក្នុងសំណុំរឿង ០០១ នេះ គឺយើងចាប់ផ្តើមនៅពាក់កណ្តាលខែ១ នៅក្នុងឆ្នាំ២០០៩ នេះ គឺជាពេលវេលាមួយបិទការស៊ើបសួររួចហើយ ហើយក៏ជាពេលវេលានៃការចាប់ផ្តើមនីតិវិធីសវនាការ ។ ដូច្នេះហើយយើងឃើញ

ថា ពេលវេលានេះ គឺជាពេលវេលាមួយដែលមានការភិតផើយសម្រាប់យើងនៅក្នុងការសិក្សាទៅលើឯកសារជាច្រើន ដែលពាក់ព័ន្ធជាមួយនឹងសំណុំរឿង០០១ នេះ ។ ហើយទន្ទឹមនឹងនេះដែរ ទោះបីជាក្រុមយើងមានរយៈពេលខ្លីនៅក្នុងការសិក្សាសំណុំរឿងនេះ ក៏ពួកយើងនៅតែខំប្រឹងប្រែងស្វះស្វែង ដើម្បីរកភស្តុតាង និងឯកសារជាច្រើន ដើម្បីមកបំភ្លឺនៅក្នុងសាលសវនាការនេះ ដើម្បីស្វែងរកការពិត ។

នៅក្នុងនុំងដែរ យើងក៏បានព្យាយាមស្វែងរកភស្តុតាងជារៀងរាល់ថ្ងៃ ទោះបីជាយើងមានការរវល់នៅក្នុងការចូលរួមសវនាការក៏ដោយ នៅពេលទំនេរយើងឆ្លៀតពេលដើម្បីស្វែងរកភស្តុតាងបន្ថែម យើងបានសិក្សាទៅលើសំណុំរឿង និងរកឯកសារផ្សេងៗដើម្បីមកបង្ហាញបំភ្លឺនៅអង្គសវនាការនេះ ។ នេះគឺជាមូលហេតុនៃការដាក់ឯកសារយឺតយ៉ាវ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងត្រូវសម្រាកហើយ អង្គជំនុំជម្រះសូមប្រកាសសម្រាកដប់ប្រាំបីនាទីពីនេះទៅរហូតដល់ម៉ោងបីនិងសាមសិបនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការរបស់យើង ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង១៥:១៥នាទីដល់ម៉ោង១៥:៣៦នាទី ]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

ជាបន្តនេះ អង្គជំនុំជម្រះចង់ស្តាប់នូវមតិយោបល់ពីភាគីផ្សេងៗទៀត ពាក់ព័ន្ធជាមួយនឹងសំណើសុំដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ដែលមានឯកសារចាស់នៅក្នុងសំណុំរឿង ដែលបានបង្ហាញរួចហើយ ហើយនិងឯកសារដែលបានរកឃើញថ្មីចំនួន១៨ទំព័រ ឬក៏១៨សន្លឹកនេះ តើមានមតិយោបល់យ៉ាងម៉េចដែរមេធាវីការពារក្តី?

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ ចំពោះមេធាវីការពារក្តីយល់ឃើញថា ឯកសារដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានសុំបញ្ចូលទៅក្នុងសំណុំរឿង គឺមានឯកសារដែលមាននៅក្នុងសំណុំរឿង

ស្រាប់ ចំពោះឯកសារដែលមាននៅក្នុងសំណុំរឿងស្រាប់នេះ ខ្ញុំយល់ថា មិនគួរដាក់ថែមទៀតវានាំតែច្រើនទេ ។ ហើយបើសិនជាមេធាវីក្រុម១ យល់ឃើញថា ចំណុចណាជាចំណុចសំខាន់នោះ នៅពេលធ្វើសេចក្តីសន្និដ្ឋានសង្កត់ទៅលើចំណុចនោះទៅ ហើយឯកសារអីលេខប៉ុន្មានអីប៉ុន្មាន ERN ប៉ុន្មាន គឺសុំបញ្ជាក់ហ្នឹងទៅបានហើយ មិនគួរដាក់ឲ្យនាំតែច្រើន ពីព្រោះវាមានស្រាប់ នេះជាចំណុចទីមួយ ។

ចំណុចទីពីរ ឯកសារថ្មីទាក់ទងនឹងស-២១ បើតាមគោលការណ៍ យើងឃើញថា រាល់ឯកសារដែលចេញពីស-២១ យើងត្រូវដាក់ជូនទៅចៅក្រមស៊ើបអង្កេតនៅពេលស៊ើបអង្កេត ដើម្បីដេញដោលរកហេតុផល រួចឯកសារខ្លះ វាមានសុទ្ធតែមានឈ្មោះមនុស្សនៅក្នុងនុំង អ្នកដែលធ្វើឯកសារហ្នឹង ។ អ៊ីចឹងមនុស្សខ្លះដែលធ្វើឯកសារហ្នឹង វានៅរស់ ដូច្នេះគេត្រូវដេញដោលគ្នានៅចៅក្រមស៊ើបអង្កេត ។ ដូច្នេះខ្ញុំយល់ថា ដាក់ឯកសារចេញពីទួលស្លែង ខាងខ្ញុំនេះគឺទទួលយកមិនបានទេ ពីព្រោះវាហួស បើឯកសារដែលក្រៅពីទួលស្លែង អាហ្នឹងខ្ញុំអាចទទួលយកបាន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

[១៥:៣៩:១៥]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ តាមពិតគឺថា យើងខ្ញុំមានការភ្ញាក់ផ្អើលណាស់លោកប្រធាន ។ យើងខ្ញុំមានការភ្ញាក់ផ្អើលដោយសារតែសំណើដែលបានលើកឡើងនៅដំណាក់កាលនេះ ហើយខ្ញុំមិនឃើញមានទំនាក់ទំនងអ្វីជាមួយនឹងបុគ្គលដែលបានលើកឡើងទាក់ទងទៅនឹងសំណើយឺតដែលបានលើកឡើងដោយមេធាវីក្រុមទីមួយនេះ ។ តើឈ្មោះអស់ទាំងហ្នឹងជាឈ្មោះដែលមាននៅក្នុងបញ្ជីនោះ ហើយដែលជាកូនក្តីនៅក្នុងក្រុមទីមួយនុំងឬ? ប៉ុន្តែបើសិនជាមិនមានៗឈ្មោះកូនក្តីរបស់ខ្លួននៅក្នុងបញ្ជី ឬក៏ចម្លើយសារភាពនោះទេ ខ្ញុំយល់ថា តើមានចំណុចអ្វីទៅក្នុងការដាក់បញ្ចូលឯកសារនេះ? ឬមួយក៏ពួកគេចង់បំពេញតួនាទីរបស់សហព្រះរាជអាជ្ញា? តួនាទីនេះមិនមែនជាតួនាទីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ប៉ុន្តែបើសិនជាសំណើនេះមានពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកូនក្តីរបស់ខ្លួន គឺថាយើងអាចពិភាក្សាគ្នាបាន ។ ដូច្នេះសំណួរទីមួយ ដែលយើងចង់សួរថាតើឯកសារហ្នឹងវាមានពាក់ព័ន្ធទៅនឹងកូនក្តីរបស់ខ្លួនដែលពួកគាត់ការពារដែរឬទេ? ហើយឯកសារនេះជាឯកសារមួយថ្មីទែង ។

ដូច្នេះជាថ្មីម្តងទៀត ខ្ញុំសូមអបអរសាទរដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្រាវជ្រាវ

រកឯកសារអស់ទាំងហ្នឹង ។ ប៉ុន្តែ ឲ្យខ្ញុំសុំទោសចុះ ដែលថាពួកគាត់បានធ្វើការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលមួយដែលបានធ្វើការទាក់ទងជាមួយនឹងឯកសារអស់ទាំងហ្នឹងជាច្រើនឆ្នាំមកហើយ ហើយជាទៀងទាត់ទៀតតាំងពីដំបូងទីនៃការបង្កើតអង្គជំនុំជម្រះនេះម៉្លេះ ។ ហើយព័ត៌មានអស់ទាំងហ្នឹងត្រូវបានដាក់បង្ហាញជាច្រើន ត្រូវបានបង្ហោះនៅក្នុងវេបសាយរបស់ខ្លួនគេទៀត ។

ដូច្នេះ គឺថាយើងមានដំណោះស្រាយជាច្រើនហើយ ដែលត្រូវបានបង្កើតឡើង ដោយគេបានដាក់នៅក្នុងវែបសាយរបស់ខ្លួន ។ ដូច្នេះ ខ្ញុំជឿថាអង្គការនោះ ដែលជាអង្គការមួយធ្វើការឡើងទាក់ទងនឹងបញ្ហានេះរយៈពេលជាងដប់ឆ្នាំមកហើយនោះ គួរតែមានចំណុចប្រសើរជាងបើសិនជាពួកគេត្រូវទៅស-២១ ទៅរកឯកសារពាក់ព័ន្ធអស់ទាំងហ្នឹង ។ ហើយខ្ញុំយល់ថា ខាងសហព្រះរាជអាជ្ញានោះ គឺបានធ្វើការជាមួយអង្គការនោះតាំងពីឆ្នាំ២០០៦មកម៉្លេះ ។ ដូច្នេះ ខ្ញុំមានការភ្ញាក់ផ្អើលខ្លាំងណាស់ ហើយរយៈពេលមួយឆ្នាំដែលជាដំណាក់កាលនៃការស៊ើបអង្កេតនោះ គឺសហព្រះរាជអាជ្ញាមិនបានរកឃើញឯកសារអស់ទាំងហ្នឹង ។ ហើយក្នុងអំឡុងពេលមួយឆ្នាំដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតក្នុងដំណាក់កាលស៊ើបអង្កេត។ ហើយរយៈពេលមួយឆ្នាំនៃសវនាការនេះទៀត គឺថាមិនមានបង្ហាញអំពីឯកសារអស់ទាំងនេះទេ ។ ដូច្នេះហើយជាថ្មីម្តងទៀត ខ្ញុំចង់សួរថាតើឯកសារអស់ទាំងហ្នឹង មានឈ្មោះរបស់មនុស្សដែលជាកូនក្តីរបស់លោក លោកស្រីដែលគាត់តំណាងដែរឬទេ? បើអត់ទេ នោះគឺជាតួនាទីរបស់ខាងសហព្រះរាជអាជ្ញាទេ ។

[១៥:៤២:៤៩]

ដូច្នេះគឺថា ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺប្រថុយប្រថានក្នុងការធ្វើ ឬក៏បំពេញកិច្ចការនេះហើយ ។ ដូចអ្វីដែលបានកើតឡើងជាមួយនឹងជនរងគ្រោះកាលពីសប្តាហ៍មុនអ៊ីចឹង ។ ដូច្នេះ ខ្លួនខ្ញុំផ្ទាល់ខ្ញុំចង់ឲ្យលះបង់ចោលនូវមធ្យោបាយ ឬក៏គំនិតនៃការគិតបែបនេះ ។ ខ្ញុំអរគុណហើយដែលបានខំប្រឹងធ្វើកិច្ចការនេះ ប៉ុន្តែកិច្ចការនេះមិនមែនជាតួនាទីរបស់ខ្លួនទេ ក្នុងការស្វែងរកឯកសារនេះ ។ គឺថាឯកសារនេះវាជាឯកសារសំខាន់ ជាផ្នែកមួយរបស់តួនាទីរបស់ខាងសហព្រះរាជអាជ្ញា បើសិនវាពាក់ព័ន្ធនឹងកូនក្តីរបស់ខ្លួន បាទគឺជាចំណុចត្រឹមត្រូវហើយ ។ ក៏ប៉ុន្តែនៅក្នុងចំណុចពេលនេះ គឺខាងជនជាប់ចោទនោះ គាត់មិនមានឱកាសធ្វើការពិភាក្សាដេញដោលទៅលើឯកសារអស់នោះទេ ហើយដល់ពេលនេះ មិនដឹងជាយ៉ាងម៉េចទេ លេចចេញឯកសារថ្មីមកយ៉ាងនេះ តើឲ្យយើងធ្វើយ៉ាងម៉េចទៅ?

គឺថាគោលបំណងរបស់យើង គឺយើងស្វែងរកយុត្តិធម៌ មិនមែនជាការលែងសើចទេនៅទីនេះ ។

ដូច្នេះវិធីសាស្ត្រនេះ ខ្ញុំយល់ថា ជាវិធីសាស្ត្រមួយដែលមិនអាចទទួលយកបាន ហើយខ្ញុំសង្ឃឹមថា គឺថា លោក លោកស្រី នឹងពិចារណាឡើងវិញនូវនីតិវិធី ដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ ។ ហើយដូចដែលខ្ញុំបាននិយាយជាច្រើនដងមកហើយកាលពីព្រឹកមិញនេះ តើអ្វីទៅគឺជាទម្រង់ដែលយើងអាចទទួលយកបានទាក់ទងទៅនឹងសេរីភាពនោះ។ ដូច្នេះខ្ញុំគឺស្នើសុំឲ្យអង្គជំនុំជម្រះមិនទទួលយកនូវឯកសារនេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ អាឡាំង វ៉ែនណឺ ។

[១៥:៤៤:៤០]

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន! ខ្ញុំធ្វើការឆ្លើយតបដោយសង្ខេប ។

សូមអរគុណលោកប្រធាន ។ ដោយសង្ខេបបំផុតនោះ ទាក់ទងទៅនឹងសំណើទីមួយដែលសហសេរិករបស់ខ្ញុំបានធ្វើ ។ ដោយយោងតាមវិធានផ្ទៃក្នុងគឺយើងនៅទីនេះដើម្បីជួយដល់សហព្រះរាជអាជ្ញា ហើយសហសេរិករបស់ខ្ញុំ ហើយទាំងយើងខ្ញុំផងដែរ ចាត់ទុកថានេះគឺភារកិច្ចរបស់ខ្ញុំ ។ ហើយយើងមានអារម្មណ៍ថាចំណុចនេះសំខាន់ណាស់ ដែលថាឯកសារនេះ ដែលមានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយនោះ ។ ខ្ញុំមិនយល់ថា នេះជាតួនាទីរបស់ខាងមេធាវីការពារក្ដីក្នុងការបដិសេធនោះទេ ។

ហើយចំណុចទីពីរ នេះគឺជាឯកសារដែលមានចំនួនតិចតួចបំផុត គឺឯកសារថ្មីនេះមានតែ១៨ទំព័រ តែប៉ុណ្ណោះ មិនមែនរាប់រយសន្លឹកនោះទេ ។ ហើយបើសិនជាជនជាប់ចោទមិនអាចឆ្លើយ-- ខាងមេធាវីការពារក្ដីមិនអាចឆ្លើយតបបាននោះ ដូចជាមិនសមរម្យទេ ពីព្រោះអីថ្ងៃនេះ គឺយើងបាននិយាយអំពីចំណុចនេះ គឺដើម្បីផ្ដល់ឱកាសឲ្យមេធាវីការពារក្ដីធ្វើការឆ្លើយតប ។ ដូច្នេះ មេធាវីការពារក្ដី គឺមានតួនាទី មានជំហរក្នុងការឆ្លើយតបបាន អាចសរសេរជាលាយលក្ខណ៍អក្សរ ។ ហើយគឺថាពួកគាត់មានពេលវេលាទាំងអស់ ដើម្បីធ្វើការឆ្លើយតបអំពីអ្វីដែលយើងបាន ឬក៏ដែលនឹងស្នើដល់ចំពោះមុខអង្គជំនុំជម្រះ អាចធ្វើនៅសប្ដាហ៍ក្រោយ គឺថាឯកសារនេះគួរតែទទួលយក ហើយសន្និដ្ឋានថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយនោះ ។

ដូច្នេះ ខ្ញុំជឿថា នេះគឺជាចំណុចមួយដែលខ្ញុំលើកឡើងជាទឡ្ហីករណ៍ ដោយថាឯកសារអស់ទាំងហ្នឹង វាមានភាពពាក់ព័ន្ធយ៉ាងជាក់លាក់បំផុត ហើយវាមានសារសំខាន់បំផុតសម្រាប់យើង ដើម្បីឲ្យពួកយើងគាំទ្រនូវការលើកឡើងរបស់យើងដែលថា នៅក្នុងការធ្វើការវិនិច្ឆ័យរបស់លោក លោកស្រីហ្នឹងគឺ

ថា មិនគួរមិនបញ្ចូលនូវភាគីជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់យើងខ្ញុំនោះទេ ។ នេះមិនមែនជាបញ្ហាមិនសំខាន់ ឬក៏បន្ទាប់បន្សំសម្រាប់ខ្ញុំទេ គឺថាយើងបានពិភាក្សាពីបញ្ហានេះរួចទៅហើយ ។

នៅក្នុងអំឡុងពេលនៃសវនាការ នៅមុខអង្គជំនុំជម្រះនេះ ហើយមេធាវីការពារក្ដីជាពិសេស ជនជាប់ចោទបានទទួចថា គាត់នឹងមិនទទួលស្គាល់អ្នកនេះ ឬក៏អ្នកនោះជាបុគ្គលនៅស-២១នោះទេ ពីព្រោះឈ្មោះរបស់គាត់នោះមិនមាននៅក្នុងបញ្ជី ។ ហើយគាត់តែងតែនិយាយ ប្រកែកនៅចំណុចនេះជាច្រើនដង ។ ហេតុដូច្នេះ គឺយើងមានតួនាទីជាអ្នកតំណាងឲ្យកូនក្ដីរបស់យើងស្វែងរកមធ្យោបាយផ្សេង ដើម្បីឲ្យអស់លោក លោកស្រីចៅក្រមជឿជាក់ថា នោះគឺមិនមែនជាបញ្ហាតែមួយទេ ដែលថាមិនមានឈ្មោះនៅក្នុងបញ្ជីនោះ គឺឈ្មោះសរុបដែលខាងសហព្រះរាជអាជ្ញាបានធ្វើនោះ ដែលថាមនុស្សប្អូននាក់នេះមិនអាចត្រូវបានគេឃុំខ្លួននៅស-២១ ឬក៏យ៉ាងម៉េចនោះ ។

ខ្ញុំឯកភាពហើយថា បញ្ជីនេះគឺមិនមានឈ្មោះកូនក្ដីរបស់ខ្ញុំទេ ក៏ប៉ុន្តែបញ្ជីនេះគឺជាការលើកឡើងនូវទឡ្ហីករណ៍មួយដ៏ល្អដើម្បីការពារនូវគំនិតដែលថា ឈ្មោះរបស់អ្នកដែលមាននៅក្នុងបញ្ជីនេះ ហើយដែលយើងគ្មានមន្ទិលសង្ស័យដែលថា ពួកគាត់នោះបានស្លាប់នៅស-២១ ដោយសារការធ្វើអត្តឃាត ឬក៏ដោយសារជំងឺ ឬក៏មធ្យោបាយផ្សេងៗទៀតនោះ គួរតែដាក់បញ្ចូលទៅក្នុងសំណុំរឿង ។ ពួកយើងលើកឡើងនេះ គឺដោយមានចិត្តស្មោះត្រង់បរិសុទ្ធក្នុងការបង្ហាញអំពីទឡ្ហីករណ៍នេះ ។ ហើយកូនក្ដីរបស់ខ្ញុំ ទោះបីជាមិនមានឈ្មោះនៅលើបញ្ជីសរុបនោះក៏ដោយ ក៏ប៉ុន្តែឈ្មោះដប់ប្អូននាក់ទៀត ដែលខ្ញុំរកឃើញនៅក្នុងសំណុំរឿងថ្មីនេះក៏មិនមាននៅក្នុងបញ្ជីនោះដែរ ។

ដូច្នេះខ្ញុំយល់ថា គឺវាមានពាក់ព័ន្ធយ៉ាងខ្លាំងបំផុតទៅនឹងសំណុំរឿងនេះ ដូច្នេះគួរតែដាក់បញ្ចូល និងសន្និដ្ឋានថាដាក់បញ្ចូលនៅក្នុង នៅចំពោះមុខ ។

[១៥:៤៩:០៤]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន! មិនមាននរណាគេធ្វើការចោទសួរទៅលើឆន្ទៈល្អរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទេ ។ ហើយសំណួរនេះ ក៏មិនមែនទាក់ទងពីឆន្ទៈល្អរបស់ពួកគាត់ដែរ ប៉ុន្តែចំណុចនេះគឺទាក់ទងទៅនឹងអង្គច្បាប់។ ដូច្នេះ គឺអាចជាលទ្ធភាពដែលថា អ្នកដែលលោក លោកស្រីដែលគាត់ជាអ្នកតំណាងឲ្យជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ អាចមានសាច់ញាតិនៅស-២១ ។ ក៏ប៉ុន្តែក្នុងចំណុចនេះ គឺថាពួកគាត់មិនមានគោលជំហរក្នុងការចោទប្រកាន់ អំពីភាពហ្មត់ចត់របស់ ឌុច នោះទេ ។ ឥឡូវនេះ ពួកគាត់ចង់

និយាយថា អាចនឹងមានមនុស្សដែលធ្លាប់បាននៅស-២១ ប៉ុន្តែមិនមាននៅក្នុងបញ្ជី ចំណុចនេះ មិនគួរតែលើកមកពិភាក្សាទេ ។

តុលាការបានធ្វើការសន្និដ្ឋានហើយថា ប្រហែលជាពួកគាត់ទាំងហ្នឹង អាចធ្លាប់បាននៅស-២១ ហើយមេធាវីរបស់ពួកគាត់នុ៎ង ។ បើសិនជាគាត់ចង់ប្រកាន់យកគោលជំហរនេះ ថាតើយើងស្វែងរកយុត្តិធម៌យ៉ាងម៉េចទៅ? បើសិនជាកូនក្តីរបស់គាត់ជឿថា សាច់ញាតិរបស់គាត់មាននៅស-២១ គឺថាខ្ញុំមិនជំទាស់អំពីសុច្ឆន្ទៈរបស់ពួកគាត់ទេ ។ ក៏ប៉ុន្តែនៅពេលដែលយើងនៅក្នុងតុលាការច្បាប់ គឺថាយើងចាំបាច់ត្រូវធ្វើដោយអាស្រ័យទៅឯកសារដែលជាភស្តុតាងនោះ ហើយជាពិសេស គឺថាដែលថាជនជាប់ចោទជាមនុស្សម្នាក់ដែលធ្វើការងារយ៉ាងហ្មត់ចត់ក្នុងការរៀបចំឯកសាររបស់ខ្លួន ។

ដូច្នេះ លោកប្រធាន ចំណុចសំខាន់នៃការពិភាក្សាគ្នាដែលបានកើតឡើងនោះ គឺជាការលើកឡើងសម្រាបដូចថា សម្រាប់ការធ្វើសន្និសីទវិញទេ ។ ប៉ុន្តែបើសិនជាយើងធ្វើការពិភាក្សាបែបនេះនៅចំពោះអង្គចៅក្រមវិញនោះ គឺវាចាំបាច់ត្រូវអាស្រ័យលើឯកសារ ហើយថ្ងៃនេះលោកបានលើកឡើងនូវឯកសារដែលនិយាយថា ជនជាប់ចោទហ្នឹង គាត់ជា-- គាត់មានពិរុទ្ធភាពហ្នឹងឬ? មានន័យថា ជាការខាតបង់ពេលវេលាទេ ពីព្រោះអីគឺថា ជនជាប់ចោទបាននិយាយហើយថា គាត់ទទួលពិរុទ្ធភាពរបស់គាត់ ។

ដូច្នេះ លោក លោកស្រីចៅក្រមនៅក្នុងករណីនេះ ខ្ញុំមិនមានឃើញវិធីដំណោះស្រាយណាផ្សេងក្រៅពីផ្តល់ការធានាដល់ដើមបណ្តឹងរដ្ឋប្បវេណីថា តើនៅក្នុងសេចក្តី-- នៅក្នុងសាលក្រមរបស់លោកលោកស្រីនោះ គឺថា មេធាវីរបស់គាត់ធ្វើឡើងដោយសុច្ឆន្ទៈ ប៉ុន្តែលោកស្រីត្រូវរំឭកពួកគាត់អំពីកត្តាច្បាប់ផងដែរ អំពីអ្វីដែលបានកើតមានឡើងនៅក្នុងអង្គសវនាការនេះ ដែលថាចួនកាលភាគីណាមួយអាចធ្វើសេចក្តីសម្រេចខុសដោយសុច្ឆន្ទៈរបស់ខ្លួន ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។ អញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ទាក់ទងទៅនឹងបញ្ជីដែលលើកឡើងដោយមេធាវីការពារក្តី ថាខ្ញុំសូមសួរលោកបន្ថែមទៅលើរយៈពេលទៅនឹងទីកន្លែង ហើយនិងពេលវេលាដែលលោកបានបង្កើតទៅលើបញ្ជីដែលមាន១៨ទំព័រនោះ ។ តាមអ្វីដែលខ្ញុំយល់ លោកបានទទួលការបកប្រែនៅថ្ងៃទី២៦ ខែសីហា ដូច្នេះ ហើយលោករង់ចាំមួយអាទិត្យក្នុងការថតចម្លងទៅលើឯកសារនោះ ថាតើខ្ញុំយល់ត្រឹមត្រូវ

ដែរឬទេ ដែលថា លោករកឃើញឯកសារនេះមួយអាទិត្យមុនរួចទៅហើយ?

ហើយចំណុចទីពីរ ចាប់ពីថ្ងៃទី២៦ ខែសីហា មកទល់ពេលបច្ចុប្បន្ន យើងមើលទៅបានបីសប្តាហ៍ហើយ តើលោកអាចពន្យល់បានដែរឬទេ ហេតុអ្វីបានជាឯកសារនុំង ផាតុផ្សំឯកសារនុំងមិនបានដាក់ជូនចំពោះមុខអង្គសវនាការរបស់យើង? ហេតុអ្វីបានជាសារសំខាន់នៃផាតុផ្សំឯកសារទាំងអស់ហ្នឹង វាបាននៅតែពិភាក្សាដដែលនៅក្នុងរយៈពេលបីអាទិត្យហ្នឹង? តើលោកអាចពន្យល់ខ្ញុំឲ្យយល់ទៅលើចំណុចហ្នឹងបានដែរឬទេ?

[១៥:៥៣:៤៥]

**កញ្ញា ទី ស្រ៊ុនណា៖**

សូមអរគុណលោកស្រីចៅក្រម ។ ទាក់ទងទៅនឹងបញ្ហានេះ នាងខ្ញុំសូមជម្រាបជូនលោកស្រីចៅក្រមថា នាងខ្ញុំបាន-- ថ្ងៃ២៦ ខែសីហា ឆ្នាំ២០០៩ គឺជាថ្ងៃដែលយើងទទួលបានឯកសារទាំងនោះ ពីព្រោះថា យើងបានចំណាយពេលវេលាមុនហ្នឹងដើម្បីស្វែងរកឯកសារទាំងនោះ ហើយបន្ទាប់ពីការដែលយើងរកបានឯកសារទាំងនោះមក យើងយកឯកសារទាំងនោះដើម្បីធ្វើការពិនិត្យបន្ថែមទៀត ដើម្បីប្រៀបធៀប ដើម្បីស្វែងរកឈ្មោះរបស់កូនក្តីយើងខ្ញុំ ថាតើមានការពាក់ព័ន្ធនៅក្នុង-- មានឈ្មោះកូនក្តីរបស់យើងខ្ញុំនៅក្នុង-- មានសាច់ញាតិរបស់កូនក្តីយើងខ្ញុំនៅក្នុងចំណុចនោះដែរឬអត់? ពេលនុំង គឺជាពេលដែលយើងស្វែងរកទៅយើងឃើញថា មានអ្នកទោសជាច្រើនដែលបានស្លាប់នៅក្នុងមន្ទីរស-២១នុំងដោយមិនមានឈ្មោះនៅក្នុងបញ្ជីកម្ទេច ហើយក៏មិនមានឈ្មោះនៅក្នុងបញ្ជីក្តាប់កម្លាំងអ្នកទោសប្រចាំថ្ងៃនោះ គឺគ្រាន់តែសរសេរទាក់ទងទៅនឹងចំនួនអ្នកទោសនៅក្នុងមន្ទីរស-២១នោះ ។ ចំពោះអ្នកដែលស្លាប់ អ្នកដែលគេយកទៅសម្លាប់ទើបគេសរសេរឈ្មោះចេញនៅក្នុងបញ្ជីនោះ នេះគឺជាចំណុចមួយដែលយើងធ្វើការប្រៀបធៀបទៅឃើញថា សាច់ញាតិរបស់កូនក្តីយើងខ្ញុំទាំងបួននាក់នោះ គឺស្ថិតនៅក្នុងកាលៈទេសៈបែបនោះដែរ ។ មានន័យថា ពួកគាត់ត្រូវបានស្លាប់នៅក្នុងមន្ទីរស-២១ ដោយពុំមានបញ្ជីនិងឯកសារច្បាស់លាស់ដើម្បីយកមកគាំទ្រនៅក្នុងការពាក្យបណ្តឹងជាដើមបណ្តឹងរដ្ឋប្បវេណី ។

ហើយទាក់ទងទៅនឹងចំណុចមួយទៀត មូលហេតុដែលយើងខកខាននៅក្នុងការដាក់ឯកសារនុំងឲ្យទាន់ពេលវេលា គឺក្នុងអំឡុពេលប៉ុន្មានសប្តាហ៍នេះ គឺជាសប្តាហ៍នៃការដេញដោលទៅលើសាក្សី ក៏ដូចជាអ្នកជំនាញដែលដាក់ដោយមេធាវីការពារក្តី ហើយនៅក្នុងអំឡុងពេលហ្នឹងដែរ ខាងតុលាការក៏មិនអនុញ្ញាតឲ្យយើងខ្ញុំបញ្ចូលនូវឯកសារថ្មីៗនោះដែរ គឺបានកំណត់យ៉ាងច្បាស់ថា អាចដាក់បានគឺនៅក្រោយ

ពេលបញ្ចប់ការដេញដោលទៅលើ-- ការសួរដេញដោលទៅសាក្សី ក៏ដូចជាអ្នកជំនាញដែលបានដាក់ដោយមេធាវីការពារក្តី ។ នេះជាហេតុមួយដែលធ្វើឲ្យយើងរង់ចាំឱកាសដើម្បីដាក់នូវឯកសារនេះផងដែរ ។ នេះគឺជាមូលហេតុដែលយើងខ្ញុំជួបប្រទះ គឺជាឧបសគ្គដែលយើងជួបប្រទះនៅក្នុងការដាក់ឯកសារនេះ ។ សូមអរគុណ ។

[១៥:៥៦:៥៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំគ្រាន់តែសួរសំណួរពីលោកប្រធានថាតើខ្ញុំអាចផ្តល់យោបល់នៅពេលនេះដែរឬទេ? សូមអរគុណលោកប្រធាន ។ ចំណុចមួយទៀតដែលខ្ញុំសូមលើកឡើង មុនដំបូងគឺយើងខ្ញុំពិភាក្សាផ្ទៃក្នុងដើម្បីស្វែងយល់ទៅលើឯកសារនោះ ។ ទីពីរ គឺយើងបានពិភាក្សាជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញាដើម្បីឲ្យយើងអាចបញ្ជាក់ឲ្យបានច្បាស់លាស់ថា ឯកសារដែលយើងមាននេះគឺវាមិនដូចគ្នា ហើយការិយាល័យសហព្រះរាជអាជ្ញាមិនមាន ។ ដូច្នេះ ហើយមិនមែនថាឯកសារដែលយើងមិនមាននៅក្នុងសំណុំរឿងនោះទេ ។ តាមពិតទៅយើងខ្ញុំក៏បានពិភាក្សាជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញាផងដែរ ហើយចំណុចចុងក្រោយ ដូចដែលលោក លោកស្រីចៅក្រមបានជ្រាបហើយ នៅក្នុងរយៈពេលបីបួនសប្តាហ៍ គឺយើងឃើញថាមានដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការ ហើយបន្ទាប់មានការដេញដោលទៅលើអត្តចរិតរបស់ជនជាប់ចោទ ។ ហើយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះគឺមិនឲ្យយើងចូលរួមដូច្នេះ ហើយយើងមិនមានលទ្ធភាពនៅក្នុងដំណាក់កាលនុ៎ង ដែលយើងដាក់ឯកសារនិងស្នើសុំចំពោះឯកសារ ឬក៏ចំពោះយើងនៅក្នុងការដាក់សំណើទៅតាមវិធាន៨៧.៤ ។ ដូច្នេះ ហើយយើងបានគិតថាអនុលោមតាមវិធាន៨៧.៤ ។ យើងអាចដាក់ឯកសារទាំងឡាយរហូតដល់ពេលបញ្ចប់សវនាការតែម្តងមិនមែនថាបញ្ចប់សវនាការដេញដោលភស្តុតាងប៉ុណ្ណឹងទេ អ៊ីចឹងយើងអាចដាក់រហូតដល់បញ្ចប់សវនាការទាំងមូល ។

[១៥:៥៨:៥១]

ដូច្នេះហើយយើងមានរយៈពេលដែលត្រូវដាក់សំណើសុំក្នុងរយៈពេលដែលបានកំណត់នៅក្នុងនេះ ដូច្នេះ ហើយទើបយើងលើកឡើងការពិភាក្សាដេញដោលនៅក្នុងថ្ងៃនេះ ហើយយើងខ្ញុំក៏បានសម្រេចចិត្ត

បង្ហាញទៅដល់មេធាវីក្តីទៅលើវត្ថុតាងនិងភស្តុតាង ហើយយើងក៏បានលើកឡើងបញ្ហានេះដើម្បីដេញដោលចំពោះមុខអង្គសវនាការ ។ ដូច្នេះ ហើយជាចំណុចមួយដែលខ្ញុំឲ្យលោកប្រធាន លោក លោកស្រីចៅក្រមជ្រាបទៅលើករណីនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំចង់ដឹងពីខាងសហព្រះរាជអាជ្ញា ថាតើសហព្រះរាជអាជ្ញាបានដឹងអំពីឯកសារដែលដើមបណ្តឹងរដ្ឋប្បវេណីគាត់មានបំណងក្នុងការស្នើសុំដាក់ជូនចំពោះមុខអង្គសវនាការរបស់យើងដែរឬទេ? ថាតើសហព្រះរាជអាជ្ញា គាត់បានដឹងអំពីគោលបំណងនៃការដាក់សំណើដែរឬទេ? ហើយគាត់ដឹង តើសហព្រះរាជអាជ្ញាអាចដឹងថាដែរឬទេថាឯកសារនេះវាអាចជួយទៅដល់ការលាតត្រដាងទៅដល់ការពិត ។

**លោក អានីស អះមេដ៖**

គឺដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំជួបជាមួយនឹងសហព្រះរាជអាជ្ញាយើងខ្ញុំ ហើយនៅក្នុងកិច្ចប្រជុំនោះ គឺខ្ញុំបានចូលរួមជាមួយសហការីនិងសហសេវិករបស់ខ្ញុំម្នាក់ ។ យើងក៏បានជម្រាបទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា ប្រហែលវាជាឯកសារពាក់ព័ន្ធ ហើយវាអាចពាក់ព័ន្ធទៅនឹងអង្គហេតុដែលយើងដោះស្រាយនៅក្នុងសវនាការរបស់យើង ។ ប៉ុន្តែការពិចារណាលើវិធាន៨៧.៤នោះ គឺយើងត្រូវបង្ហាញឲ្យបានសមរម្យដើម្បីតុលាការទទួលយកឯកសារនេះ ។

ហើយយើងខ្ញុំសូមលើកឡើងថា វាអាស្រ័យទៅលើអង្គជំនុំជម្រះក្នុងការពិចារណាទៅលើការដាក់នូវឯកសារនេះ ហើយយើងនឹងអនុវត្តតាមទៅតាមអ្វីដែលលោកចៅក្រមបានណែនាំ ។ ហើយយើងក៏គិតដែរថាឯកសារហើយ-- យើងក៏បានពិចារណាដែរ ថាឯកសារនេះវាមានភាពចាំបាច់ ហើយវាពាក់ព័ន្ធដូច្នេះ ហើយយើងគួរតែពិចារណាទៅលើការដាក់សំណើរនេះផងដែរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

[១៦:០១:២០]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ។ វាហាក់ដូចជាបង្ហាញយ៉ាងច្បាស់ហើយដែលថា ឯកសារទាំងអស់នេះបានកំពុងតែសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ ដូច្នេះ យើងគួរតែបើកការដេញដោលសាជាថ្មីដើម្បីឲ្យជនជាប់ចោទមានលទ្ធភាពផ្ដល់យោបល់ទៅលើឯកសារដែលបាន-- ដែលមានបំណងស្នើសុំនេះ ។ សូមអភ័យទោស ប៉ុន្តែវាហាក់ដូចជាធ្វើទៅរួចទេ យើងបានប្រឹងប្រែងហើយថា កុំឲ្យមានសវនាការមួយដែលពន្យារ ហើយវាហាក់ដូចជាមានការស្នើសុំឲ្យពន្យាររយៈពេលសវនាការរបស់យើងអ៊ីចឹង ។ ដូច្នេះ ហើយយើងដឹងហើយថា ជនជាប់ចោទគាត់ទទួលស្គាល់ទៅលើគ្រប់យ៉ាងទាំងអស់ហើយ ហើយថាតើឯកសារនោះវាមិនបង្ហាញអំពីពិរុទ្ធភាពយ៉ាងម៉េច? ហើយហាក់ដូចជាឯកសារទាំងនោះវាមិនកើតចេញពីកូនក្ដីរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ។ ដូច្នេះ ហើយនេះជាការយល់ឃើញចំពោះការយល់ឃើញនៃការស្វែងរកយុត្តិធម៌ ហើយយើងអាចធ្វើការដេញដោលទៅលើភស្តុតាងហ្នឹង នៅថ្ងៃទី២៨ ខែធ្នូ បាន ។

**លោក អាឡាំង វែនណឺ៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតនិយាយមួយម៉ាត់ ពីរម៉ាត់ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនិយាយគ្នាឲ្យហើយ លោកនិយាយប៉ុន្មានដងទៀតដើម្បីឲ្យច្បាស់លាស់? រាប់ដងតែម្ដងទៅថាតើលោកសុំនិយាយប៉ុន្មានដងទៀតនៅក្នុងករណីនេះ? ដើម្បីតុលាការនឹងសម្រេចឲ្យហើយ ចៀសវាងដូច្នេះវាមិនត្រឹមត្រូវទេ វានាំឲ្យមានការអូសបន្លាយពេលវេលា ។ លោកអាចនិយាយបានទេ ថាតើសុំនិយាយហ្នឹងប៉ុន្មានដងទៀតរបៀបនេះ? អាចឆ្លើយបានទេ? ករណីហ្នឹង ឆ្លើយឆ្លងៗគ្នាប៉ុន្មានដងទៀត?

[១៦:០៣:១១]

**លោក អាឡាំង វែនណឺ៖**

លោកប្រធានខ្ញុំសូមគោរព! លោកប្រធានបានស្នើសុំឲ្យសហព្រះរាជអាជ្ញាចំពោះបញ្ហានៃការដាក់ឯកសារនេះ ដែលសហព្រះរាជអាជ្ញាគាត់បានលើឡើងអំពីចំណុចហ្នឹង ហើយមេធាវីការពារក្ដីនិយាយអម្បាញ់មិញដែរ ។ ដូច្នេះ ហើយវាចំណុចដែលថា សមស្រប ហើយនិងត្រឹមត្រូវដែលខ្ញុំឆ្លើយតបទៅលើចំណុច ដូច្នេះ ហើយវាជាភាពត្រឹមត្រូវដែលខ្ញុំសូមឆ្លើយតបទៅលើអ្វីដែលលោកមេធាវីហ្វ្រង់ស្វ័រ រូ បានលើកឡើង ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំមិនយល់នូវអ្វីដែលលោកនិយាយនេះទេ កំពុងតែជជែកយកឈ្នះ យកចាញ់ យកខុស យកត្រូវ រៀងខ្លួន ស្រាប់មកថាឥឡូវក៏ដូចជាគំនិតស្របគ្នា រវាងព្រះរាជអាជ្ញា ជាមួយនិងមេធាវី ហ្វ្រង់ស្វ័រ រ៉ូ ។ លោកបញ្ជាក់ម្តងទៀតមើល៍ ឲ្យច្បាស់ ហើយជាលើកចុងក្រោយនៃការជជែកអំពីបញ្ហាដែលបានលើកឡើងនេះ ដើម្បីទុកលទ្ធភាពជូនដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតលើកបញ្ហាផ្សេងទៀត ដើម្បីលៃពេលវេលាអាចស្អែក ដើម្បីក្តាប់បញ្ហាទាំងអស់ហ្នឹងឲ្យជុំ ហើយនិងតើកំណត់ថាសវនាការនឹងត្រូវធ្វើបន្តប៉ុន្មានសប្តាហ៍ ដើម្បីបិទការស៊ើបសួរ-- ដើម្បីបិទការពិភាក្សាដេញដោលនោះ? បើបញ្ហានេះ វាទំហំធំធេងវាត្រូវតែបើកការជជែកដេញដោលពិនិត្យលើឯកសារ ដែលមានបញ្ហាដែលដាក់ដោយភាគីនេះ ។ តើព្យាករណ៍ ឬក៏ប៉ាន់ស្មានពេលវេលាត្រូវដេញដោលប៉ុន្មានសប្តាហ៍ទៀតមុននឹងបិទនោះ? អ៊ីចឹងវាឥទ្ធិពលដល់ដំណើរប្រព្រឹត្តទៅនៃការ ដែលកំណត់ការបរិច្ឆេទនៅសេចក្តីសន្និដ្ឋានផ្ទាល់មាត់ចុងក្រោយដែលបានកំណត់រួចហើយ ។

**លោក អាឡាំង វែនណឺ៖**

ខ្ញុំនឹងលើកឡើងដោយសង្ខេប។ ជាបឋមដូចដែលខ្ញុំបានលើកឡើងច្រើនដងហើយ គឺថាយើងខ្ញុំពិចារណាថា ឯកសារនេះវាមានភាពពាក់ព័ន្ធ ហើយប្រសិនបើមេធាវីការពារក្តីលើកឡើងថា ឯកសារនេះមិនមានតម្លៃ ។ ដូច្នេះហើយខ្ញុំគិតថា អនុលោមតាមវិធាន ៨៧.៤ គឺវាអនុញ្ញាតឲ្យមេធាវីការពារក្តីឆ្លើយតបជាលាយលក្ខណ៍អក្សរ ហើយជនជាប់ចោទគឺអាចឆ្លើយតបទៅនឹងឯកសាររបស់ខ្ញុំតាមរយៈមេធាវីរបស់គាត់ ។

លោកប្រធានជាទីគោរព! សហព្រះរាជអាជ្ញាគឺគាត់មិនបានប្រកាន់ជំហររបស់គាត់នោះទេ ហើយគាត់ក៏មិនយល់ស្របជាមួយមេធាវីការពារក្តី ឬក៏គាត់មិនយល់ស្របជាមួយនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីរបស់យើងនោះដែរ ។ ដូច្នេះគាត់មិនប្រកាន់ជំហររបស់គាត់នៅខាងភាគីណាមួយនៅឡើយទេ ។ សូមអរគុណ ។

[១៦:០៧:៥០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំគ្រាន់តែចង់ឲ្យយើងត្រឡប់ទៅលើបញ្ហាដែលបានលើកឡើងដោយមេធាវីការពារក្តីឡើងវិញអម្បាញ់មិញនេះ ។ ចំណុចដែលលើកឡើងនោះ គឺទាក់ទងទៅនឹងការសង្ខេបឯកសារជាភាសាបារាំង ជាពិសេសគឺឯកសារដែលសហព្រះរាជអាជ្ញាមានបំណងក្នុងការដាក់នៅចំពោះមុខតុលាការ ហើយឯកសារនុ៎ងគឺវាពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ ។ អ្វីដែលខ្ញុំចង់ដឹងពីខាងសហព្រះរាជអាជ្ញានោះ គឺថា តើការការធ្វើឯកសារសង្ខេបនៅរាល់ឯកសារនីមួយៗភ្ជាប់ទៅនឹងឯកសារដើមនោះបានបញ្ជូនទៅបកប្រែជាភាសាបារាំងរួចហើយឬនៅ? ហើយខ្ញុំចង់ដឹងថា តើវាពិតដូចដែលមេធាវីការពារក្តីលើកឡើងដែរឬទេ? ខ្ញុំនឹងសួរមេធាវីការពារក្តីនៅពេលក្រោយ។ បន្ទាប់មុនដំបូងខ្ញុំសូមឲ្យខាងសហព្រះរាជអាជ្ញាឆ្លើយទៅនឹងសំណួររបស់ខ្ញុំសិន ថាតើមានការដាក់សំណើសុំបកប្រែទៅលើបញ្ជីឯកសាររបស់លោកដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរបស់យើងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធហើយឬនៅ?

[១៦:០៨:៣៨]

**លោក អានីស អះមេដ៖**

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ នៅពេលដែលយើងបានដាក់នៅឧបសម្ព័ន្ធរបស់យើងទាក់ទងភ្ជាប់ទៅនឹងជម្លោះប្រដាប់អាវុធដែលនៅក្នុងនោះគឺមានឯកសារមួយចំនួន-- ទំព័រមួយចំនួនគឺជាសេចក្តីសង្ខេបពិស្តារទៅលើឯកសារគឺជាការដាក់ឯកសារពីរភាសា ជាពីរភាសារបស់សហព្រះរាជអាជ្ញាតាមសេចក្តីណែនាំអនុវត្ត ។ នៅពេលដែលយើងដាក់ជាពីភាសាហើយនោះនៅការិយាល័យចៅក្រមស៊ើបអង្កេត ។ ដូច្នេះហើយវាជាការងាររបស់ផ្នែកគ្រប់គ្រងតុលាការក្នុងការបកប្រែទៅជាភាសារបស់ភាគីផ្សេងទៀត ។ ហើយនៅក្នុងដំណាក់កាលនេះ គឺខ្ញុំមិនអាចជួយជម្រាបលោកចៅក្រមទៅលើបញ្ហានេះទាក់ទងទៅនឹងការបកប្រែនោះទេ ។ ហើយខ្ញុំអាចជម្រាបជូនលោកចៅក្រមនៅថ្ងៃស្អែកថា ការបកប្រែនោះយ៉ាងម៉េច? ប៉ុន្តែយើងខ្ញុំបានដាក់ជាពីរភាសាហើយ គឺភាសាអង់គ្លេសនិងភាសាខ្មែរ ហើយជាភាសាផ្លូវការដែលយើងបានជ្រើសរើសអនុលោមទៅតាមសេចក្តីណែនាំអនុវត្ត ។ ប៉ុន្តែ នៅពេលនេះខ្ញុំមានវេទិកាហើយ គឺខ្ញុំសូមបន្ថែមទៅលើចំណុចមួយ ឯកសារជាច្រើននេះ គឺខ្ញុំនឹងផ្តល់ចំនួនប្រសិនបើខ្ញុំមានពេល ។

ឯកសារនោះ គឺជាឯកសារ វាមិនមែនជាឯកសារសង្ខេបទេ ហើយវាមានជាភាសាច្រើន ហើយ

វាមានឯកសារ៤៣០ ហើយនិង២០០ឯកសារផងដែរ ដែលមានភាសាខ្មែរ និងអង់គ្លេស ។ ដូច្នេះហើយ គឺខ្ញុំនឹងជម្រាបលោក លោកស្រីចៅក្រមទាក់ទងទៅនឹងលទ្ធភាពនៃការបកឯកសារ ឬក៏ការរង់ចាំការបកឯកសារទៅលើអត្ថបទទាំងអស់នេះ ។ សូមអរគុណ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំនឹងរង់ចាំការបញ្ជាក់ទៅលើការបកប្រែភាសាបារាំងនៅថ្ងៃស្អែក ។ ដូច្នេះ នៅពេលនេះខ្ញុំសូមសួរមេធាវីការពារក្តី ។ ខ្ញុំយល់ថា តំណាងសហព្រះរាជអាជ្ញាបានធ្វើការដាក់សំណើសូមបញ្ចូលឯកសារទៅលើចម្លើយសារភាព ដែលចម្លើយសារភាពនោះវាទំនងជាការគាំទ្រ ហើយមានចំណាររបស់ជនជាប់ចោទ ។ ហើយសំណើនេះ ខ្ញុំគិតថា គឺថាលោកទាំងពីរភាគីសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីគួរតែពិភាក្សា ជួបគ្នាពិភាក្សាទៅលើថា តើឯកសារណាខ្លះដែលយើងគួរតែដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ដូច្នេះអ្វីដែលខ្ញុំចង់ដឹងនោះ គឺថាមេធាវីការពារក្តីនឹងទទួលយកសំណើរបស់សហព្រះរាជអាជ្ញាដែរឬទេ? ឬក៏បានទទួលយល់ស្របទៅនឹងការដាក់សំណើរបស់សហព្រះរាជអាជ្ញារួចទៅហើយ? ខ្ញុំចង់ឲ្យលោកបញ្ជាក់ទៅលើចំណុចហ្នឹង ។

[១៦:១១:២៩]

**លោក ហ្រ្វង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំគឺថាអាចបត់បែនទៅបានទៅតាមកាលៈទេសៈ ហើយខ្ញុំនឹងជម្រាបអង្គជំនុំជម្រះថា យើងមានពេលវេលាគ្រប់គ្រាន់អាចពិភាក្សាបានជាមួយនឹងខាងការិយាល័យសហព្រះរាជអាជ្ញា ហើយពេលវេលាទាំងអស់នេះដែលយើងមានវាហាក់ដូចជាមានប្រយោជន៍ទេ ។ ដូច្នេះហើយខ្ញុំនឹងមិនចំណាយពេលបន្ថែមទៀតក្នុងការពិភាក្សានោះទេ ។ ប្រសិនបើការិយាល័យសហព្រះរាជអាជ្ញាផ្តល់នូវឯកសារដើម្បីឲ្យខ្ញុំប្រើពេលតិចនោះ ដើម្បីដាក់ជូននៅចំពោះមុខតុលាការរបស់យើង ដូច្នេះចំពោះភាគីរបស់ខ្ញុំគឺខ្ញុំនឹងមិនដើរហួស ឬក៏អនុវត្តហួសទៅលើពេលវេលានោះទេ ។ យើងមានរយៈពេលបីខែ ចំពោះការទទួលយកអង្គហេតុហើយ ហើយយើងមានទាំងពេលថ្ងៃ ពេលយប់ពិចារណាទៅលើអង្គហេតុដែលយើងត្រូវទទួលស្គាល់ទាំងអស់នោះ ។

[១៦:១២:៤៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**លោក អានីស អះមេដ៖**

ខ្ញុំមិនមែនថាចង់និយាយមិនចេះចប់នោះទេ ប៉ុន្តែខ្ញុំសូមបញ្ចប់នៅត្រង់នេះ ដោយឆ្លើយតបទៅនឹងការសង្កេតរបស់មេធាវីការពារក្តី ។ បញ្ហាដែលមាននៅចំពោះមុខអង្គសវនាការនេះ គឺវាទាក់ទងទៅនឹងឯកសារចំណារ ហើយវាមិនពាក់ព័ន្ធទៅនឹងការព្រមព្រៀងទៅលើអង្គហេតុនោះទេ ។ ដូច្នេះហើយខ្ញុំសូមលើកឡើងដោយគោរពថា ដោយពិចារណាទៅលើការទទួលនូវឯកសារផ្សេងៗទៀតហើយពីខាងមេធាវីការពារក្តី ។ ដូច្នេះហើយយើងអាចពិចារណាថា មេធាវីការពារក្តីប្រសិនបើចង់នោះ ចង់ធ្វើការវាយតម្លៃទៅលើឯកសារដែលគាត់ចង់យល់ស្របនោះ គាត់អាចធ្វើទៅបាន ។ ដូច្នេះហើយគិតថា យើងគិតថាឯកសារទាំងអស់នេះគួរតែបញ្ចូលទៅក្នុងសំណុំរឿង ហើយយើងអាចចាត់ទុកថាវាបានដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ដោយផ្អែកទៅលើការដាក់ពាក្យសុំរបស់យើង ។

[១៦:១៣:៤៩]

ខ្ញុំសូមបន្ថែមថា យើងបានដកចេញពីបញ្ជីនៅឯកសារដែលបានដាក់នៅចំពោះមុខឯកសារ ហើយត្រូវបានទទួលលេខ E3 ហើយយើងឃើញហើយថា មានការពន្យារនៅក្នុងការទទួលយកឯកសារ E3 ។ ហើយឯកសារដែលនៅចំពោះមុខលោក លោកស្រីចៅក្រមនេះ គឺមិនទាន់បានដាក់លេខឯកសារ E3 នៅឡើយទេ ដែលយើងមាននៅក្នុងឧបសម្ព័ន្ធ ប៉ុន្តែឯកសារទាំងឡាយដែលមានដាក់លេខ E3 នេះត្រូវបានដកចេញពីបញ្ជីរួចហើយ ។ ដូច្នេះហើយការដែលស្នើសុំទៅចំណុចនេះយើងខ្ញុំសូមលើកឡើងថាលេខ E3 នេះគួរតែដាក់ចូលទៅលើឯកសារទាំងស្រុង ឬក៏យើងមិនត្រូវដាក់តែឯកសារពីរបីទំព័រ ដែលយើងបានពិភាក្សាគ្នាទៅលើចំណុចនេះទេ ។

ដើម្បីឲ្យលោក លោកស្រីចៅក្រម អាចមានឯកសារទាំងមូលក្នុងការពិចារណាទៅលើសាលក្រម ហើយប្រសិនបើមានការប្តឹងសារទុក្ខអីផ្សេងនោះ គឺគេអាចយកពិចារណា-- គេអាចយកឯកសារទាំងនោះមកពិចារណាផងដែរ ។ ដូច្នេះហើយ ការលើកឡើងរបស់ខ្ញុំគឺថាឯកសារទាំងអស់ដែលមានលេខ ERN អាចហើយ រួចហើយនោះគឺយើងគួរតែផ្តល់ឋានៈលេខ E3 ដើម្បីឲ្យយើងបញ្ជាក់ថា យើងអាចបញ្ចូលនៅក្នុងសេចក្តីសម្រេចរបស់យើងបាន ។ ដូច្នេះហើយនេះ ជាការលើកឡើងទៅលើសំណើរបស់ខ្ញុំចុងក្រោយលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក ហ្វេង់ស្វ័រ រូ៖**

ខ្ញុំមិនឆ្លើយតបទៅនឹងចំណុចហ្នឹងទេ ប៉ុន្តែខ្ញុំសូមលើកចំណុចនូវចំណុចបញ្ជាក់មួយ ខ្ញុំស្នើសុំថា គ្រប់ឯកសារទាំងអស់ដែលនឹងត្រូវដាក់នៅចំពោះមុខអង្គសវនាការរបស់យើងត្រូវដាក់ចូលនៅក្នុងគេហទំព័រ ។ ដូច្នេះហើយ យើងមិនអាចដាក់នៅក្នុងគេហទំព័រនោះទេ ដោយសារតែពេលដែលយើងអាចដាក់បាននោះគឺយើងគោរពទៅលើជនរងគ្រោះ ។ នៅពេលដែលចំណាររបស់ ឌុច បានដេញដោលនៅក្នុងតុលាការ យើងឃើញថាឯកសារដំបូង-- ទំព័រដំបូងនោះអាចដាក់នៅក្នុងគេហទំព័រយើងបាន ។ ហើយប្រសិនបើយើងចង់ចងចាំអំពីការចងចាំរបស់ជនរងគ្រោះនោះ យើងមិនគួរដាក់ចម្លើយសារភាពទាំងមូលនៅក្នុងគេហទំព័រនោះទេ យើងដាក់តែទំព័រដើមបានហើយ ។ ខ្ញុំចង់ទាញចំណុចនេះឲ្យលោកចៅក្រមបានជ្រាប ។ ដូច្នេះចំណុចរបស់ខ្ញុំគឺខ្ញុំចង់លើកឡើងដូច្នេះ ។ ហើយមានតែចម្លើយសារភាព ឬចំណារទាំងឡាយដែលបានដេញដោលនៅក្នុងតុលាការរបស់យើងទេដែលគួរដាក់ចូលទៅក្នុងអង្គជំនុំជម្រះរបស់យើង ។ សូមអរគុណ ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១៩:៥៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកប្រធានជាទីគោរព! ខ្ញុំចង់សួរសំណួរចុងក្រោយពីខាងសហព្រះរាជអាជ្ញា ។ យើងខ្ញុំយល់ហើយថា សហព្រះរាជអាជ្ញាចង់ឲ្យដំណើរការជំនុំជម្រះប្រព្រឹត្តទៅលឿន ប៉ុន្តែយើងខ្ញុំមានសំណួរមួយចង់សួរទៅកាន់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងឯកសារចំនួន៦០ ដែលវាមានចំណាររបស់ជនជាប់ចោទដោយផ្ទាល់ ។ ថាតើលោកសហព្រះរាជអាជ្ញាមានបំណងចង់ដាក់ឯកសារនេះចំពោះមុខតុលាការឬក៏យ៉ាងម៉េច? រួមទាំងឯកសារដែលមិនបានពិភាក្សាដេញដោលតទល់គ្នាផងដែរ ថាតើលោកចង់ដាក់កម្រិតទៅលើឯកសារ លោកចង់ស្នើដាក់តែឯកសារដែលវាបានតទល់គ្នាហើយ ឬក៏យ៉ាងម៉េច? ហើយប្រសិនបើវាអ៊ីចឹងមែន គឺវាមានបញ្ហា ដោយសារតែមេធាវីការពារក្តីនោះ គាត់គួរតែមានឱកាសក្នុងការដាក់សេចក្តីសន្និដ្ឋានរបស់គាត់ទាក់ទងទៅនឹងឯកសារភស្តុតាងដែលមិនទាន់បានពិភាក្សាគ្នាដេញដោលតាំងពីមុន ។

ដូច្នេះអ្វីដែលយើងខ្ញុំចង់ដឹងថា តើខាងការិយាល័យសហព្រះរាជអាជ្ញាយល់ស្របដែរឬទេ ថាគួរតែកម្រិតការស្នើសុំដាក់ឯកសាររបស់គាត់ត្រឹមតែដាក់ឯកសារដែលបានពិភាក្សាគ្នាដេញដោលរួចហើយតែប៉ុណ្ណោះបានហើយ ។ ដោយយើងត្រូវចាំទុកថា អម្បាញ់មិញនេះមេធាវីការពារក្តីបានលើកឡើងអំពីឯកសារ ដែលបានបង្កើតដោយតំណាងសហព្រះរាជអាជ្ញា ហើយចំពោះខ្ញុំនោះ ឯកសារនោះ គឺឯកសារដែលបានបង្ហាញជនជាប់ចោទដោយផ្ទាល់រួចហើយ ។ ហើយពេលខ្លះទៅក៏បានបង្ហាញជូនអង្គជំនុំជម្រះរួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ។

**លោក អានីស អះមេដ៖**

លោកចៅក្រមជាទីគោរព! ខ្ញុំមិនទាន់បានឆ្លើយនៅទីនោះទេ ហើយការអនុញ្ញាតពីលោកចៅក្រមហើយប្រសិនបើយើងពន្យារពេលសវនាការត្រឹមនេះសិន ហើយខ្ញុំនឹងឆ្លើយតបទៅនៅព្រឹកថ្ងៃស្អែក ។ ដោយយើងខ្ញុំនឹងឆ្លើយតបទៅនឹងចម្លើយរបស់លោកចៅក្រម ។ ប៉ុន្តែ នៅពេលនេះខ្ញុំស្នើសុំថា នៅពេលនេះយើងគួរតែទុកសិន ហើយយើងខ្ញុំនឹងឆ្លើយនៅព្រឹកស្អែក ហើយខ្ញុំនឹងទុកពេលដើម្បីពិភាក្សាជាមួយនឹងមេធាវីការពារក្តី ហើយប្រសិនបើយើងមិនផ្អាកនៅពេលនេះសិនទេ យើងខ្ញុំនឹងផ្តល់ការឆ្លើយតបរបស់ខ្ញុំនៅពេលនេះតែម្តង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំមានសំណួរមួយសួរទៅកាន់មេធាវីការពារក្តី ។ ថាតើមេធាវីការពារក្តីមានឯកសារណាផ្សេងដែលចង់ដាក់នៅចំពោះមុខតុលាការដែរឬទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

អង្គជំនុំជម្រះមានបញ្ជីរបស់យើងខ្ញុំហើយ ទាក់ទងទៅនឹងឯកសារដែលយើងបានដាក់ជូន គឺឯកសារ D80 ។ នៅពេលដែលយើងចាប់ផ្តើមសវនាការ ដែលយើងមានឯកសារលេខ E59 យើងបានដាក់ឯកសារមួយចំនួនហើយនៅពេលចំពោះមុខតុលាការរបស់យើង ។ ឯកសារទាំងអស់នោះ គឺទាក់ទងទៅនឹងឯកសារសៀវភៅ ហើយនិងរូបភាពវីដេអូ និងប្រតិចារឹកជាលាយលក្ខណ៍អក្សរទាក់ទងទៅនឹងករណី អុប្រេីណូរិច ផងដែរ ។

យើងមានឯកសារមួយទៀត ដែលវាជាឯកសារមួយទំនងមើលទៅដូចជាថ្មីដែរ ។ គឺជាឯកសារនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរចម្លើយ ផ្តល់ឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ីគាត់បានផ្តល់ការសម្ភាសន៍នេះទៅដល់កាសែតបារាំង ហើយយើងខ្ញុំមិនមានបំណងដាក់ឯកសារនេះចំពោះ

មុខតុលាការនោះទេ រហូតដល់យើងបានឃើញវីដេអូនោះជាមុន ។

ដូច្នេះហើយនៅពេលនេះយើងខ្ញុំស្នើសុំដាក់ឯកសារនេះនៅចំពោះមុខតុលាការតែម្តង។ ទាំងអស់នេះគឺជាឯកសារថ្មី ហើយឯកសារដទៃទៀតនោះគឺយើងបានដាក់ជាសាធារណៈ និងផ្សាយជាសាធារណៈរួចហើយ ។ ដូច្នេះហើយយើងខ្ញុំមិនចំណាយពេលច្រើនទៀតទេនៅពេលនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលត្រូវសម្រាកនៅពេលរសៀលហើយ ៗតទៅទៀតក៏អត់ចប់ដែរ ដោយសារនៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបីក្រុមទៀតក៏មិនបានបង្ហាញពីការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ដែលគាត់មានបំណងនឹងដាក់នោះដែរ ។ ហើយនៅការឆ្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះការដាក់ឯកសាររបស់មេធាវីការពារក្តីទៀត ។ អ៊ីចឹងឃើញនៅមានបញ្ហាច្រើន ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹក ។

អនុរក្សមន្ទីរឃុំឃាំងឲ្យជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនេះនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនជាកំហិត ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង ១៦:២៦នាទី]*